## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាល កូរ៉េលើវិស័យអប់រំនៅកម្ពុជាតាមរយៈ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ

# ( KOICA )

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៩


តាក់តែងឡើងដោយ

និស្សិតឈ្មោះ: **អៀង គីមហ៊ុយ**

**ឆូ រនីន**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី៣

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **អៀង គីមហ៊ុយ** និង **ធូ វេនីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៣ ក្រុមD4B1 និងD4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងនាមយើងខ្ញុំជានិស្សិត យើងខ្ញុំមានកិត្តិយសយ៉ាងខ្លាំងដែលមាន ឱកាសបានសិក្សាស្រាវជ្រាវ ហើយព្រមទាំងបានរៀបរៀងឯកសារមួយច្បាប់នេះឡើង។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

លោកអ្នកមានគុណទាំងបួន ដែលលោកទាំងពីរតែងតែជួយជ្រោមជ្រែង ហើយបានលះបង់ទាំងកម្លាំងកាយនិងចិត្ត ព្រមជាមួយនឹងឧបត្ថម្ភជាថវិកាក្នុងការស្រាវជ្រាវ និងអ្វីដែលមិនអាចបំភ្លេចបាននោះគឺ លោកទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ និងតម្រង់ទិសក្នុងការសិក្សា ទើបយើងខ្ញុំទាំងពីរនាក់អាចមានលទ្ធផលដូចថ្ងៃនេះ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស និងព្រឹទ្ធបុរសរង លោកលោកស្រីដែលជាបុគ្គលិកការិយាល័យ និងដេប៉ាតឺម៉ង់ លោក និងលោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន និងជួយសម្រួលដល់ការសិក្សារបស់យើងខ្ញុំរយៈពេលបួនឆ្នាំនេះ។

សូមថ្លែងអំណរគុណជាពិសេសដល់លោកសាស្ត្រាចារ្យ បណ្ឌិត **ឈុន ពហុ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្ហាញ ផ្តល់ជាគំនិត និងខិតខំកែលម្អ ព្រមទាំងបង្ហាញមាគ៌ាក្នុងការសរសេរនូវឯកសារស្រាវជ្រាវមួយច្បាប់នេះ។

សូមថ្លែងអំណរគុណជាពិសេសដល់ លោកគ្រូ **យុន សីហា** ដែលជាអនុប្រធានការិយាល័យសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ នាយកដ្ឋានផែនការ ក្នុងអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ នៃក្រសួង អប់រំ យុវជន និងកីឡា ដែលលោកបានចំណាយពេលដ៏មានតម្លៃរបស់លោក បើទោះបីជាមិនបានជួបដោយផ្ទាល់ ក៏លោកបានជួយផ្តល់ជាគន្លឹះស្រាវជ្រាវឯកសារពាក់ព័ន្ធនានាដល់យើងខ្ញុំទាំងពីរនាក់ផងដែរ។

កញ្ញា **នូ សុខធី** ជាមិត្តរួមថ្នាក់ ដែលបានជួយផ្តល់នូវមតិយោបល់ និងគំនិតល្អៗ ថែមទាំងបានជួយត្រួតពិនិត្យ និងកែតម្រូវនូវអក្ខរាវិរុទ្ធ និងអត្ថបទ ពិសេសនោះគឺ បានជួយជាកម្លាំងចិត្តក្នុងការសរសេររបាយការណ៍មួយនេះដោយជោគជ័យ។

មិត្តភក្តិ ដែលជាសមាជិកក្នុងក្រុមការងារ និងមិត្តិភក្តិដែលបានផ្តល់ជាគំនិតនៅក្នុងការស្រាវជ្រាវសៀវភៅមួយក្បាលនេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមលើហត្ថប្រណម្យបង្ហាញដល់វត្ថុស័ក្តិសិទ្ធក្នុងលោកនេះ សូមប្រសិទ្ធិពរជ័យ សិរីមង្គលចូលកើតមានដល់អ្នកមានគុណដែលបានរៀបរាប់ខាងលើ ព្រមទាំងបណ្តាមិត្តអ្នកអានទាំងអស់កុំបីឃ្លាងឃ្លាតឡើយ ព្រោះបើគ្មានអ្នកទាំងអស់គ្នាទេ សៀវភៅឯកសារស្រាវជ្រាវមួយក្បាលនេះក៏មិនអាចលេចចេញជារូបរាងបានដែរ។

# អារម្ភកថា

ក្រោយពីទទួលការអប់រំនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំមកនេះ យើងខ្ញុំបានធ្វើដំណើរមកដល់ទីបញ្ចប់នៃការសិក្សាថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍។ មុននឹងបញ្ចប់ការសិក្សានេះ យើងខ្ញុំពិតជាមានអារម្មណ៍សោមនស្សរីករាយយ៉ាងខ្លាំង ដែលបានបន្សល់ទុកនូវស្នាដៃមួយសម្រាប់អ្នកជំនាន់ក្រោយនោះគឺ សារណាបញ្ចប់ការសិក្សាដែលមានចំណងជើងថា **"ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េលើវិស័យអប់រំនៅកម្ពុជា តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)"**។ ការជ្រើសរើសប្រធានបទមួយនេះមកសិក្សាស្រាវជ្រាវ យើងខ្ញុំពិតជាមិនងាយស្រួលទេ តែដោយសារការជួយជ្រោមជ្រែង និងបង្ហាត់បង្ហាញពីលោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** ព្រមទាំងតាមរយៈការខិតខំស្វែងរក រួមជាមួយការស្រាវជ្រាវ ពីសំណាក់យើងខ្ញុំទាំងពីរផងនោះ យើងខ្ញុំបានសម្រេចសៀវភៅស្រាវជ្រាវដែលកំពុងមានវត្តមានចំពោះមុខអ្នកអានទាំងអស់គ្នានេះ។

ហេតុដែលក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទនេះ ដោយយើងខ្ញុំសង្កេតឃើញថា ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលកូរ៉េ កំពុងតែមានភាពជិតស្និត ដោយមានការសហការអភិវឌ្ឍន៍ សេដ្ឋកិច្ចនិងសង្គមនៅកម្ពុជាកាន់តែសម្បូរបែប ស្របពេលប្រទេសកំពុងអភិវឌ្ឍន៍នេះ កំពុងមានការផ្តោតអាទិភាពខ្ពស់លើការអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន ក្នុងគោលបំណងសម្រេចឲ្យបាននូវចក្ខុវិស័យក្លាយខ្លួនជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ហេតុនេះ យើងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវពីការរួមចំណែកជំនួយអភិវឌ្ឍន៍ផ្លូវការរដ្ឋាភិបាលកូរ៉េលើវិស័យអប់រំកម្ពុជា។ ទន្ទឹមនឹងនេះដែរ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសៀវភៅសារណាបញ្ចប់ការសិក្សានេះអាចជួយមិត្តអ្នកស្រាវជ្រាវ ក៏ដូចជាប្អូនៗនិស្សិតជំនាន់ក្រោយទុកជាឯកសារ និងជាពិសេសសម្រាប់ប្អូននិស្សិតណាដែលចង់ធ្វើការស្រាវជ្រាវ លើប្រធានបទដែលទាក់ទងនឹងជំនួយអភិវឌ្ឍន៍ផ្លូវការលើវិស័យអប់រំកម្ពុជា ដើម្បីទុកជាទុនក្នុងការស្រាវជ្រាវរបស់ប្អូនផងដែរ ។

ជាចុងក្រោយ អាស្រ័យដោយការយល់ដឹងនៅមានកម្រិត ខ្វះខាតបទពិសោធន៍ក្នុងការអនុវត្តជាកស្តែង រួមនឹងឯកសារពុំសូវសម្បូរបែប យើងខ្ញុំទាំងពីរនាក់ជឿជាក់ថាប្រាកដជាមានកំហុសឆ្គង និងចំណុចខ្វះខាតជាក់ជាពុំខាន ។ ដូចនេះហើយ យើងខ្ញុំទាំងពីរសូមលើកម្រាមដៃដប់ខន្តីអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយ និងស្វាគមន៍រាល់មតិរិះគន់ដើម្បីស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោក លោកស្រី និងមិត្តសិស្សនិស្សិត ដើម្បីកែលម្អសៀវភៅនេះឲ្យប្រសើរជាងមុន ។

## មាតិកា

បញ្ជីអក្សរកាត់ ....................................................................................................vii
បញ្ជីតារាង ................................................................................................................ ix
បញ្ជីរូបភាព ................................................................................................................ x
បញ្ជីក្រាហ្វិក ............................................................................................................. xi
បញ្ជីឧបសម្ព័ន្ធ ............................................................................................................ xii

## សេចក្តីផ្តើម

១. លំនាំបញ្ហា ............................................................................................................ ១
២. ចំណោទបញ្ហា .......................................................................................................... ២
៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ............................................................................ ៣
៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ................................................................. ៣
៥. វិធីសាស្រ្តក្នុងការស្រាវជ្រាវ .......................................................................................... ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ........................................................................................ ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ......................................................................................... ៤

## ជំពូកទី ១ រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងជំនួយអភិវឌ្ឍន៍ផ្លូវការ និងការអប់រំ

១.១. និយមន័យ ............................................................................................................ ៦
១.១.១. ជំនួយអភិវឌ្ឍន៍ផ្លូវការ ........................................................................................ ៦
១.១.២. ការអប់រំ ............................................................................................................. ៦
១.២. ទ្រឹស្តី និងការសិក្សាអំពី កំណើន និងជំនួយលើវិស័យអប់រំ ............................................ ៨
១.២.១. ទ្រឹស្តីពួកនេអូក្លាសិក (Neoclassical Theory) ........................................................ ៨
១.២.២. ទ្រឹស្តីពួកអែនឌូស្សែនឹស (Endogenous Theory) .................................................... ៨
១.២.៣. ការសិក្សាស្រាវជ្រាវរបស់លោក Dreher et al ........................................................... ៩
១.៣. សញ្ញាណទូទៅនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ..................................................................... ៩
១.៣.១. ប្រវត្តិនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ ................................................................... ៩
១.៣.២. ប្រតិបត្តិការរបស់គណៈកម្មាធិការផ្តល់ជំនួយដើម្បីកិច្ចអភិវឌ្ឍន៍ ............................... ១១

១.៣.៣. ប្រភេទនៃជំនួយអភិវឌ្ឍន៍ ............ ១២
១.៣.៣.១. កិច្ចសហប្រតិបត្តិការបច្ចេកទេស ............ ១២
១.៣.៣.២. កិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ការវិនិយោគ ............ ១២
១.៣.៣.៣. ជំនួយគម្រោងវិនិយោគ ............ ១២
១.៣.៣.៤. ជំនួយទ្រទ្រង់ថវិកា ឬតុល្យការជញ្ជីងទូទាត់ ............ ១៣
១.៣.៣.៥. ជំនួយជាស្បៀងអាហារ ............ ១៣
១.៣.៣.៦. ជំនួយមនុស្សធម៌ និងសង្គ្រោះបន្ទាន់ ............ ១៣
១.៣.៤. កត្តាដែលជំរុញឲ្យមានការផ្តល់ ODA ពីប្រទេសអភិវឌ្ឍន៍ ............ ១៣
១.៣.៤.១. កត្តានយោបាយ និងការទូត ............ ១៤
១.៣.៤.២. កត្តាសេដ្ឋកិច្ច ............ ១៤
១.៣.៤.៣. កត្តាមនុស្សធម៌ ............ ១៤
១.៣.៤.៤. កត្តាសមាគមឯករាជ្យពិភពលោក ............ ១៥
១.៣.៥. ផលវិជ្ជមានចំពោះប្រទេសកំពុងអភិវឌ្ឍន៍ដែលទទួល ODA ............ ១៥
១.៤. ការផ្តល់ ODA របស់កូរ៉េ ............ ១៦
១.៤.១. ប្រវត្តិនៃការផ្តល់ ODA របស់កូរ៉េ ............ ១៦
១.៤.២. ការចាត់ថ្នាក់ ODA របស់កូរ៉េ ............ ១៧
១.៤.៣. ក្របខណ្ឌផ្លូវច្បាប់នៃការផ្តល់ ODA របស់កូរ៉េ ............ ១៨
១.៤.៤. គោលនយោបាយជំនួយអភិវឌ្ឍន៍ផ្លូវការរបស់កូរ៉េ ............ ២០
១.៤.៥. ប្រព័ន្ធគ្រប់គ្រង ODA របស់កូរ៉េ ............ ២២
១.៤.៦. ដំណើរការនៃការអនុម័តថវិកាជាតិសំខាន់ៗប្រចាំឆ្នាំរបស់កូរ៉េ ............ ២៥
១.៥. ប្រវត្តិវិស័យអប់រំនៅកម្ពុជាក្រោយឆ្នាំ ១៩៧៩ ............ ២៦
១.៦. យុទ្ធសាស្ត្រពង្រឹងគុណភាពអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជា ............ ២៧
១.៧. គោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ............ ៣០
១.៨. បញ្ហាប្រឈម និងដំណោះស្រាយក្នុងវិស័យអប់រំកម្ពុជា ............ ៣១
១.៨.១. បញ្ហាប្រឈម ............ ៣១

១.៨.១.១. បញ្ហាពាក់ព័ន្ធនឹងគ្រូបង្រៀន ..... ៣១
១.៨.១.២. បញ្ហាសមត្ថភាពបុគ្គលិកក្នុងស្ថាប័នអប់រំ ..... ៣២
១.៨.១.៣. បញ្ហាការគ្រប់គ្រង ..... ៣៣
១.៨.១.៤. បញ្ហាទាក់ទងនឹងសាលារៀន ..... ៣៣
១.៨.២. ដំណោះស្រាយ ..... ៣៥
១.៩. ស្ថានភាពនៃទំនាក់ទំនងរវាងប្រទេសកម្ពុជា និងកូរ៉េ ..... ៣៨
១.១០. នីតិវិធីនៃការផ្តល់គម្រោងជំនួយឥតសំណង ..... ៣៩
១.១១. បទពិសោធការផ្តល់ជំនួយឥតសំណងរបស់កូរ៉េក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ..... ៤០
១.១១.១. ជំនួយលើការអប់រំរបស់ KOICA នៅវៀតណាម ..... ៤០
១.១១.១.១ យុទ្ធសាស្ត្រលើកកម្ពស់ការអប់រំរបស់ KOICA ..... ៤១
១.១១.១.២. គម្រោងក្នុងវិស័យអប់រំដែល KOICA បាននិងកំពុងអនុវត្តន៍ ..... ៤២
១.១១.១.៣. សមិទ្ធផលដែលទទួលបាន ..... ៤៣
១.១១.២.បទពិសោធជំនួយលើការអប់រំរបស់ KOICA នៅឡាវ ..... ៤៣
១.១១.២.១. យុទ្ធសាស្ត្រលើកកម្ពស់ការអប់រំរបស់ KOICA ..... ៤៤
១.១១.២.២. ការអនុវត្តរបស់ KOICA ..... ៤៥
១.១១.២.៣. សមិទ្ធផលដែលទទួលបាន ..... ៤៥
១.១២. គម្រោងជំនួយឥតសំណងទ្វេភាគី កម្ពុជា-កូរ៉េ តាមវិស័យ ..... ៤៦
១.១២.១. វិស័យសុខាភិបាល ..... ៤៦
១.១២.២. វិស័យអប់រំ ..... ៤៧
១.១២.៣. វិស័យដឹកជញ្ជូន ..... ៤៨
១.១២.៤. វិស័យទឹក ..... ៤៩
១.១២.៥. វិស័យថាមពល ..... ៤៩
១.១២.៦. វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងភាពច្នៃប្រឌិត (STI) ..... ៤៩
១.១២.៧. វិស័យកសិកម្មនិងការអភិវឌ្ឍជនបទ ..... ៥០
១.១២.៨. វិស័យសេដ្ឋកិច្ច ..... ៥០

១.១២.៩. វិស័យបរិស្ថាន ........................................................................................................ ៥១
១.១២.១០. វិស័យវប្បធម៌ ................................................................................................... ៥១

## ជំពូកទី ២ ស្ថានភាពទូទៅនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការតាមរយៈ KOICA លើវិស័យអប់រំកម្ពុជា

២.១. ទិដ្ឋភាពទូទៅរបស់ KOICA .............................................................................................. ៥២
២.១.១. ប្រវត្តិរបស់ KOICA ........................................................................................................ ៥២
២.១.១.១. KOICA ការិយាល័យកណ្តាល ....................................................................................... ៥២
២.១.១.២. KOICA ប្រចាំប្រទេសកម្ពុជា ....................................................................................... ៥៣
២.១.២. ទីតាំងរបស់ការិយាល័យ KOICA ប្រចាំកម្ពុជា ...................................................................... ៥៣
២.១.៣. ចក្ខុវិស័យ និងបេសកកម្ម .................................................................................................. ៥៤
២.១.៣.១. KOICA ការិយាល័យកណ្តាល ...................................................................................... ៥៤
២.១.៣.២. KOICA លើវិស័យអប់រំ ................................................................................................ ៥៤
២.១.៤. រចនាសម្ព័ន្ធគ្រប់គ្រង .......................................................................................................... ៥៥
២.២. យុទ្ធសាស្ត្រភាពជាដៃគូរបស់សាធារណៈរដ្ឋកូរ៉េសម្រាប់ព្រះរាជាណាចក្រកម្ពុជា ........ ៥៥
២.៣. គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) ........................................................................................................................ ៥៧
២.៤. នីតិវិធីនៃការស្នើជំនួយលើគម្រោង និងវដ្តនៃការអនុម័តគម្រោងពី KOICA ................. ៥៨
២.៤.១. នីតិវិធីនៃការស្នើជំនួយលើគម្រោងពី KOICA ................................................................ ៥៨
២.៤.២. វដ្តគម្រោងជំនួយឥតសំណងរបស់ KOICA ...................................................................... ៥៩
២.៥. ជំនួយឥតសំណងលើវិស័យអប់រំកម្ពុជាតាមរយៈ KOICA ............................................. ៦១
២.៥.១. ជំនួយជាសម្ភារ ឧបករណ៍សិក្សា ....................................................................................... ៦១
២.៥.២. ជំនួយលើគម្រោងការអប់រំ ................................................................................................ ៦២
២.៥.២.១. គម្រោងអប់រំទ្វេភាគីទូទៅ .............................................................................................. ៦២
២.៥.២.២. គម្រោងសាងសង់អាគារសិក្សា ....................................................................................... ៦៤
២.៥.៣. គម្រោងអភិវឌ្ឍន៍វិស័យអប់រំកម្ពុជានាពេលបច្ចុប្បន្ន ............................................................ ៦៥

២.៥.៤. គម្រោងសាងសង់អាគារមជ្ឈមណ្ឌលសិក្សានៅកម្ពុជានាពេលអនាគត ........... ៦៦
២.៥.៥. កិច្ចសហប្រតិបត្តិការបច្ចេកទេស ........................................................ ៦៧
២.៥.៥.១. ការផ្តល់កម្មវិធីបណ្តុះបណ្តាល ........................................................ ៦៧
២.៥.៥.២. ការបញ្ជូនអ្នកជំនាញ .........................................................................៧៣
២.៥.៥.៣. ការបញ្ជូនគ្រូបង្រៀនតៃក្វាន់ដូ ........................................................ ៧៥
២.៥.៥.៤. កម្មវិធីអ្នកស្ម័គ្រចិត្តរបស់ KOICA ................................................... ៧៦
២.៥.៦. ផ្សេងៗទៀត ..................................................................................... ៨៥
២.៥.៦.១. សមាគមអតីតកម្មសិក្សាការី កម្ពុជា-កូរ៉េ (CAMKAA) ............................ ៨៥
២.៥.៦.២. ក្រុមសុខសប្បាយ (SST) .................................................................. ៨៦

## ជំពូកទី ៣ ការសិក្សាលើលទ្ធផលស្រាវជ្រាវ

៣.១. សមិទ្ធផល និង ការវាយតម្លៃ ..........................................................................៨៨
៣.១.១. សមិទ្ធផលលើវិស័យអប់រំ ................................................................... ៨៨
៣.១.២. ការវាយតម្លៃ ..................................................................................... ៩២
៣.១.២.១. ការកើនឡើងធនធានមនុស្ស និងកាត់បន្ថយការចំណាយលើការអប់រំ .... ៩២
៣.១.២.២. ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច ..............................៩៣
៣.១.២.៣. ការរួមចំណែកក្នុងសង្គមខ្មែរ ...........................................................៩៤
៣.១.២.៤. ការទាក់ទាញវិនិយោគិនពីបរទេស.....................................................៩៥
៣.១.២.៥. ការកសាងកិត្តិយសជូនជាតិ ........................................................... ៩៦
៣.២. បញ្ហាប្រឈម និងដំណោះស្រាយ .....................................................................៩៧
៣.២.១. បញ្ហាប្រឈម ..................................................................................... ៩៧
៣.២.១.១. អំឡុងពេលសហការអនុវត្តន៍គម្រោង.................................................. ៩៧
៣.២.១.២. ក្រោយពេលបញ្ចប់គម្រោង ............................................................. ៩៨
៣.២.១.៣. ភាពស្មុគស្មាញនៅក្នុង KOICA ..........................................................៩៩
៣.២.១.៤. ចំពោះអ្នកស្ម័គ្រចិត្តរបស់ KOICA នៅកម្ពុជា ...................................... ១០០
៣.២.២. ដំណោះស្រាយ ..................................................................................១០១

៣.២.២.១. អំឡុងពេល និងក្រោយពេលអនុវត្តន៍គម្រោង ..................................... ១០១
៣.២.២.២. ចំពោះភាពស្មុគស្មាញក្នុងស្ថាប័នកូរ៉េ ................................................ ១០៣
៣.២.២.៣. ចំពោះអ្នកស្ម័គ្រចិត្តកូរ៉េ KOICA ប្រចាំកម្ពុជា ..................................... ១០៧

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ................................................................................................ ១០៩
២. អនុសាសន៍................................................................................................................ ១១១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពន្យល់ |
|---|---|
| CAMKAA | Cambodia-Korea Alumni Association<br>សមាគមអតីតកម្មសិក្សាការី កម្ពុជា-កូរ៉េ ឬហៅកាត់ថា ស.អ.ក.ក. |
| CATC | Civil Aviation Training Center<br>មជ្ឈមណ្ឌលបណ្តុះបណ្តាលអាកាសចរណ៍ស៊ីវិល |
| CDC | The Council for the Development of Cambodia<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDRI | Cambodia Development Resource Institute<br>វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា |
| CIAT | Capacity Improvement and Advancement for Tomorrow<br>ការពង្រឹង និងការបង្កើនសមត្ថភាពសម្រាប់ថ្ងៃស្អែក |
| CIDC | Committee for International Development Cooperation<br>គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ |
| CKCC | Cambodia-Korea Cooperation Center<br>មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ |
| CKTTC | Cambodia-Korea Taekwondo Training Center<br>សាលហ្វឹកហាត់តៃក្វាន់ដូ កម្ពុជា-កូរ៉េ |
| CLMV | Cambodia, Laos, Myanmar, and Vietnam<br>កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម |
| CRDB | Cambodian Rehabilitation and Development Board<br>គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា |
| DAC | Development Assistance Committee<br>គណៈកម្មាធិការផ្តល់ជំនួយដើម្បីកិច្ចអភិវឌ្ឍន៍ |
| EDCF | Economic Development Cooperation Fund<br>មូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច |
| GNI | Gross National Income<br>ប្រាក់ចំណូលជាតិសរុប |

| | |
|---|---|
| ICT | Information and Communications Technology<br>បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង |
| KCNSA | Kampong Cham National School of Agriculture<br>សាលាជាតិកសិកម្មកំពង់ចាម |
| KOICA | Korea International Cooperation Agency<br>ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| KOVs | Korean Oversea Volunteers<br>អ្នកស្ម័គ្រចិត្តជនជាតិកូរ៉េនៅក្រៅប្រទេស |
| MoEYS | Ministry of Education, Youth and Sport<br>ក្រសួងអប់រំ យុវជន និងកីឡា |
| MOFAT | Ministry of Foreign Affair and Trade<br>ក្រសួងការបរទេស និងពាណិជ្ជកម្ម |
| MOSF | Ministry of Strategy and Finance<br>ក្រសួងយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ |
| NIPES | National Institute of Physical Education and Sport<br>វិទ្យាស្ថានជាតិអប់រំ និងកីឡា |
| NTTI | National Technical Training Institute<br>វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស |
| OECD | Organization for Economic Cooperation and Development<br>អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច |
| PPP | Public-Private Partnership<br>ភាពជាដៃគូរវាងសាធារណៈ-ឯកជន |
| SMU | Saemaul Undong<br>វិធីសាស្ត្រចលនាភូមិថ្មី |
| TVET | Technical and Vocational Education and Training<br>ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| អ.ស.ហ. | អង្គការសហប្រជាជាតិ |

# បញ្ជីតារាង


តារាងទី២.១ ៖ ចំនួនថវិកាដែលចំណាយដោយរដ្ឋាភិបាលកូរ៉េលើកម្មវិធីអាហារូបករណ៍... ៧២
តារាងទី២.២ ៖ ទិន្នន័យការបញ្ជូនអ្នកជំនាញចាប់តាំងពីឆ្នាំ ១៩៩៦-២០១០ ......................៧៤
តារាងទី២.៣ ៖ ចំនួននៃការបញ្ជូនគ្រូបង្រៀនតៃក្វាន់ដូគិតចាប់ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២០០៨៧៥
តារាងទី២.៤ ៖ បច្ចុប្បន្នភាពចំនួនសហប្រតិបត្តិការ KOVs គិតត្រឹមខែ តុលា ឆ្នាំ ២០១៧....៧៩
តារាងទី២.៥ ៖ សកម្មភាពកិច្ចសហប្រតិបត្តិការរបស់ KOVs ក្នុងឆ្នាំ ២០១៨ ...................... ៨០
តារាងទី២.៦ ៖ ទិន្នន័យអ្នកស្ម័គ្រចិត្ត WFK Advisors តាមស្ថាប័ននានានៅកម្ពុជា ចាប់ពីឆ្នាំ ២០១២ - ២០១៦ ........................................................................ ៨២
តារាងទី២.៧ ៖ បច្ចុប្បន្នភាពសហប្រតិបត្តិការរបស់អ្នកស្ម័គ្រចិត្ត WFK Advisors គិតត្រឹមខែ តុលា ឆ្នាំ ២០១៧ ........................................................................ ៨៤

# បញ្ជីរូបភាព


រូបភាពទី១ ៖ ទីតាំងរបស់ KOICA ប្រចាំនៅកម្ពុជា ........................................................ ៥៣

រូបភាពទី២ ៖ ផែនទីបច្ចុប្បន្នភាពបែងចែកអ្នកស្ម័គ្រចិត្តរបស់ KOICA នៅកម្ពុជាគិតត្រឹមខែតុលា ២០១៧ .......................................................................................... ៨៥

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១.១ ៖ ចំនួនទឹកប្រាក់ជំនួយអភិវឌ្ឍន៍ផ្លូវការគិតសំណាងសមមូលជាភាគរយនៃ GNI របស់ប្រទេសដែលជាសមាជិក OECD DAC ក្នុងឆ្នាំ ២០១៨.................... ១១

ក្រាហ្វិកទី២.១ ៖ សមាមាត្រសិក្ខាកាមតាមវិស័យ ........................................................... ៧៣

ក្រាហ្វិកទី២.២ ៖ បង្ហាញពីបច្ចុប្បន្នភាពនៃសមាមាត្រអ្នកស្ម័គ្រចិត្តកូរ៉េតាមផ្នែក ឆ្នាំ ២០១៨. ៨១

ក្រាហ្វិកទី២.៣ ៖ អ្នកស្ម័គ្រចិត្ត WFK Advisors នៅតាមក្រសួងក្នុងឆ្នាំ ២០១៨ .................... ៨៤

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ ៖ កញ្ចប់ថវិកានៃODAរដ្ឋាភិបាលកូរ៉េ ដែលបានមកពីស្ថាប័ននានា ឆ្នាំ២០១៩

ឧបសម្ព័ន្ធទី២ ៖ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤

ឧបសម្ព័ន្ធទី៣ ៖ សមិទ្ធផលពានរង្វាន់អូឡាំព្យាដអន្តរជាតិឆ្នាំ២០១៦-២០១៧ និង ២០១៧-២០១៨ នៃប្រទេសវៀតណាម

ឧបសម្ព័ន្ធទី៤ ៖ តារាងទិន្នន័យនៃការផ្តល់ជំនួយឥតសំណងរបស់កូរ៉េ លើវិស័យផ្សេងៗនៅកម្ពុជា ចាប់ពីឆ្នាំ១៩៩១ ដល់ ឆ្នាំ២០១៧

ឧបសម្ព័ន្ធទី៥ ៖ រចនាសម្ព័ន្ធអង្គភាពKOICA ការិយាល័យកណ្តាល

ឧបសម្ព័ន្ធទី៦ ៖ CPS កម្ពុជា ២០១៦-២០២០

ឧបសម្ព័ន្ធទី៧ ៖ បញ្ជីគម្រោងអាទិភាពសម្រាប់ឆ្នាំ ២០១៩

ឧបសម្ព័ន្ធទី៨ ៖ PCP របស់ KOICA

ឧបសម្ព័ន្ធទី៩ ៖ សេចក្តីប្រកាសស្តីពី ការផ្តល់អាហារូបករណ៍ដល់មន្ត្រី នៃក្រសួង ស្ថាប័នរដ្ឋនៅកម្ពុជា ឲ្យទៅសិក្សាថ្នាក់ បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់នៅកូរ៉េ

ឧបសម្ព័ន្ធទី១០ ៖ សេចក្តីណែនាំស្តីអំពី ការបំពេញពាក្យសុំអាហារូបករណ៍KOICA ឆ្នាំ២០១៩

ឧបសម្ព័ន្ធទី១១ ៖ លិខិតរដ្ឋបាលស្នើសុំចុះបញ្ជីរបស់ សមាគមអតីតកម្មសិក្សាការីកម្ពុជា-កូរ៉េ ក្រសួងមហាផ្ទៃ

ឧបសម្ព័ន្ធទី១២ ៖ តារាងសូចនាករទាក់ទងនឹងការអប់រំបឋមសិក្សា (ថ្នាក់ជាតិ)

ឧបសម្ព័ន្ធទី១៣ ៖ ក្រាហ្វិកភាពក្រីក្រក្នុងប្រជាជនម្នាក់ៗក្នុងកម្រិត ទូទាំងប្រទេស ជនបទ និងទីក្រុង នៅកម្ពុជា គិតចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១២

ឧបសម្ព័ន្ធទី១៤ ៖ សេចក្តីប្រកាសស្តីពី ការដេញថ្លៃគម្រោងODA

ឧបសម្ព័ន្ធទី១៥ ៖ ព័ត៌មាន និងកម្មវត្ថុនៃគំរោង ឬកម្មវិធី ODA លើវិស័យអប់រំ តាមរយៈKOICA មកកម្ពុជា

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ស្ថិតក្នុងបរិបទសង្គមនាពេលបច្ចុប្បន្ន ប្រទេសកម្ពុជា កំពុងតែមានការរីកចម្រើនយ៉ាងលឿនគួរឲ្យកត់សម្គាល់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ អស់រយៈពេលជិតមួយទសវត្សរ៍ចុងក្រោយនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងខិតខំកសាងសេដ្ឋកិច្ចរបស់ខ្លួន ដើម្បីប្រែក្លាយសេដ្ឋកិច្ចដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបមួយនេះ ទៅជាសេដ្ឋកិច្ចដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ធ្លាប់តែជាប្រទេសមួយ ដែលបានបែកបាក់ដោយសារតែសង្គ្រាមស៊ីវិលអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ ព្រមទាំងរងការឈ្លានពានពីសំណាក់ប្រទេសក្រៅផងនោះ ប្រទេសដ៏កំសត់មួយនេះ បាននិងកំពុងស្តារការអភិវឌ្ឍរបស់ខ្លួនលើហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍជាតិ។

ក្រោយពីទទួលបានសន្តិភាព ស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គមក្រោយឆ្នាំ ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមយ៉ាងច្រើន តែដោយហេតុថាប្រទេសកម្ពុជា ទើបតែងើបចេញពីផ្នក់សង្គ្រាម ហើយពិសេសជាងនេះទៀតគឺ ធនធានមនុស្ស ដែលជាឆ្អឹងខ្នងដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍ ត្រូវបានបាត់បង់ស្ទើរតែទាំងស្រុងនៅសម័យកម្ពុជាប្រជាធិបតេយ្យនោះ ទើបធ្វើឲ្យការរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចនិងសង្គមឡើងវិញនៅមានកម្រិតនៅឡើយ។ ហេតុដូចនេះហើយទើបរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងខិតខំដើម្បីបង្កើនកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍យ៉ាងច្រើន ជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងក្នុងស្រុកនិងអន្តរជាតិ ដើម្បីការកសាងអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកម្ពុជាឡើងវិញ។

ជាការពិតណាស់ ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ជាកត្តាចាំបាច់បំផុតក្នុងការអភិវឌ្ឍជាតិ ឲ្យមានការរីកចម្រើនប្រកបដោយចីរភាព។ ដើម្បីទទួលបាននូវធនធានមនុស្ស ដែលមានសមត្ថភាពពេញលេញ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិស័យអប់រំ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជា បានបង្កើនគម្រោងចំណាយរបស់ខ្លួនលើវិស័យមួយនេះ ច្រើនជាងវិស័យអាទិភាពផ្សេងទៀតទាំងអស់។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលកម្ពុជា បានស្វែងរកដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសអភិវឌ្ឍន៍នានាដើម្បីទទួលបានការផ្តល់ជំនួយ និងគាំទ្រយុទ្ធសាស្ត្រគោលនយោបាយអប់រំនៅកម្ពុជាបន្ថែមទៀត។ តួយ៉ាង ប្រទេសកូរ៉េ ជាប្រទេសអភិវឌ្ឍន៍មួយនៅអាស៊ីអាគ្នេយ៍ ដែលមានប្រព័ន្ធអប់រំស្តង់ដារអន្តរជាតិ រួមទាំងជាដៃគូសហការអភិវឌ្ឍន៍មួយដ៏សំខាន់សម្រាប់កម្ពុជា ហើយប្រទេសជឿនលឿនមួយនេះ បានផ្តល់ជំនួយឥតសំណងជាច្រើន

ដល់កម្ពុជា។ ចំពោះការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួមមាន មន្ទីរពេទ្យ អាគារមជ្ឈមណ្ឌលសិក្សា និងផ្លូវថ្នល់ជាច្រើន ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលកូរ៉េ បានផ្តល់ដល់ប្រទេសកម្ពុជា ការបណ្តុះបណ្តាលធនធានមនុស្ស ការពង្រឹងគុណភាពអប់រំ និងការផ្គត់ផ្គង់សម្ភារសិក្សាដល់គ្រឹះស្ថានអប់រំនៅកម្ពុជា សុទ្ធតែជាផ្នែកមួយដ៏សំខាន់ក្នុងការផ្តល់ជំនួយនេះ។

## ២. ចំណោទបញ្ហា

បច្ចុប្បន្ន ប្រទេសកម្ពុជា កំពុងតែស្ថិតក្នុងបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងកំពុងរួមគ្នាជាមួយប្រទេសក្នុងតំបន់ ឆ្ពោះទៅរកយុគសម័យឌីជីថលនាពេលខាងមុខ។ ហេតុនេះ ការប្រកួតប្រជែងទីផ្សារការងារទាំងក្នុងស្រុកនិងក្រៅស្រុក កំពុងតែមានការកើនឡើង ស្របពេលដែលកម្លាំងពលកម្មនៅប្រទេសកម្ពុជា ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅឡើយ ព្រមទាំងស្តង់ដារគុណភាពអប់រំកម្ពុជា នៅតែជាបញ្ហាប្រឈមមួយគួរឲ្យព្រួយបារម្ភនាពេលបច្ចុប្បន្ន។ បើទោះបីជា មានអន្តរាគមន៍ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើននូវការចំណាយទៅលើវិស័យមួយនេះក៏ដោយ ក៏វានៅមានកម្រិតនៅឡើយ មិនទាន់អាចឆ្លើយតបលើតម្រូវការចាំបាច់បានទាំងស្រុងនោះទេ។ មួយវិញទៀត ប្រទេសកំពុងអភិវឌ្ឍន៍នេះ ទាមទារបទពិសោធបន្ថែមទៀត លើការអភិវឌ្ឍវិស័យនេះផងនោះ ទើបរាជរដ្ឋាភិបាលកម្ពុជា ត្រូវការជំនួយបន្ថែមពីមជ្ឈដ្ឋានអន្តរជាតិ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ រដ្ឋាភិបាលកូរ៉េ បានផ្តល់ជំនួយឥតសំណងជាច្រើនលើការអភិវឌ្ឍវិស័យអប់រំ រួមនឹងការពង្រឹងសមត្ថភាពធនធានមនុស្សនៅកម្ពុជា។ កត្តាមួយចំនួន ដែលយើងខ្ញុំមានបំណងសិក្សាទៅលើ ការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ លើវិស័យអប់រំកម្ពុជាមានដូចខាងក្រោម ៖

- តើរដ្ឋាភិបាលកូរ៉េ មានគោលបំណងអ្វីខ្លះ ចំពោះការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ខ្លួនលើវិស័យអប់រំនៅកម្ពុជា ?
- តើការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិ-ការអន្តរជាតិកូរ៉េប្រចាំកម្ពុជា (KOICA) លើវិស័យអប់រំកម្ពុជា មានរូបភាពបែបណាខ្លះ ?
- តើការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ លើវិស័យអប់រំនេះ ផ្តល់សមិទ្ធផលនិងផលប្រយោជន៍ដូចម្តេចខ្លះ ដល់ប្រទេសកម្ពុជា?
- តើការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ កន្លងមកលើវិស័យអប់រំនៅកម្ពុជាមានបញ្ហាប្រឈមអ្វីខ្លះ? ហើយមានដំណោះស្រាយយ៉ាងណាខ្លះដែរ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងសិក្សាស្រាវជ្រាវប្រធានបទ "**ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ រដ្ឋាភិបាលកូរ៉េលើវិស័យអប់រំនៅកម្ពុជា តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)**" ដោយសារជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលកូរ៉េ ក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា បានក្លាយជាមុខព្រួញដ៏សំខាន់ ក្នុងការជំរុញវិស័យអប់រំក្នុងប្រទេសមួយនេះ ឲ្យមានភាពរីកចម្រើន តាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស ដែលមានសក្តានុពលខ្លាំងនៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច ក៏ដូចជាអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យកាន់តែជឿនលឿនប្រកបដោយនិរន្តរភាព។ ម្យ៉ាងវិញទៀត យើងខ្ញុំក៏មានគោលបំណងមួយចំនួនទៀតដូចខាងក្រោម ៖

- សិក្សាស្វែងយល់ពីទ្រឹស្តី ប្រភេទ និងលក្ខណៈនានា នៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ នៅប្រទេសកម្ពុជា។
- សិក្សាឲ្យឃើញពីទំនាក់ទំនង និងគោលនយោបាយ នៃការផ្តល់ជំនួយនៅកម្ពុជា។
- ស្វែងយល់ពីសកម្មភាព ការអនុវត្តជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ លើវិស័យអប់រំនៅប្រទេសកម្ពុជា។
- សិក្សាពីសមិទ្ធផលនិងការវាយតម្លៃ ការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់កូរ៉េមកកម្ពុជា។
- សិក្សាពីរបកគំហើញ ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលកើតមានក្នុងការអនុវត្តជំនួយអភិវឌ្ឍន៍ផ្លូវការនេះ។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវអត្ថបទសារណាមួយនេះ យើងខ្ញុំសូមធ្វើការសិក្សាតែទៅលើទំនាក់ទំនងជំនួយអភិវឌ្ឍន៍ផ្លូវការរបស់កូរ៉េលើវិស័យអប់រំកម្ពុជាតែប៉ុណ្ណោះ។ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ប្រចាំកម្ពុជា (KOICA) រដ្ឋាភិបាលកូរ៉េ បានផ្តល់ជំនួយឥតសំណង ហេតុនេះ យើងខ្ញុំសូមធ្វើការសិក្សាផ្តោតសំខាន់លើរូបភាព នៃការផ្តល់ជំនួយឥតសំណងទ្វេភាគីរបស់រដ្ឋាភិបាលកូរ៉េ លើវិស័យអប់រំនៅកម្ពុជា តែប៉ុណ្ណោះ។ ចំពោះទិន្នន័យនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការវិញគឺ គិតចាប់ពីឆ្នាំ ១៩៩៣ រហូតមកដល់ពេលបច្ចុប្បន្ន។

## ៥. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "**ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ រដ្ឋាភិបាលកូរ៉េលើវិស័យអប់រំនៅកម្ពុជាតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)**" មួយនេះ យើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រពិពណ៌នា ដោយប្រើប្រាស់ទិន្នន័យបន្ទាប់បន្សំ (Secondary Data)

សម្រាប់ស្រង់យកទិន្នន័យសំខាន់ៗដែលពាក់ព័ន្ធ។ ទិន្នន័យបន្ទាប់បន្សំ (Secondary Data) គឺសំដៅទៅលើប្រភេទទិន្នន័យស្រាវជ្រាវ ដែលប្រមូលបានតាមរយៈសៀវភៅ ឯកសារផ្សេងៗជាច្រើន។ ដើម្បីសម្រេចបានការសិក្សាស្រាវជ្រាវមួយនេះ យើងខ្ញុំបានប្រមូលទិន្នន័យបន្ទាប់បន្សំ (Secondary Data) ដូចជា ៖

- ប្រមូលឯកសារនានា ពាក់ព័ន្ធនឹងប្រធានបទពីបណ្ណាល័យនៅក្នុង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ទទួលបានឯកសារស្រាវជ្រាវមួយចំនួនពាក់ព័ន្ធនឹងប្រធានបទពី ក្រសួងអប់រំ យុវជន និងកីឡា។
- ការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត តាមរយៈគេហទំព័ររបស់ MoEYS, CDC, KOICA, OECD, ODA KOREA និងគេហទំព័រពាក់ព័ន្ធផ្សេងទៀត។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណា ស្តីពីប្រធានបទ "**ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ រដ្ឋាភិបាល កូរ៉េលើវិស័យអប់រំនៅកម្ពុជាតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)**" ក្នុងទិសដៅវាយតម្លៃសកម្មភាពផ្តល់ជំនួយ និងការរួមចំណែកអភិវឌ្ឍន៍ជំនួយរបស់ប្រទេសកូរ៉េ នៅកម្ពុជា។ ទន្ទឹមនឹងនេះ ការសិក្សាសារណាមួយនេះផ្តល់នូវចំណេះដឹង និងផលប្រយោជន៍ដូចជា៖

- យល់ដឹងពីសកម្មភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍គម្រោង និងកម្មវិធីអភិវឌ្ឍន៍នានារបស់ប្រទេសកូរ៉េ ចំពោះប្រទេសកម្ពុជាលើវិស័យអប់រំ។
- យល់ដឹងឲ្យកាន់តែច្បាស់ពីសកម្មភាពប្រើប្រាស់ និងស្ថាប័នដែលអនុវត្តជំនួយអភិវឌ្ឍន៍ជាផ្លូវការរបស់កូរ៉េនៅកម្ពុជា។
- ស្វែងរកដំណោះស្រាយសមស្រប ចំពោះបញ្ហាប្រឈមដែលធ្លាប់បានកើតមានកន្លងមកក្នុងការអនុវត្តជំនួយអភិវឌ្ឍន៍ផ្លូវការរបស់កូរ៉េនៅកម្ពុជា។
- ជាឯកសារដែលអាចយកទៅប្រើប្រាស់សម្រាប់ការសិក្សា និងយកទៅបង្រៀនបន្តបាន។
- សម្រាប់សិស្សានុសិស្សជំនាន់ក្រោយទុកជាបទពិសោធ និងជាគម្រូ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទ "**ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ រដ្ឋាភិបាលកូរ៉េលើវិស័យអប់រំ នៅកម្ពុជាតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)**" ត្រូវបានបែងចែកជាប្រាំផ្នែកសំខាន់ៗដែលមានចែងដោយសង្ខេបខ្លឹមសារដូចខាងក្រោម៖

## សេចក្តីផ្តើម

សេចក្តីផ្តើម ជាចំណុចចាប់ផ្តើមនៃប្រធានបទ ដែលនឹងធ្វើការសិក្សាទៅលើផ្នែកដូចជា ស្ថានភាពទូទៅ មូលហេតុ និងគោលបំណងនៃការសិក្សា ទំហំនិងដែនកំណត់ វិធីសាស្ត្រស្រាវជ្រាវ មូលហេតុនាំឲ្យមានការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ មកលើវិស័យអប់រំនៅកម្ពុជា និងសិក្សាពីបញ្ហាប្រឈម ដើម្បីឈានទៅរកដំណោះស្រាយដ៏សមស្រប។

## ជំពូកទី ១ ៖ រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងជំនួយអភិវឌ្ឍន៍ផ្លូវការ និងការអប់រំ

នៅក្នុងផ្នែកនេះផងដែរ យើងខ្ញុំនឹងលើកយកនិយមន័យដែលពាក់ព័ន្ធនឹងប្រធានបទ ក៏ដូចជា ទ្រឹស្តីរបស់ក្រុមសេដ្ឋវិទូនិងអ្នកស្រាវជ្រាវមួយចំនួន មកធ្វើការសិក្សា គោលបំណងបង្ហាញពីការផ្តល់ជំនួយអភិវឌ្ឍន៍លើវិស័យអប់រំ បានជំរុញឲ្យមានកំណើនសេដ្ឋកិច្ចរបស់ជាតិ ប្រកបដោយចេរភាព។ មួយវិញទៀត ក៏មានការសិក្សាពី ប្រភេទ ផលប្រយោជន៍ និងមូលហេតុដែលនៅពីក្រោយការផ្តល់និងទទួលជំនួយដែរ។ មិនតែប៉ុណ្ណោះ យើងខ្ញុំធ្វើការសិក្សាពី គោលនយោបាយផែនការយុទ្ធសាស្ត្រ បញ្ហាប្រឈមនិងដំណោះស្រាយ បាននិងកំពុងកើតមាននៅលើវិស័យអប់រំកម្ពុជា នីតិវិធីផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ បទពិសោធ និងទំនាក់ទំនងរវាងកម្ពុជា-កូរ៉េ។

## ជំពូកទី ២ ៖ ស្ថានភាពទូទៅនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការតាមរយៈ KOICA លើវិស័យអប់រំកម្ពុជា

ក្នុងជំពូកនេះ យើងខ្ញុំនឹងសិក្សាពីស្ថានភាពទូទៅរបស់ KOICA យុទ្ធសាស្ត្រ និងនីតិវិធីនៃការស្នើជំនួយលើគម្រោងនិងការអនុម័តគម្រោងពី KOICA ព្រមទាំងបង្ហាញពីការរួមចំណែកនៃជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ លើវិស័យអប់រំនៅកម្ពុជា។

## ជំពូកទី ៣ ៖ ការសិក្សាលើលទ្ធផលស្រាវជ្រាវ

ចំពោះជំពូកនេះវិញ យើងខ្ញុំនឹងធ្វើការសិក្សាពីសមិទ្ធផល និងផលប្រយោជន៍ដែលបានមកពីការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការនេះ លើកម្ពុជា។ ម៉្យាងទៀត យើងខ្ញុំបកស្រាយពីរូបភាពសំខាន់ដែលជាបញ្ហាលើការអនុវត្តជំនួយអភិវឌ្ឍន៍នេះ ស្របពេលដែលនឹងត្រូវបង្ហាញពីដំណោះស្រាយដែលសមស្របរបស់ភាគីពាក់ព័ន្ធ ក្នុងការដោះស្រាយបញ្ហាប្រឈមនាពេលកន្លងមក។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ចំណែកឯផ្នែកចុងក្រោយបង្អស់នេះវិញ យើងខ្ញុំនឹងធ្វើការសន្និដ្ឋាន និងធ្វើការសង្ខេបលើប្រធានបទឡើងវិញ ហើយមិនត្រឹមតែប៉ុណ្ណោះ យើងខ្ញុំនឹងផ្តល់ជាអនុសាសន៍មួយចំនួន ដល់ប្រធានបទថែមទៀតផងដែរ។

# ជំពូកទី១
# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងជំនួយ
# អភិវឌ្ឍន៍ផ្លូវការ និង ការអប់រំ

# ជំពូកទី ១ រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងជំនួយអភិវឌ្ឍន៍ផ្លូវការ និងការអប់រំ

## ១.១. និយមន័យ

### ១.១.១. ជំនួយអភិវឌ្ឍន៍ផ្លូវការ

**ជំនួយអភិវឌ្ឍន៍ផ្លូវការ** (ODA) មានន័យថាជា ជំនួយរដ្ឋាភិបាលដែលបង្កើតឡើងដើម្បីជំរុញកំណើន និងសុខុមាលភាពសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ផ្តល់នូវជំនួយឥតសំណង កម្ចី និងជំនួយបច្ចេកទេសទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ឬអង្គការអន្តរជាតិផងដែរ។[1]

ចំណែកគណៈកម្មាធិការផ្តល់ជំនួយដើម្បីកិច្ចអភិវឌ្ឍន៍ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច (OECD DAC) បានឲ្យនិយមន័យ ODA ថាជាលំហូរធនធានទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈទីភ្នាក់ងារផ្លូវការ និងរដ្ឋាភិបាលកណ្តាលនិងតំបន់ ឬភ្នាក់ងារប្រតិបត្តិការរបស់ពួកគេ ហើយវាត្រូវបានគ្រប់គ្រង ដោយផ្សារភ្ជាប់នឹងកម្មវត្ថុមួយដ៏សំខាន់គឺ ការជំរុញកំណើននិងសុខុមាលភាពសេដ្ឋកិច្ច (ក្នុងន័យនេះ ជំនួយសម្រាប់គោលដៅយោធា និងការធ្វើពាណិជ្ជកម្មក៏ត្រូវបានរាប់បញ្ចូលដែរ) និងត្រូវបានផ្តល់ ODA ដល់ប្រទេសដែលមានឈ្មោះក្នុងបញ្ជី DAC និងដល់ស្ថាប័នពហុភាគី ដូចដែលបានបែងចែកដោយ OECD DAC ដោយមានគុណវុឌ្ឍិជាអង្គការអន្តរជាតិ រួមទាំងមានឥណទាន និងសម្បទានយ៉ាងហោច ២៥% នៃ ODA។

បើយោងតាមរបាយការណ៍ទីពីរស្តីពី ស្ថានភាពគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា បានកំណត់និយមន័យ ODA ថាជាប្រាក់ផ្តល់ឲ្យបណ្តាប្រទេស និងដែនដីដែលមានក្នុងផ្នែកទី១ នៃបញ្ជីរបស់គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ស្តីពីអ្នកទទួលជំនួយ(បណ្តាប្រទេសកំពុងអភិវឌ្ឍន៍) ដែល៖ (ក) ប្រកាន់យកវិស័យផ្លូវការ (ខ) លើកតម្កើនការអភិវឌ្ឍសេដ្ឋកិច្ច និងសុខុមាលភាពជាគោលបំណងសំខាន់ (គ) យល់ព្រមលើលក្ខខណ្ឌសម្បទានហិរញ្ញវត្ថុ (បើកម្ចីមានលក្ខណៈជាប្រាក់សម្បទានយ៉ាងតិចបំផុត ២៥%)។

### ១.១.២. ការអប់រំ

**ការអប់រំ** សំដៅកិច្ចដំណើរការអភិវឌ្ឍការសិក្សា ការបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញា និងសីលធម៌ តាមរយៈការគ្រប់សកម្មភាពអប់រំ ដែលធ្វើឲ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឲ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។[2]

[1] https://www.odakorea.go.kr/eng.overview.What.do (ចូលទស្សនាថ្ងៃទី ២៨ មីនា ២០១៩)

[2] ដកស្រង់ចេញពីច្បាប់ស្តីពីការអប់រំ (រដ្ឋសភាអនុម័ត ១៩ តុលា ២០០៧) ជំពូកទី១ មាត្រា៤

តាមនិយមន័យខាងលើ យើងខ្ញុំអាចកំណត់ន័យរបស់ប្រធានបទ "**ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់រាជរដ្ឋាភិបាលកូរ៉េលើវិស័យអប់រំនៅកម្ពុជា តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)**" នេះបានថា ជាការផ្តល់នូវធនធានជា ហិរញ្ញវត្ថុ ឬមិនមែនជាហិរញ្ញវត្ថុ ដូចជា សម្ភារ ឬបច្ចេកទេស ទៅលើដំណើរការអភិវឌ្ឍឬ ការបណ្តុះបណ្តាលធនធានមនុស្សនៅប្រទេសកម្ពុជា ដើម្បីជួយបង្កើនសមត្ថភាពរបស់ពួកគេ ដែលអាចនាំឲ្យប្រទេសខ្លួនឈានទៅរកកំណើន និង អភិវឌ្ឍន៍ជានិរន្តរ៍។

ការអប់រំ នៅប្រទេសកម្ពុជាត្រូវបានធ្វើឡើងតាមរយៈរូបភាពជា ការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និង ការអប់រំមិនផ្លូវការ។[3]

**ការអប់រំក្នុងប្រព័ន្ធ** សំដៅដល់ដំណើរការសិក្សាដែលមានលក្ខណៈជាប្រព័ន្ធ និង ហ្មត់ចត់ មានរចនាសម្ព័ន្ធរៀបរយ និងតាមលំដាប់ថ្នាក់ ដែលផ្តល់ឲ្យដោយគ្រឹះស្ថានសិក្សាមានអាជ្ញាប័ណ្ណអប់រំត្រឹមត្រូវ ឬដែលមានការទទួលស្គាល់គុណភាពអប់រំស្របទៅតាមលក្ខខណ្ឌផ្នែកច្បាប់ និង នីតិវិធីដែលមានចែងក្នុងច្បាប់នេះ។

**ការអប់រំក្រៅប្រព័ន្ធ** សំដៅដល់សកម្មភាពអប់រំ ដែលមានការរៀបចំមានលក្ខណៈជាប្រព័ន្ធធ្វើឡើងក្រៅក្របខ័ណ្ឌនៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ដើម្បីផ្តល់ការសិក្សាដែលបានជ្រើសរើស។ ការអប់រំនេះគ្របដណ្តប់លើកម្មវិធីអប់រំជាច្រើន ដូចជា អក្ខរកម្ម បំណិនជីវិត បំណិនការងារ ការអប់រំមូលដ្ឋាន សម្រាប់អ្នកសិក្សាដែលមិនចូលសិក្សានៅគ្រឹះស្ថានសិក្សាក្នុងប្រព័ន្ធ មានលក្ខណៈជាការសិក្សាបន្ត និងការសិក្សាកម្រិតសមមូលសម្រាប់ការបញ្ចូលទៅក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬជាការអប់រំអស់មួយជីវិត។

**ការអប់រំមិនផ្លូវការ** សំដៅដល់ដំណើរការស្វ័យសិក្សា ឬការសិក្សាដោយខ្លួនឯង និងជាដំណើរការសិក្សាអស់មួយជីវិត តាមការចាប់អារម្មណ៍ សក្តានុពល និងការត្រៀមខ្លួនជាស្រេច ដើម្បីចាប់យកឱកាសដែលមាន ហើយដែលអ្នកសិក្សាទទួល និងបង្កើនផ្គុំចំណេះដឹង ជំនាញ ឥរិយាបថ និងគំនិតបានមកពីបទពិសោធប្រចាំថ្ងៃពីការងារ ការសំដែង និងពីជីវិតផ្ទាល់ ព្រមទាំងជាការសិក្សាតាមរយៈមនុស្ស សង្គម មជ្ឈដ្ឋានជុំវិញប្រព័ន្ធសារព័ត៌មាន និងប្រភពចំណេះដឹង ឬប្រភពព័ត៌មានផ្សេងទៀតនៅពេលណា និង នៅទីកន្លែងណាផ្សេងទៀតក៏ដោយក្រៅពីកម្មវិធីអប់រំក្នុងប្រព័ន្ធ និងកម្មវិធីអប់រំក្រៅប្រព័ន្ធ។

[3] ដកស្រង់ចេញពីច្បាប់ស្តីពីការអប់រំ (រដ្ឋសភាអនុម័ត ១៩ តុលា ២០០៧) ឧបសម្ព័ន្ធ ទំព័រទី១និងទី២

## ១.២. ទ្រឹស្តី និងការសិក្សាអំពី កំណើន និងជំនួយលើវិស័យអប់រំ

### ១.២.១. ទ្រឹស្តីពួកនេអូក្លាសិក (Neoclassical Theory)

យោងតាមគំរូកំណើន Solow របស់ពួកនេអូក្លាសិកបានលើកឡើងថា ជំនួយបរទេសអាចជំរុញឲ្យមានកំណើន តាមរយៈការផ្តល់ឲ្យប្រទេសដែលត្រូវការជំនួយហិរញ្ញវត្ថុនោះ ដើម្បីបង្កើនឱកាសវិនិយោគ និងអាចឲ្យរដ្ឋាភិបាលនៃប្រទេសនោះ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម។ ទន្ទឹមនឹងនេះដែរ ទ្រឹស្តីនេះក៏បានចែងថា ការអប់រំអាចបង្កើនធនធានមនុស្ស ហើយអាចរួមចំណែកយ៉ាងសំខាន់លើកម្លាំងពលកម្ម ដើម្បីជំរុញផលិតភាពពលកម្មនិងនាំឲ្យមានកំណើន។ ម្យ៉ាងទៀត ទ្រឹស្តីនេះបានបញ្ជាក់ថា សេដ្ឋវិទូអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចរយៈពេលវែងតាមរយៈការធ្វើឲ្យរីកចម្រើននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលផ្តោតទៅលើអាជីពរបស់ពលករទាំងឡាយណា ដែលមិនស្ថិតនៅក្រោមច្បាប់ការងារ ឬស្ថិតនៅក្រោមច្បាប់ស្តីអំពីការងារដែរ ប៉ុន្តែមិនបានគ្របដណ្តប់ឲ្យទូលំទូលាយ ដោយអាជីវកម្មនោះមានសមាជិកតិចតួចពេក។

### ១.២.២. ទ្រឹស្តីពួកអែនឌូស្សែនីស (Endogenous Theory)

នៅក្នុងទំនាក់ទំនងរវាង ជំនួយលើការអប់រំ និងកំណើន យើងកត់សម្គាល់ឃើញថា ទ្រឹស្តីកំណើនអែនឌូស្សែនីស បានបំពេញបន្ថែមនូវចន្លោះខ្វះខាតរបស់ទ្រឹស្តីកំណើន Solow ដោយបានបង្ហាញឲ្យឃើញពីទំនាក់ទំនងវិជ្ជមានរវាងការអប់រំ និងកំណើន។ លើសពីនេះទៅទៀត ការសិក្សាលើភាពជាក់ស្តែងមួយចំនួនបានរកឃើញថា ការរួមចំណែករបស់មូលធនមនុស្ស និងការវិនិយោគលើវិស័យអប់រំ សុទ្ធតែមានទំនាក់ទំនងវិជ្ជមានជាមួយនឹងកំណើន។ ការផ្តល់ជំនួយលើវិស័យអប់រំ អាចផ្តល់នូវធនធាន ក៏ដូចជាហិរញ្ញវត្ថុ ដែលអភិវឌ្ឍន៍ការអប់រំដូចជា កសាងសាលារៀន ជួល និងបណ្តុះបណ្តាលគ្រូបង្រៀន ផ្គត់ផ្គង់សៀវភៅ និងសម្ភារសិក្សាបន្ថែមទៀតដល់សិស្សានុសិស្សផងដែរ។ ហេតុដូចនេះហើយ វានឹងធ្វើឲ្យគុណភាពនៃការអប់រំកាន់តែប្រសើរឡើង និងអត្រាអក្ខរកម្មកាន់តែកើនឡើងថែមមួយកម្រិតទៀតនៅក្នុងប្រទេសដែលទទួលជំនួយនេះ។ តាមរយៈទ្រឹស្តីនេះ យើងអាចមើលឃើញថា ជំនួយផ្នែកអប់រំ មានឥទ្ធិពលវិជ្ជមានលើកំណើនសេដ្ឋកិច្ចរបស់ប្រទេសដែលទទួលជំនួយ ដោយមានការសម្របសម្រួល និងប្រមូលផ្តុំមូលធនក្នុងប្រទេសនេះកាន់តែច្រើន។ គួរបញ្ជាក់ផងដែរថា ក្នុងទ្រឹស្តីកំណើនសេដ្ឋកិច្ចគឺមានហេតុផល ៣ ដែលបង្ហាញពីឥទ្ធិពលនៃការអប់រំជំរុញឲ្យមានកំណើន៖

១) ការអប់រំ អាចបង្កើនចំណេះដឹងបន្ថែមលើសមត្ថភាពយល់ដឹង បង្កើនផលិតភាព ដើម្បីបង្កើនទិន្នផលរហូតដល់ចំណុចលំនឹង។

២) ការអប់រំ អាចបង្កើនសមត្ថភាពក្នុងការច្នៃប្រឌិត ដែលមានទំនាក់ទំនងនឹងការបង្កើតទំនិញនិងសេវាកម្ម។

៣) ការអប់រំអាចធ្វើឲ្យមនុស្ស឴ឆាប់ចាប់យកចំណេះដឹងពីប្រភពខាងក្រៅបានយ៉ាងងាយស្រួល និងផ្ទេរចំណេះដឹងទៅឲ្យអ្នកដទៃតាមរយៈ ព័ត៌មាន បច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗ ដើម្បីយកមកអនុវត្តន៍ ដែលនាំឲ្យសម្រេចបានគោលដៅរបស់ខ្លួន។

### ១.២.៣. ការសិក្សាស្រាវជ្រាវរបស់លោក Dreher et al

ការផ្តល់ជំនួយលើការអប់រំមានច្រើនរូបភាព ដូចជា កម្មវិធីផ្តល់អាហារតាមសាលារៀន ការសាងសង់ថ្នាក់រៀន ការបណ្តុះបណ្តាលគ្រូបង្រៀន ផ្តល់អាហារូបករណ៍ដល់កុមារី កម្មវិធីដើម្បីកាត់បន្ថយការបោះបង់ការសិក្សា កម្មវិធីអភិវឌ្ឍកម្មវិធីសិក្សា ដែលមានគោលដៅផ្តោតលើកម្រិតអប់រំខុសៗគ្នា និងការប្រើប្រាស់វិធីជំនួយផ្សេងៗ។ បើនិយាយពីការរួមចំណែករបស់ជំនួយទៅលើការអប់រំ វាពិតជាបានបង្កើននូវអត្រានៃការចូលរៀនរបស់កុមារ ដោយយោងតាមការសិក្សាស្រាវជ្រាវរបស់លោក Dreher et al (អ្នកនិពន្ធ) ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានសេដ្ឋកិច្ចស្វ៊ីស ហើយជាអ្នកស្រាវជ្រាវនៅ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច និងនៅមជ្ឈមណ្ឌលសិក្សាសេដ្ឋកិច្ច ក្នុងសាកលវិទ្យាល័យ Munich។ ជាក់ស្តែង ការសិក្សានេះលោកបានធ្វើការវិភាគលើប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៩៦ប្រទេស ដោយគិតចាប់ពីឆ្នាំ ១៩៧០ ដល់ ២០០៤ ដែលជាលទ្ធផល លោកបានរកឃើញថា កាលណាបង្កើនជំនួយជាមធ្យម ១ភាគរយ នៃផលិតផលក្នុងស្រុកសរុប នាំឲ្យការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា កើនឡើងពី ២,៥ទៅ ៥ ភាគរយ។[4]

## ១.៣. សញ្ញាណទូទៅនៃជំនួយអភិវឌ្ឍន៍ផ្លូវការ

### ១.៣.១. ប្រវត្តិនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ[5]

ODA ត្រូវបានផ្តួចផ្តើមឡើងក្រោយសង្គ្រាមលោកលើកទី២ ពេលប្រទេសឧស្សាហកម្មជឿនលឿនជាច្រើន បានចាប់ផ្តើមផ្តល់ជំនួយដល់អតីតប្រទេសក្រោមអាណានិគមរបស់ខ្លួន ដើម្បីកាត់បន្ថយភាពក្រីក្រ តាមរយៈការអនុវត្តស្មារតីសហប្រតិបត្តិការសមាគមរួមសកល។

នៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៤៥ បានចែងថា វាជាការសំខាន់ណាស់ ដើម្បីសម្រេចបាននូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការដោះស្រាយបញ្ហាអន្តរជាតិក្នុងបរិបទ

[4] Dreher, A., Nunnenkamp, P., Thiele, R., 2008. Does Aid for Education Educate Children? Evidence from Panel Data. World Bank Economic Review. 22(2), 291–314.

[5] https://www.odakorea.go.kr/eng.overview.History02.do (ចូលទស្សនាថ្ងៃទី ៣០ មីនា ២០១៩)

សេដ្ឋកិច្ច សង្គម វប្បធម៌ ឬមនុស្សធម៌។ នៅទសវត្សរ៍ឆ្នាំ ១៩៥០ អង្គការអន្តរជាតិជាច្រើនក៏បានចាប់ផ្តើមផ្តល់ជំនួយសង្គ្រោះបន្ទាន់ ដល់បណ្តាប្រទេសទើបទទួលបានឯករាជ្យ ដែលរូបភាពនេះបានក្លាយជាមូលដ្ឋានសម្រាប់ការផ្តល់ជំនួយពហុភាគី។ ម្យ៉ាងទៀត ជំនួយទ្វេភាគីបានចាប់ផ្តើមរីកចម្រើនផងដែរ នៅពេលដែលសហរដ្ឋអាមេរិក និងសហភាពសូវៀត បានគាំទ្រដល់ការស្តារឡើងវិញក្រោយសង្គ្រាមនៅអឺរ៉ុបខាងលិច ក្នុងអំឡុងពេលសង្គ្រាមត្រជាក់។

នាសម័យប្រជុំលើកទី១៦ នៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៦១ អង្គការសហប្រជាជាតិបានកំណត់ទសវត្សរ៍ឆ្នាំ ១៩៦០ ជា **ទសវត្សរ៍អភិវឌ្ឍន៍សហប្រជាជាតិ**។ តាមរយៈសេចក្តីប្រកាសនេះ អ.ស.ប. បានលើកទឹកចិត្តឲ្យប្រទេសជាសមាជិកឧស្សាហកម្មជឿនលឿនផ្តល់ ១% នៃ GNP របស់ខ្លួន ជាការផ្តល់ជំនួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងភាពបន្ទាប់ចាំបាច់សម្រាប់សមាគមសកលលោក ដើម្បីធ្វើសកម្មភាពរួមគ្នា គោលបំណងជួយដោះស្រាយបញ្ហាភាពក្រីក្ររបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ គួររំលឹកឡើងវិញដែរថា លំហូរមូលធនមានរូបភាពច្រើនដូចជា ជំនួយឥតសំណង កម្ចី ឥណទាន ការនាំចេញ ការវិនិយោគឯកជន ជាដើម។ តាមរយៈរូបភាពបែបនេះ សមាជិកគណៈកម្មាធិការផ្តល់ជំនួយដើម្បីកិច្ចអភិវឌ្ឍន៍ (DAC) បានទាមទារឲ្យមានវិធានការដាក់លាក់បន្ថែមទៀតចំពោះ លំហូរហិរញ្ញប្បទាន ជាពិសេសចំពោះសមាជិកដែលមានចំណែកហិរញ្ញប្បទានច្រើនជាងគេក្នុងលំហូរនេះ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ នៅឆ្នាំ ១៩៦៩ DAC បានបង្កើតក្រុមអាដហុកផ្នែកបញ្ហាស្ថិតិ ក្នុងគោលបំណងឈានទៅរកការកំណត់និយមន័យ និងអត្តសញ្ញាណនៃជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)។ ហេតុនេះ ពាក្យថាជំនួយអភិវឌ្ឍន៍ផ្លូវការ ត្រូវបានប្រើប្រាស់ជាលើកដំបូងនៅចុងទសវត្សរ៍ឆ្នាំ ១៩៦០ ដោយ DAC។

អង្គការសហប្រជាជាតិបានប្រកាសថាទសវត្សរ៍ឆ្នាំ ១៩៧០ ជា **ទសវត្សរ៍ទី ២ នៃការអភិវឌ្ឍសហប្រជាជាតិ** បន្ទាប់ពីទសវត្សឆ្នាំ ១៩៦០ ហើយវាបានជំរុញឲ្យប្រទេសដែលជាម្ចាស់ជំនួយបង្កើន ODA របស់ខ្លួនឲ្យដល់ ០.៧%នៃ GNI ប្រចាំប្រទេសនីមួយៗនៅពាក់កណ្តាលទសវត្សរ៍នេះ ដើម្បីសម្រេចបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ៦% នៃប្រទេសកំពុងអភិវឌ្ឍន៍។ បើទោះបីជាសេចក្តីប្រកាសនេះបានចេញតាំងពីទសវត្សរ៍ឆ្នាំ ១៩៧០ ក៏ដោយ មកទល់នឹងពេលបច្ចុប្បន្ននេះ បណ្តាប្រទេសដែលជាសមាជិក DAC ភាគច្រើនគឺមិនទាន់អាចសម្រេចបានគោលដៅនេះនៅឡើយ រួមទាំងសាធារណៈរដ្ឋកូរ៉េផងនោះ នេះបើយោងតាមទិន្នន័យដែលបានបង្ហាញដោយ OECD ដូចនៅក្នុងក្រាហ្វិកទី១.១។ ផ្ទុយទៅវិញ គេសង្កេតឃើញថាប្រទេសដែលជាសមាជិកទាំងនោះ បានខិតខំនៅក្នុងការសម្រេចឲ្យបានគោលដៅមួយនេះយ៉ាងខ្លាំង គួយ៉ាងនៅខែ កញ្ញា

ឆ្នាំ២០០០ ប្រមុខរដ្ឋចំនួន ១៨៩ បានអនុម័ត **សេចក្តីថ្លែងការណ៍សហស្សវត្សរ៍របស់អ.ស.ប.** ក្នុងមហាសន្និបាត អ.ស.ប. លើកទី៥៥ ហើយបានប្រកាសអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ គោលដៅនេះត្រូវបានគាំទ្រដោយ សមាគមពិភពលោកដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្ររួមគ្នា ហើយវាមានសារៈសំខាន់ណាស់ក្នុងការប្រមូលផ្តុំមតិជាឯកឆន្ទទូទាំងពិភពលោក ដោយមានអ្នកចូលរួមជាសកល។ នៅក្រោមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នេះ សមាគមសកលលោកបានចាប់ផ្តើមពិភាក្សា លើការពង្រីកការផ្តល់ជំនួយហិរញ្ញប្បទាន ក្នុងកិច្ចអភិវឌ្ឍន៍ និងជាយុទ្ធសាស្ត្រអនុវត្តប្រកបដោយប្រសិទ្ធភាព។

ក្រាហ្វិកទី១.១៖ ចំនួនទឹកប្រាក់ជំនួយអភិវឌ្ឍន៍ផ្លូវការឥតសំណងសមមូលជាភាគរយ នៃ GNI របស់ប្រទេសដែលជាសមាជិក OECD DAC ក្នុងឆ្នាំ ២០០៨




*(ប្រភព ៖ https://www2.compareyourcountry.org/oda?cr=oecd&lg=en)*

### ១.៣.២. ប្រតិបត្តិការរបស់គណៈកម្មាធិការផ្តល់ជំនួយដើម្បីកិច្ចអភិវឌ្ឍន៍

គណៈកម្មាធិការផ្តល់ជំនួយដើម្បីកិច្ចអភិវឌ្ឍន៍ (DAC) មុនដំបូងមានឈ្មោះថាក្រុមផ្តល់ជំនួយដើម្បីកិច្ចអភិវឌ្ឍន៍ (DAG) ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៦០ ហើយការងារចម្បងដែលបង្កើតគណៈកម្មាធិការនេះឡើង ដើម្បីអនុវត្តន៍នូវភារកិច្ចមួយចំនួនដូចជា៖

- ចងក្រង និងគ្រប់គ្រងរបាយការណ៍មួយដែលត្រឹមត្រូវស្តីពី លំហូរនៃជំនួយរបស់រដ្ឋ ដែលជាសមាជិកនៃ OECD ទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍។
- ចូលរួមចំណែក ក្នុងការកសាងសមត្ថភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចពិភពលោក ឲ្យមានភាពប្រសើរជាងមុន។

- ចូលរួមចំណែក ក្នុងការកសាងសមត្ថភាពរបស់ប្រជាជន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីឲ្យពួកគេចាកចេញពីភាពក្រីក្រ និងអាចចូលរួមសកម្មភាពពេញលេញក្នុងសង្គម។
- បង្កើតជាកិច្ចប្រជុំជាន់ខ្ពស់ប្រចាំឆ្នាំ ដោយមានការចូលរួមពីថ្នាក់រដ្ឋមន្ត្រី ឬមេដឹកនាំនៃរដ្ឋដែលជាសមាជិកនៃ OECD ដើម្បីពិភាក្សាលើកិច្ចការងារ ដែលពាក់ព័ន្ធទៅនឹងការផ្តល់ជំនួយអន្តរជាតិដើម្បីកិច្ចអភិវឌ្ឍន៍ ក៏ដូចជាផ្តល់អនុសាសន៍និងដំណោះស្រាយ លើបញ្ហានានាដែលជួបប្រទះកន្លងមក។ ក្រៅពីរដ្ឋដែលជាសមាជិកនៃ OECD កិច្ចប្រជុំនោះក៏មានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់នៃ ធនាគារពិភពលោក មូលនិធិរូបិយវត្ថុរបស់អន្តរជាតិ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិផងដែរ។

### ១.៣.៣. ប្រភេទនៃជំនួយអភិវឌ្ឍន៍[6]

បើយោងតាម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា CDC បានបែងចែកជំនួយអភិវឌ្ឍន៍ជា ៦ប្រភេទ ដូចតទៅ៖

#### ១.៣.៣.១. កិច្ចសហប្រតិបត្តិការបច្ចេកទេស

ជាការផ្តល់ប្រភពធនធាន ដែលមានគោលដៅផ្ទេរនូវបច្ចេកទេស ជំនាញខាងការគ្រប់គ្រង និងចំណេះដឹង សំដៅការកសាងសមត្ថភាពជាតិ ក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ ដោយមិនផ្តោតទៅលើការអនុវត្តគម្រោងវិនិយោគជាក់លាក់ណាមួយឡើយ។ កិច្ចសហប្រតិបត្តិការនេះ រួមបញ្ចូលទាំងបណ្តាសកម្មភាពមុនពេលវិនិយោគដូចជា ការសិក្សាពីលទ្ធភាពទាំងឡាយ ដែលត្រូវធ្វើមុនពេលអនុវត្តន៍គម្រោងនិយោគ ឬមុនពេលធានាហិរញ្ញប្បទាន។

#### ១.៣.៣.២. កិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ការវិនិយោគ

គឺការផ្តល់ប្រភពធនធាន សំដៅពង្រឹងសមត្ថភាពដើម្បីអនុវត្តន៍គម្រោងវិនិយោគជាក់លាក់ណាមួយ។ កិច្ចសហប្រតិបត្តិការសម្រាប់ការវិនិយោគ ក៏រួមបញ្ចូលនូវបណ្តាសកម្មភាព ដែលត្រូវអនុវត្តន៍ចាប់ផ្តើមគម្រោងវិនិយោគ។

#### ១.៣.៣.៣. ជំនួយគម្រោងវិនិយោគ

គឺជាការផ្តល់ធនធានជាសាច់ប្រាក់ឬទំនិញ សម្រាប់គម្រោងវិនិយោគជាមូលធនជាក់លាក់ដែលបង្កើតផលិតផលនិងសេវាកម្មថ្មីៗ។ ជំនួយគម្រោងវិនិយោគនេះ ក៏អាចរួមបញ្ចូលទាំងផ្នែកសហប្រតិបត្តិការបច្ចេកទេសផងដែរ។

[6] ឯកសាររបាយការណ៍ស្តីពី *កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ ២០០៤-២០០៥* ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០០៦ ទំព័រ ៤៦

#### ១.៣.៣.៤. ជំនួយទ្រទ្រង់ថវិកា ឬតុល្យការជញ្ជីងទូទាត់

គឺជាការផ្តល់ហិរញ្ញប្បទានមួយ ដែលនៅក្នុងបរិបទនៃកម្មវិធីអភិវឌ្ឍន៍ វាមានលក្ខណៈយ៉ាងទូលំទូលាយជាងគម្រោងវិនិយោគ ឬកិច្ចសហប្រតិបត្តិការបច្ចេកទេស ហើយកម្មវិធីមួយនេះ មានគោលដៅធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនិង/ឬជាការផ្តល់ជំនួយសម្រាប់ទ្រទ្រង់ថវិកា និងតុល្យភាពជញ្ជីងទូទាត់ ព្រមទាំងធានាស្ថេរភាពនៃអត្រាប្តូរប្រាក់។ ជំនួយប្រភេទនេះ អាចជាទំនិញ តែមិនមែនជាអាហារ ជាជំនួយឥតសំណង ឬកម្ចីសម្រាប់ទូទាត់ទំនិញ។ ប្រភពធនធានដែលបានមកពីការលើកលែងបំណុលសាធារណៈ ក៏ចាត់ចូលក្នុងប្រភេទជំនួយនេះដែរ។

#### ១.៣.៣.៥. ជំនួយជាស្បៀងអាហារ

គឺជាការផ្តល់ជំនួយជាម្ហូបអាហារ សម្រាប់បំពេញតម្រូវការប្រើប្រាស់របស់ប្រជាជន សំដៅដល់ការអភិវឌ្ឍប្រទេស។ ជំនួយនេះមានជាជំនួយឥតសំណង និងមានជាកម្ចីសម្រាប់ទិញស្បៀងអាហារ។ ចំណាយរួមផ្សំដូចជា ការដឹកជញ្ជូន ថ្លៃឃ្លាំងស្តុក និងការចែកចាយក៏រាប់បញ្ចូលក្នុងជំនួយប្រភេទនេះដែរ។ រួមទាំងការឧបត្ថម្ភដែលមានដូចជា ចំណីសត្វ និងឧបករណ៍កសិកម្មសម្រាប់ការផលិតស្បៀង ក៏ត្រូវរាប់បញ្ចូលក្នុងជំនួយប្រភេទនេះដែរ ដោយមានទំនាក់ទំនងនឹងកម្មវិធីស្បៀងអាហារ។

#### ១.៣.៣.៦. ជំនួយមនុស្សធម៌ និងសង្គ្រោះបន្ទាន់

គឺជាការផ្តល់ជំនួយដើម្បីសម្រួលការលំបាក និងការកែលម្អសុខភាពរបស់ប្រជាជនដែលទទួលរងគ្រោះពីគ្រោះថ្នាក់ធម្មជាតិ ឬគ្រោះមហន្តរាយនានាដែលបង្កឡើងដោយមនុស្ស។ ជំនួយជាស្បៀងអាហារសម្រាប់មនុស្សធម៌ និងសង្គ្រោះបន្ទាន់ក៏ត្រូវបានរាប់បញ្ចូលក្នុងជំនួយប្រភេទនេះដែរ។ ជាទូទៅ ជំនួយសង្គ្រោះបន្ទាន់ និងជំនួយមនុស្ស មិនពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍ជាតិនោះ ឬការពង្រឹងសមត្ថភាពជាតិឡើយ។ ទោះបីជា ជំនួយប្រភេទនេះត្រូវបានកត់ត្រាជាជំនួយអភិវឌ្ឍន៍ផ្លូវការក៏ដោយ ក៏ជំនួយនេះផ្តោតសំខាន់តែទៅលើជំនួយមនុស្សធម៌ប៉ុណ្ណោះ ពោលគឺមិនផ្តោតលើកិច្ចសហប្រតិបត្តិការ ដើម្បីកិច្ចអភិវឌ្ឍន៍នោះទេ។

### ១.៣.៤. កត្តាដែលជំរុញឲ្យមានការផ្តល់ ODA ពីប្រទេសអភិវឌ្ឍន៍

គោលដៅសំខាន់នៃការផ្តល់ ODA គឺដើម្បីជំរុញការអភិវឌ្ឍ និងសុខុមាលភាពសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍។ ចំពោះទស្សនៈរបស់ប្រទេសដែលផ្តល់ជំនួយ ផ្ទុយទៅវិញ កម្មវត្ថុរបស់ពួកគេក្នុងការផ្តល់ ODA មិនដូចគ្នាទាំងអស់នោះទេ ដោយសារតែរបៀបវីរៈ និងកម្មវត្ថុថ្នាក់ជាតិក៏ដូចជាប្រវត្តិទំនាក់ទំនង និងវប្បធម៌ជាមួយប្រទេសកំពុងអភិវឌ្ឍន៍មានភាពទូលំទូលាយ។ កត្តា

ដែលនៅពីក្រោយការផ្តល់ ODA កន្លងមកមាន ៣ គឺៈ កត្តានយោបាយនិងការទូត កត្តាសេដ្ឋកិច្ច និងកត្តាមនុស្សធម៌។ ក៏ប៉ុន្តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ការកើនឡើងនៃការពឹងអាស្រ័យគ្នាទៅវិញទៅមករវាងបណ្តាប្រទេសទាំងអស់កាន់តែខ្លាំងឡើង ដោយសារសកលភាវូបនីយកម្ម នោះជាមូលហេតុដែល វាត្រូវបានគេចាត់ទុកថាជាកត្តាដ៏សំខាន់មួយក្នុងចំណោមកត្តាដទៃទៀតក្នុងការផ្តល់ ODA ផងដែរ ។

**១.៣.៤.១. កត្តានយោបាយ និងការទូត**

ODA ត្រូវបានជះឥទ្ធិពលដោយកត្តាជាច្រើនរួមមាន ការការពារឧបសម្ព័ន្ធ មនោគមវិជ្ជានយោបាយ ប្រវត្តិទំនាក់ទំនង ការការពារសុវត្ថិភាព និងគោលនយោបាយបរទេស។ អំឡុងពេលសង្គ្រាមត្រជាក់ លោកខាងលិចនិងលោកខាងកើត បានប្រើប្រាស់ការផ្តល់ជំនួយ ជាឧបករណ៍យុទ្ធសាស្ត្រ ដើម្បីពង្រីកអំណាចរបស់ខ្លួន តាមរយៈ ការបញ្ជ្រាបមនោគមវិជ្ជារបស់ពួកគេ។ ប្រទេសមហាអំណាចអឺរ៉ុប បានផ្តល់ជំនួយអភិវឌ្ឍន៍ទៅកាន់អតីតប្រទេស ដែលស្ថិតនៅក្រោមអាណានិគមរបស់ខ្លួន ក្នុងគោលបំណងជាការទូទាត់សំណង ក៏ដូចជាការរក្សានូវឥទ្ធិពលរបស់ខ្លួនលើប្រទេសទាំងនោះផងដែរ។ នាប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសដែលផ្តល់ជំនួយបានបង្កើន ODA ដើម្បីពង្រីកទំនាក់ទំនងរបស់ពួកគេ រួមជាមួយការជ្រៀតចូលក្នុងសេដ្ឋកិច្ច និងការកសាងនូវសក្តានុពលរបស់ខ្លួន ដើម្បីលើកតម្កើនវត្តមានរបស់ពួកគេលើឆាកអន្តរជាតិ។

**១.៣.៤.២. កត្តាសេដ្ឋកិច្ច**

កត្តាសេដ្ឋកិច្ច ត្រូវបានផ្សារភ្ជាប់ជាមួយនឹងផ្នត់គំនិតមួយដែលថា ODA អាចជាមូលដ្ឋានគ្រឹះដ៏សំខាន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ហើយវាក៏អាចផ្តល់ផលត្រលប់មកវិញ តាមរយៈការពង្រីកឱកាសទីផ្សារឲ្យដល់ក្រុមហ៊ុនក្នុងប្រទេសផ្តល់ជំនួយ ដែលកំពុងមានបំណងដាក់ទីតាំងនៅទីផ្សារក្រៅប្រទេសផងដែរ។

**១.៣.៤.៣. កត្តាមនុស្សធម៌**

កត្តានេះបានផ្តើមឲ្យមានកិច្ចសហប្រតិបត្តិការ ប្រកបដោយមនុស្សធម៌នៃសកលលោក ក្នុងគោលបំណងលុបបំបាត់ភាពក្រីក្រ ដើម្បីជួយលើកតម្កើនតម្លៃមនុស្សជាតិជាសកល (ឧទាហរណ៍ សិទ្ធិមនុស្សជាដើម)។ ទស្សនវិស័យនៃមនុស្សធម៌ ដោយផ្តោតលើភាពជាក់ស្តែងដែលរូបភាពរបស់ភាពក្រីក្រដែលនៅតែកើតមាន បើទោះបីជាបណ្តាប្រទេសមួយចំនួននៅលើពិភពលោក បានសម្រេចនូវការអភិវឌ្ឍដ៏អស្ចារ្យចាប់តាំងពីក្រោយសង្គ្រាមលោកទី ២ ក៏ដោយ។ ហេតុនេះ ការផ្តល់ជំនួយដល់ប្រជាជនដែលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាកិច្ចមួយដ៏មាន

តម្លៃ ដើម្បីឲ្យពួកគាត់ទទួលបាននូវជីវភាពរស់នៅសមរម្យ ហើយក៏អាចបំពេញកិច្ចការងារប្រកបដោយមនុស្សធម៌ ដែលនាំឲ្យមានការលើកកម្ពស់គុណតម្លៃរបស់ពិភពលោក។

**១.៣.៤.៤. កត្តាសមាគមឯករាជ្យពិភពលោក**

ក្នុងយុគសម័យទំនើប ដែលមានការផ្សារភ្ជាប់ទំនាក់ទំនងកាន់តែជិតស្និតនោះ ប្រជាជនក៏ដូចជាព័ត៌មាន ត្រូវបានអនុញ្ញាតឲ្យចល័តចេញ និងចូលក្នុងប្រទេសដោយសេរី។ មិនត្រឹមតែប៉ុណ្ណោះ អ្វីដែលកើតឡើងក្នុងមាតុប្រទេសមួយ មិនមែនមានវត្តមានត្រឹមក្នុងទឹកដី ឬត្រឹមព្រំដែនកំណត់របស់ប្រទេសនោះទេ តែវាអាចជះឥទ្ធិពលយ៉ាងឆាប់រហ័សដល់ប្រទេសជិតខាង និងបណ្តាប្រទេសផ្សេងទៀតផងដែរ។ ជាឧទាហរណ៍ដូចជា ការបំពុលបរិស្ថាន ការប្រែប្រួលអាកាសធាតុ ការរីករាលដាលនៃជំងឺឆ្លង ក៏ដូចជាអស្ថេរភាពនយោបាយជាដើម សុទ្ធតែធ្វើឲ្យមានសកលលោកចលាចល តាមរយៈការបង្កើតឲ្យមានភេរវកម្ម ឬវិបត្តិជនភៀសខ្លួន ដែលបណ្តាលឲ្យកើតមានការគំរាមកំហែងដល់សន្តិសុខ សុវត្ថិភាពរបស់ពិភពលោកកាន់តែធ្ងន់ធ្ងរ។ ក្នុងបរិបទនៃការផ្លាស់ប្តូរពិភពលោកនេះ ប្រទេសម្ចាស់ជំនួយ បានចាប់ផ្តើមទទួលស្គាល់ថាប្រទេសកំពុងអភិវឌ្ឍន៍មិនមែនជាប្រទេសទទួលជំនួយទេ តែជាដៃគូសេដ្ឋកិច្ច និងនយោបាយដ៏សំខាន់ដែលមានទំនាក់ទំនងយ៉ាងជិតស្និត ដើម្បីភាពរុងរឿង និងការរស់នៅយូរអង្វែង។

**១.៣.៥. ផលវិជ្ជមានចំពោះប្រទេសកំពុងអភិវឌ្ឍន៍ដែលទទួល** ODA

ប្រទេសកំពុងអភិវឌ្ឍន៍ មានលទ្ធភាពតិចតួចនៅក្នុងការនាំចូលគ្រឿងម៉ាស៊ីន និងទំនិញមូលធនផ្សេងៗ។ ហេតុនេះ ជំនួយបរទេស មានសារៈសំខាន់ណាស់ក្នុងការបំពេញការសន្សំពោលគឺកាត់បន្ថយគម្លាតវិនិយោគនិងពាណិជ្ជកម្ម ដោយបង្កើនការវិនិយោគ ហើយជំរុញឲ្យមានកំណើន។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៨០មក មានគោលដៅនៃការផ្តល់ជំនួយជាច្រើន ស្របពេលដែលមានការរំពឹងទុកនូវផលប្រយោជន៍ជាច្រើននៅក្នុងលក្ខខណ្ឌ កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ ការវិនិយោគ និងការចំណាយសាធារណៈ ទៅលើសេវាកម្មដែលមាននៅក្នុងប្រទេសទទួលជំនួយ ឬប្រទេសកំពុងអភិវឌ្ឍន៍។

លើសពីនេះទៅទៀត ជំនួយបរទេស ក្នុងរូបភាពជាជំនួយបច្ចេកទេស គឺបានផ្តល់ឲ្យនូវចំណេះដឹង និងជំនាញបច្ចេកទេស ដែលអាចជះឥទ្ធិពលវិជ្ជមានដល់ដំណើរការអភិវឌ្ឍន៍។ ចំណេះដឹង និងជំនាញបច្ចេកទេស ត្រូវបានគេរំពឹងថានឹងអាចធ្វើឲ្យមានដំណើរការអភិវឌ្ឍន៍តាមរយៈការលើកកម្ពស់គុណភាពកម្លាំងពលកម្ម (ធនធានមនុស្ស) និងបំពេញនូវចន្លោះខ្វះខាតនៃជំនាញ។

ការផ្តល់ជំនួយតាមការគាំទ្រថវិកាជាតិ អាចជួយដល់រដ្ឋាភិបាលឆ្លើយតបនឹងការអភិវឌ្ឍ និងបង្វិលការចំណាយរបស់ខ្លួន។ ដូច្នេះ ជំនួយបរទេសលើការវិនិយោគលើវិស័យអប់រំ សុខភាព និងហេដ្ឋារចនាសម្ព័ន្ធរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ។

ការឧបត្ថម្ភការនាំចូល (ដែលស្ថិតនៅក្រោមកម្មវិធីផ្តល់ជំនួយ) ជួយបង្កើនសមត្ថភាពផលិតរបស់សហគ្រាសសាធារណៈនិងឯកជន ដែលជាលទ្ធផលនាំឲ្យមានការជំរុញផលិតកម្ម ទទួលបានទិន្នផលខ្ពស់ និងបង្កើនលទ្ធភាពប្រើប្រាស់។

លើសពីនេះទៀត ជំនួយបរទេស មានសារៈសំខាន់ណាស់ក្នុងគ្រា ដែលប្រទេសអភិវឌ្ឍន៍មានអាសន្ន ជាពិសេសនៅក្នុងតំបន់ ដែលងាយរងគ្រោះដោយសារសង្គ្រាម និងតំបន់ដែលកំពុងរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិដូចជា ព្យុះជាដើម។ ករណីភាគច្រើន ជំនួយមនុស្សធម៌នេះបានជួយសង្គ្រោះជីវិតមនុស្សជាច្រើន ដោយបានផ្តល់ម្ហូបអាហារដល់អ្នកអត់ឃ្លាន និងថែទាំសុខភាព ផ្តល់ឱសថដល់អ្នកដែលងាយរងគ្រោះនឹងជំងឺធ្ងន់ធ្ងរពេលមានអាសន្ន។

ការផ្ទេរបន្ទុកបំណុល អាចបន្ធូរបន្ថយការរឹតបន្តឹងលើការប្តូររូបិយប័ណ្ណអន្តរជាតិ និងជួយកាត់បន្ថយការសងបំណុលដ៏ច្រើនលើសលប់។ ធនធានបន្ថែមពីការលុបចោលបំណុល ជួយបង្កើនការនាំចូល និងជំរុញការវិនិយោគ។

## **១.៤. ការផ្តល់ ODA របស់កូរ៉េ**

### **១.៤.១. ប្រវត្តិនៃការផ្តល់ ODA របស់កូរ៉េ**

សង្គ្រាមប្រទេសកូរ៉េ ដែលបានចាប់ផ្តើមនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥០ ត្រូវបានបញ្ចប់នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៥៣ ដោយបន្សល់ទុកនូវប្រទេសឲ្យស្ថិតនៅក្នុងចំណោមបណ្តាប្រទេសក្រីក្របំផុតលើពិភពលោក។ ខណៈពេលនោះ ប្រភពមូលធនតែមួយគត់ដែលមាននៅក្នុងប្រទេសកូរ៉េគឺបានមកពី ជំនួយផ្លូវការ។ នៅទសវត្សរ៍ឆ្នាំ ១៩៥០ គោលដៅសំខាន់នៃជំនួយគឺជំនួយមនុស្សធម៌ និងជំនួយយោធា។ ចំណែកទសវត្សរ៍ឆ្នាំ ១៩៦០ ការវិនិយោគទុនបរទេសធំៗបានជំរុញកំណើនសេដ្ឋកិច្ច បើទោះបីជា ODA បានកំពុងបន្តផ្តល់ដល់កូរ៉េក៏ដោយ។ ជាលទ្ធផលនោះ រចនាសម្ព័ន្ធសេដ្ឋកិច្ចកូរ៉េ ត្រូវបានផ្លាស់ប្តូរទៅជាប្រសើរឡើងវិញ។ ODA ដែលបានផ្តល់ឲ្យប្រទេសកូរ៉េ ត្រូវបានពង្រីកវិសាលភាពពី ជំនួយឥតសំណងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ទៅជាការផ្តល់ប្រាក់កម្ចីសម្បទាន ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្ម។ នៅទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ការកែតម្រូវកម្មវិធីប្រាក់កម្ចី ឬកម្ចីតាមវិស័យ បានរួមចំណែកដល់ការធ្វើ

កំណែទម្រង់រចនាសម្ព័ន្ធឧស្សាហកម្មទាំងមូល។ ខណៈពេលសេដ្ឋកិច្ចប្រទេសកូរ៉េកំពុងកាន់តែមានភាពរឹងមាំ ប្រភពធនធាន ODA កាន់តែមានភាពសម្បូរបែបឡើង។

ប្រទេសកូរ៉េបានក្លាយជាម្ចាស់ជំនួយក្នុងទសវត្សឆ្នាំ១៩៦០។ ជំហានដំបូងក្នុងការផ្តល់ជំនួយនោះបានកើតឡើងនៅឆ្នាំ១៩៦៣ ពេលដែលប្រទេសកូរ៉េបានរៀបចំកម្មវិធីបណ្តុះបណ្តាលមួយ ដែលឧបត្ថម្ភដោយសហរដ្ឋអាមេរិក សម្រាប់មន្រ្តីសាធារណៈមកពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ នៅឆ្នាំ១៩៧៧ ប្រទេសកូរ៉េបានផ្តល់សម្ភារដែលគិតជាទឹកប្រាក់ចំនួន USD ២ លានដុល្លារ ដោយថវិកាផ្ទាល់ខ្លួនជាលើកដំបូង។ ឆ្នាំ១៩៨៧ ប្រទេសកូរ៉េបង្កើតមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច (EDCF) ដើម្បីផ្តល់ប្រាក់កម្ចីសម្បទានដល់ប្រទេសកំពុងអភិវឌ្ឍន៍។ ក្រោយមកនៅឆ្នាំ ១៩៩១ ប្រទេសកូរ៉េក៏បានធ្វើការចាប់ផ្តើមផ្តល់នូវជំនួយឥតសំណង តាមរយៈការបង្កើតទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)។ រហូតដល់ឆ្នាំ២០០០ ប្រទេសកូរ៉េត្រូវបានលុបឈ្មោះចេញពីបញ្ជីអ្នកទទួលODA ដោយ DAC(គណៈកម្មាធិការជំនួយអភិវឌ្ឍន៍)។ បន្ទាប់មក ប្រទេសកូរ៉េអាចចូលរួមជាសមាជិក DAC ក្នុងអង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ក្នុងនាមជាសមាជិកម្ចាស់ជំនួយអន្តរជាតិនៅខែវិច្ឆិកា ឆ្នាំ២០០៩។

### ១.៤.២. ការចាត់ថ្នាក់ ODA របស់កូរ៉េ

| ប្រភេទនៃជំនួយ | | | ភ្នាក់ងារ | ក្រសួងទទួលបន្ទុក |
|---|---|---|---|---|
| **ជំនួយទ្វេភាគី** | ជំនួយឥតសំណង | ជំនួយសម្ភារ | KOICA | MOFAT |
| | | ជំនួយហិរញ្ញវត្ថុ | | |
| | | ជំនួយលើគម្រោង | | |
| | | កិច្ចសហប្រតិបត្តិការបច្ចេកទេស(ជំនួយលើការស្រាវជ្រាវ ការអញ្ជើញអ្នកហាត់រៀនធ្វើការការ បញ្ជូនអ្នកជំនាញ និងអ្នកស្ម័គ្រចិត្ត) | | |
| | កម្ចីសម្បទាន | ជំនួយកម្ចីអភិវឌ្ឍន៍ (មូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច EDCF) | EXIM | MOSF |
| **ជំនួយពហុភាគី** | វិភាគទាន ៖ ប្រព័ន្ធ UN និងស្ថាប័នពហុជាតិដទៃទៀត | | MOFAT | MOFAT |
| | បរិវិសទានមូលធន ៖ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ | | Bank of Korea | MOSF |

*(ប្រភព ៖ www.odakorea.go.kr)*

ODA ត្រូវបានគេចាត់ថ្នាក់ជាពីរគឺ ODAទ្វេភាគី និងពហុភាគី។ ODAទ្វេភាគីមាន ២ ប្រភេទ គឺ ជំនួយឥតសំណង និងកម្ចីសម្បទាន។ ជំនួយឥតសំណង គឺជាការផ្តល់ហិរញ្ញវត្ថុ ទំនិញ រួមទាំងសេវាកម្មទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយគ្មានទាមទារនូវសំណងត្រលប់មកវិញ។ ផ្ទុយទៅវិញ កម្ចីសម្បទាន ជាការផ្តល់ហិរញ្ញវត្ថុ ទំនិញ និងសេវាកម្មទៅប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងន័យជាកម្ចី តែមានលក្ខណៈអនុគ្រោះជាងមូលនិធិវិស័យឯកជនផ្សេងទៀត ហើយវាទាមទារឲ្យមានសំណងវិញ។

ODA ពហុភាគី ត្រូវបានគេបែងចែកជា ២ គឺ វិភាគទាន និងបរិវិសទានមូលធន។ វិភាគទានសំដៅទៅលើការបែងចែកមូលនិធិទៅកាន់អង្គការអន្តរជាតិ ដូចជា ភ្នាក់ងារ UN ដើម្បីចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីដោះស្រាយឲ្យបាននូវបញ្ហាសេដ្ឋកិច្ច សង្គម បរិស្ថាន រួមទាំងភាពក្រីក្រ និងការលើកកម្ពស់ស្ត្រី។ បរិវិសទានមូលធន សំដៅទៅលើការបែងចែកមូលនិធិទៅឲ្យធនាគារអភិវឌ្ឍន៍ជំនួយពហុភាគី (MDBs) ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ដែលនេះជាការផ្តល់ជំនួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ដោយប្រយោល។

### ១.៤.៣. ក្របខណ្ឌផ្លូវច្បាប់នៃការផ្តល់ ODA របស់កូរ៉េ[7]

កូរ៉េបានអនុម័តច្បាប់ស្តីពី កិច្ចសហប្រតិបត្តិការអន្តរជាតិ និងអនុក្រឹត្យ ដែលបានចូលជាធរមាននៅក្នុងខែ កក្កដា ឆ្នាំ ២០១០ ហើយក៏បានដាក់មូលដ្ឋានច្បាប់សម្រាប់ប្រព័ន្ធ ODA ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ផងដែរ។ ច្បាប់នេះបានកំណត់ពីៈ

- គោលការណ៍ និងគោលដៅចម្បងៗ
- តួនាទីរបស់គណៈកម្មាធិការសហប្រតិបត្តិការអន្តរជាតិក្នុងកិច្ចអភិវឌ្ឍន៍ (CIDC)
- ការបង្កើតគោលនយោបាយ ODA រយៈពេលមធ្យម
- តួនាទី និងមុខងាររបស់ភ្នាក់ងារត្រួតពិនិត្យកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ
- ការជ្រើសរើសប្រទេសជាដៃគូអាទិភាព
- ការវាយតម្លៃ
- ការគាំទ្រដល់អង្គការសង្គមស៊ីវិល
- ទំនាក់ទំនងសាធារណៈ ដើម្បីបង្កើនតម្លាភាព និងការចូលរួមរបស់ប្រជាជន ។

ចំណែកឯអនុក្រឹត្យដែលចេញដោយរដ្ឋាភិបាលវិញ បានចែងពីសេចក្តីលំអិតនៃអំណាចដែលត្រូវអនុវត្តន៍ច្បាប់នេះ។

[7] https://www.odakorea.go.kr/eng.policy.Legal.do (ចូលទស្សនាថ្ងៃទី ៣០ មីនា ២០១៩)

យោងតាមមាត្រា ៣ នៃក្របខណ្ឌច្បាប់ខាងលើ បានចែងពីគោលការណ៍ជាមូលដ្ឋានចំនួន ៥ នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិរបស់កូរ៉េ ដែលមានដូចតទៅ ៖

១. ការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍

២. លើកកម្ពស់សិទ្ធិមនុស្ស ស្ត្រី និងកុមារ ព្រមទាំងសម្រេចឲ្យបាននូវសមភាពយេនឌ័រ

៣. ការស្វែងយល់ពីការអភិវឌ្ឍប្រកបដោយចេរភាព និងមនុស្សធម៌

៤. ការជំរុញទំនាក់ទំនងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយដៃគូអភិវឌ្ឍន៍

៥. ការបន្តបង្កើតសន្តិភាព និងវិបុលភាពនៅក្នុងសមាគមអន្តរជាតិ។

នៅក្នុងខ្លឹមសារនៃគោលការណ៍ទាំង៥ ខាងលើនេះ បានបង្ហាញពីកម្មវត្ថុសំខាន់មួយចំនួន នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិរបស់កូរ៉េ ដើម្បីសម្រេចបាននូវបញ្ហាដូចខាងក្រោម ៖

- ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។
- ការគាំទ្រការអភិវឌ្ឍរបស់ប្រទេសដៃគូ និងពង្រឹងប្រព័ន្ធ និងលក្ខខណ្ឌនៃការអភិវឌ្ឍ។
- ពង្រឹងទំនាក់ទំនងមិត្តភាពជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។
- ការរួមចំណែកក្នុងការដោះស្រាយបញ្ហាជាសកល ទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ។
- ព្រមទាំងបញ្ហាផ្សេងទៀតដែលចាំបាច់សម្រាប់ការអនុវត្តគោលការណ៍មូលដ្ឋាន។

ក្រៅពីច្បាប់ និងអនុក្រឹត្យខាងលើ កូរ៉េក៏មានច្បាប់ជាច្រើនទាក់ទងនឹងការកំណត់ភ្នាក់ងារ ODA ជាមួយនឹងសកម្មភាពផងដែរ ដែលមានដូចជា ៖

**ច្បាប់ស្តីពី វិធានការសម្រាប់ការដាក់សំណើទៅកាន់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ** (អនុម័តនៅឆ្នាំ ១៩៦៣) ដែលចែងពីការធ្វើនិយ័តកម្មសមាជិកភាពជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងវិធានការនានាដើម្បីបំពេញភារកិច្ចជាសមាជិក ដែលបានមានចែងនៅក្នុងកិច្ចព្រមព្រៀងគ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនីមួយៗ។

**ច្បាប់ស្តីពី មូលនិធិសហប្រតិបត្តិការសេដ្ឋកិច្ច** (អនុម័តឆ្នាំ១៩៨៧) ចែងពីការធ្វើនិយតកម្មបង្កើតកិច្ចសហប្រតិបត្តិការនិងគ្រប់គ្រងមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រាក់កម្ចី។

**ច្បាប់ស្តីពី ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ** (អនុម័តនៅឆ្នាំ ១៩៩១) ដែលចែងពីការបង្កើតមូលដ្ឋានគ្រឹះនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) និងអាណត្តិរបស់ខ្លួនដើម្បីអនុវត្តគម្រោងជំនួយឥតសំណងនិងកិច្ចសហប្រតិបត្តិការបច្ចេកទេស។

**ច្បាប់ស្តីពី ជំនួយសង្គ្រោះបន្ទាន់ក្រៅប្រទេស** (អនុម័តនៅឆ្នាំ ២០០៧) ដែលចែងពីកិច្ចចាំបាច់សម្រាប់ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ទៅបរទេសមាន ការផ្តល់ឧបករណ៍ ការបញ្ជូនក្រុមសង្គ្រោះបន្ទាន់ និងការផ្តល់ជំនួយបណ្តោះអាសន្នដល់ប្រទេសដែលរងគ្រោះធម្មជាតិជាដើម។

### ១.៤.៤. គោលនយោបាយជំនួយអភិវឌ្ឍន៍ផ្លូវការរបស់កូរ៉េ




*(ប្រភព ៖ KOREA's ODA WHITE PAPER 2017)*

ការចូលរួមជាសមាជិក DAC គឺជាចំណុចរបត់មួយនៅក្នុងប្រព័ន្ធ ODA របស់ប្រទេសកូរ៉េ។ ខណៈពេលដែលត្រូវស្របតាមបទដ្ឋានអន្តរជាតិ រដ្ឋាភិបាលកូរ៉េកំពុងធ្វើការយ៉ាងណា គឺដើម្បី

---

[8] International Aid Transparency Initiative (គំនិតផ្តួចផ្តើមអំពីតម្លាភាពជំនួយអន្តរជាតិ) ជាគំនិតផ្តួចផ្តើមជាសកលដើម្បីលើកកម្ពស់តម្លាភាពនៃការអភិវឌ្ឍនធនធានមនុស្សនិងលទ្ធផលរបស់ពួកគេដើម្បីដោះស្រាយភាពក្រីក្រនិងវិបត្តិ។

[9] Human Life International (ជីវិតមនុស្សជាអន្តរជាតិ)គឺជាក្រុមប្រឆាំងការរំលូតកូនជាអន្តរជាតិ ដែលមានមូលដ្ឋាននៅសហរដ្ឋអាម៉េរិក។

បង្កើតនូវក្តីសង្ឃឹម និងសន្តិភាពពិភពលោក ក៏ដូចជាចែករំលែកនូវបទពិសោធអភិវឌ្ឍន៍ដ៏ជោគជ័យរបស់ប្រទេសកូរ៉េជាមួយបណ្តាប្រទេសដទៃដែលជាដៃគូរបស់ខ្លួន។ មកទល់នឹងពេលនេះ ប្រទេសនេះបានអនុម័តក្របខ័ណ្ឌច្បាប់ និងអនុក្រឹត្យ ដើម្បីអភិវឌ្ឍន៍គម្រោងយុទ្ធសាស្ត្រ នាខែតុលា ឆ្នាំ២០១០ ដោយបង្កើតយុទ្ធសាស្ត្ររយៈពេលមធ្យមសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទី១ និងទី២ (២០១១ - ២០១៥ និង ២០១៦ - ២០២០) ក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីឲ្យស្ថាប័នមួយនេះកាន់តែមានភាពរឹងមាំ និងជាមូលដ្ឋានក្នុងការផ្តល់ ODA របស់ខ្លួន។

ស្របតាមទស្សនៈ និងគោលការណ៍ជាមូលដ្ឋាន ដែលបានកំណត់ក្នុងក្របខ័ណ្ឌការងាររដ្ឋាភិបាលកូរ៉េ បន្តពង្រីក ODA របស់ខ្លួន ស្របពេលដែលពួកគេកំពុងកែលម្អប្រព័ន្ធ ODA ដែរ។ យុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០១៦-២០២០) សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ កំណត់សសរស្តម្ភបីយ៉ាងច្បាស់ **ODA សមាហរណកម្ម ODA សំខាន់** និង **ODA រួមសហការ** និង កំណត់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព(SDGs) និងគោលដៅគោលនយោបាយ។

**ODA សមាហរណកម្ម** មានការគិតពីសារៈសំខាន់នៃការគ្រប់គ្រង ODA ដែលប្រកបដោយតម្លាភាព ក៏ដូចជាប្រសិទ្ធភាពក្នុងបរិបទដែលចំនួនអង្គការសហប្រតិបត្តិការអភិវឌ្ឍន៍ និងគម្រោងដែលកំពុងបន្តកើនឡើង។ តាមរយៈការជំរុញកិច្ចសហការ វាត្រូវបានគេយល់ឃើញថា ODA អាចត្រូវបានផ្តល់ឲ្យក្នុងលក្ខណៈរួមបញ្ចូលគ្នា ប្រកបដោយការសហការនិងជាប្រព័ន្ធ ហើយវាក៏បានដោះស្រាយផងដែរនូវបញ្ហានៃការបែងចែក។

**ODA សំខាន់** ពាក់ព័ន្ធនឹងការកែលម្អនីតិវិធីកំណត់អត្តសញ្ញាណគម្រោង ដោយពង្រឹងការសម្របសម្រួល ODA របស់ប្រទេសកូរ៉េ និងការពិគ្រោះយោបល់ជាមួយបណ្តាប្រទេសជាដៃគូរបស់ខ្លួន និងពង្រឹងការគ្រប់គ្រងក្រោយបញ្ចប់គម្រោង និងការវាយតម្លៃដោយឯករាជ្យ។

**ODA រួមសហការ** ដើម្បីមានការទទួលស្គាល់ ចាប់អារម្មណ៍កាន់តែច្រើន ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ រដ្ឋាភិបាលកូរ៉េកំពុងធ្វើការប្រមូលផ្តុំដៃគូពាក់ព័ន្ធមិនមែនរដ្ឋាភិបាលរួមមានសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ និងពាណិជ្ជករ និងពង្រឹងភាពជាដៃគូជាមួយអង្គការអន្តរជាតិ ដូចជា បណ្តាញការវាយតម្លៃការអនុវត្តស្ថាប័នពហុភាគី (MOPAN) និងក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមអ.ស.ប (ECOSOC)។

តាមរយៈសកម្មភាពទាំងនេះ ប្រទេសកូរ៉េបានពិនិត្យឡើងវិញនូវប្រព័ន្ធ ODA ទាំងអស់របស់ខ្លួនហើយបានកំណត់តម្រូវការចាំបាច់សម្រាប់យុទ្ធសាស្ត្ររួមគ្នា និងប្រព័ន្ធគ្រប់គ្រងដែលមានមូលដ្ឋានផ្អែកលើលទ្ធផលនៃការសម្របសម្រួល។ ដោយយល់អំពីបញ្ហាបែកចែកក្នុងប្រព័ន្ធ

ODA កូរ៉េបានខិតខំប្រឹងប្រែងអនុវត្ត ODA ឲ្យកាន់តែស៊ីជម្រៅនៅក្នុងចំណោមភ្នាក់ងារជាច្រើន និងនៅក្នុងការអនុម័តប្រភេទផ្សេងទៀតនៃ ODA។ ដើម្បីធ្វើដូច្នេះឲ្យបាននោះ រដ្ឋាភិបាលកូរ៉េ បានធ្វើការបង្កើត គណៈកម្មាធិការសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ជាអន្តរជាតិ (CIDC) ក្រោមការិយាល័យរបស់នាយករដ្ឋមន្ត្រី។ រដ្ឋាភិបាលកូរ៉េ បានរៀបចំ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស (CPS) សម្រាប់ប្រទេសទទួលជំនួយជាដៃគូអាទិភាពដែលត្រូវបានជ្រើសរើស។ CPS បានផ្តល់នូវការណែនាំរួមសម្រាប់គ្រប់ក្រសួង និងភ្នាក់ងារប្រតិបត្តិ ODA ទាំងអស់ និងដើរតួជាគោលការណ៍ណែនាំមូលដ្ឋានសម្រាប់ផ្តល់ជំនួយដល់ប្រទេសដែលមានអាទិភាព ដោយវិស័យសំខាន់ពីរ ឬបីត្រូវបានកំណត់ជ្រើសរើស និងផ្តោតគោលដៅបង្កើនប្រសិទ្ធភាពជំនួយ។

### **១.៤.៥. ប្រព័ន្ធគ្រប់គ្រង** ODA **របស់កូរ៉េ**

**រចនាសម្ព័ន្ធការគ្រប់គ្រង** ODA **របស់កូរ៉េ**




*(ប្រភព ៖ OECD Development Co-operation Peer Reviews KOREA 2018)*

CIDC ជាស្ថាប័នសំរបសំរួល និងអនុម័តគោលនយោបាយ ODA ទាំងអស់ ដើម្បីពង្រឹកទំនាក់ទំនងគោលនយោបាយ និងប្រព័ន្ធកម្មវិធីផ្តល់ជំនួយ។ MOSF និង MOFA ដែលគ្រប់គ្រងប្រាក់កម្ចីសម្បទាននិងជំនួយឥតសំណង ត្រូវធ្វើសេចក្តីព្រាងគោលនយោបាយODA រយៈពេលមធ្យម និងផែនការអនុវត្តប្រចាំឆ្នាំ ដែលបានអនុម័តចុងក្រោយដោយ CIDC។ KOICA និង Korea Eximbank បានអនុវត្តជំនួយឥតសំណង និងប្រាក់កម្ចីសម្បទានរៀងខ្លួន និងក្រសួងផ្សេងទៀត[10] ក៏មានតួនាទីក្នុងការផ្តល់ODA របស់កូរ៉េដែរ ជាពិសេសសម្រាប់ជំនួយឥតសំណង និងកិច្ចសហប្រតិបត្តិការបច្ចេកទេស។

**តួអង្គសំខាន់ក្នុងកិច្ចសហប្រតិបត្តិការរបស់កូរ៉េ[11] ៖**

- **នាយករដ្ឋមន្ត្រី** លោក Lee Nak-yeon ត្រូវបានតែងតាំងដោយ ប្រធានាធិបតី លោក Moon Jae-in ដែលជាអ្នកគ្រប់គ្រងរដ្ឋាភិបាលកូរ៉េខាងត្បូង និងបង្កើតគោលការណ៍ការណែនាំ យុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ក្រសួង និងទីភ្នាក់ងារនានាត្រូវកំណត់គោលដៅជាមួយចំនួនODA និងវិស័យអាទិភាព ដើម្បីដាក់ជូនប្រធានាធិបតី។ នៅក្នុង**ការិយាល័យរបស់នាយករដ្ឋមន្ត្រី** លោក Park Jin-ho គឺជាអគ្គនាយកការិយាល័យ ODA។ ស្ថិតក្រោមអំណាចប្រធានាធិបតី ការបង្កើតគោលនយោបាយ និងការអនុម័តមានក្រសួងពីរ ដែលអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍មួយនេះ គឺ ក្រសួងការបរទេស (MOFA) និងក្រសួងយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ (MOSF)។
- CIDC ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ហើយចាប់តាំងពីពេលនោះមក វាបានអនុវត្តន៍គោលនយោបាយសំខាន់ និងផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិសម្រាប់ឆ្នាំ ២០១៦-២០២០ និងផែនការ ការអនុវត្ត ODA ប្រចាំឆ្នាំទៀតផង។ គោលនយោបាយដែលទាក់ទងទៅនឹងជំនួយអភិវឌ្ឍន៍សំខាន់ៗ គឺត្រូវបានអនុម័តដោយគណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (CIDC)។ CIDC មានសមាជិកចំនួន ២៥ នាក់រួមទាំងនាយករដ្ឋមន្ត្រី (ដែលជាប្រធាន CIDC) សមាជិកគណៈរដ្ឋមន្ត្រី ១៤នាក់ ប្រធានKOICA ប្រធានKorea Eximbank និងអ្នកជំនាញ ៧នាក់។ CIDC មានកិច្ចប្រជុំប្រហែល ៣ ដងក្នុងមួយឆ្នាំ។ អនុគណៈកម្មាធិការវាយតម្លៃ ដែលរួមមានសមាសភាពដូចជា អគ្គនាយកក្រសួង MOFA និង MOSF នាយកប្រតិបត្តិមកពី KOICA និង Korea

[10] ឧបសម្ព័ន្ធទី១

[11] https://donortracker.org/country/south-korea (ចូលទស្សនាថ្ងៃទី ៣០ មីនា ២០១៩)

Eximbank រួមទាំងអ្នកតំណាងចំនួន ៩ រូប ដែលមកពីស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិល តែងតែជួបប្រជុំគ្នាមុនកិច្ចប្រជុំ CIDC នីមួយៗ។ អនុគណៈកម្មាធិការ មានតួនាទីពិនិត្យឡើងវិញ ដើម្បីធ្វើការកែតម្រូវនៃការចំណាយ ODA របស់កូរ៉េខាងត្បូង ជាមួយរបៀបវារៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព (SDGs) និងផ្តល់ប្រឹក្សាយោបល់ដល់ CIDC។

- **MOFA** បច្ចុប្បន្នដឹកនាំដោយ Kang Kyung-wha មានតួនាទីកំណត់គោលនយោបាយ និងអាទិភាពសម្រាប់ជំនួយឥតសំណងទ្វេភាគី និង ODA ពហុភាគីតាមរយៈ អ.ស.ប និងមូលនិធិពហុភាគីជាច្រើនដូចជា មូលនិធិសកលប្រយុទ្ធនាំងនឹងជំងឺអេដស៍ របេង និងជំងឺគ្រុនចាញ់ ជាដើម។ ចំពោះជំនួយទ្វេភាគីវិញ គឺត្រូវបានធ្វើការអនុវត្តដោយ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA) ដែលត្រូវត្រួតពិនិត្យដោយក្រសួងការបរទេស។ នៅក្នុងក្រសួងនេះ អគ្គនាយក (នាពេលបច្ចុប្បន្នលោក Jeon Jin-kyu) ទទួលខុសត្រូវចំពោះការិយាល័យ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ក្នុងផែនការការងារប្រចាំឆ្នាំរបស់ខ្លួន MOFA សំដៅពង្រឹងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធ ក្នុងស្រុកនិងអន្តរជាតិ និងពង្រីករបៀបវារៈរបស់ខ្លួន ដោយបង្កើនថវិកា ODA និង ជំនួយមនុស្សធម៌សរុប បង្កើនការសហការគ្នារវាងការអភិវឌ្ឍ និងកិច្ចការបរទេស គាំទ្រដល់សមត្ថភាពអង្គការមិនមែនរដ្ឋាភិបាល និងវិស័យដទៃទៀត ដៃគូសហការកម្រិតតូច និងលើកកំពស់គណនេយ្យភាព ប្រសិទ្ធភាព និងតម្លាភាពនៃODA។
- **MOSF** ដែលបច្ចុប្បន្នដឹកនាំដោយលោក Hong Nam-ki បានកំណត់គោលនយោបាយនៃការផ្តល់ប្រាក់កម្ចី ODA និងគ្រប់គ្រងវិភាគទានដល់ធនាគារអភិវឌ្ឍន៍ពហុភាគី។ វាក៏គ្រប់គ្រងផងដែរនូវ មូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កូរ៉េខាងត្បូង (EDCF) ដែលផ្តល់ប្រាក់កម្ចីទ្វេភាគី និងមានធនាគារនីហារ៍ណែអាហារ៍ណេកូរ៉េ (Korea Eximbank) ដែលជាអ្នកអនុវត្តវា។ លើសពីនេះទៀត MOSF ជាអ្នកកំណត់ថវិកាជាតិ ហើយការិយាល័យថវិការបស់វា អាចបដិសេធការផ្តល់ជំនួយឥតសំណង និងប្រាក់កម្ចីរបស់ក្រសួង ដែលមិនទាន់បានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការអនុម័តគម្រោង។ ក្នុង MOSFអគ្គនាយកបច្ចុប្បន្ន Yook Tae Sikទទួលខុសត្រូវការិយាល័យហិរញ្ញវត្ថុអភិវឌ្ឍន៍។
- **KOICA** គឺជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍។ KOICA ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩១ ហើយវាទទួលខុសត្រូវ ក្នុងការផ្តល់ជំនួយឥតសំណងទ្វេភាគី និងកិច្ចសហប្រតិបត្តិការបច្ចេកទេស។

- EDCF ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៧ ក្នុងគោលបំណងជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងប្រទេសកូរ៉េខាងត្បូង និងបណ្តាប្រទេសជាដៃគូ តាមរយៈកម្ចី។ ចំណែកឯទិសដៅប្រតិបត្តិការរបស់ EDCF និងការទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយ MOSF។ Korea Eximbank ជាអ្នកគ្រប់គ្រងផងនិងអនុវត្តកម្ចីរបស់ EDCFផង។ Korea Eximbank ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៦ ដើម្បីទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូង តាមរយៈការនាំចេញ-ចូល និងគម្រោងវិនិយោគបរទេស។ គោលដៅវាមាន ការលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ការអភិវឌ្ឍយុទ្ធសាស្ត្រឧស្សាហកម្ម របស់ប្រទេសកូរ៉េខាងត្បូង និងការបង្រួបបង្រួមជាមួយកូរ៉េខាងជើង។

**សំគាល់** ៖ មន្ត្រីរដ្ឋាភិបាល មិនត្រូវបានអនុញ្ញាតឲ្យចូលរួមដោយស្របច្បាប់ជាមួយគណបក្សនយោបាយទេ។ ហេតុដូចនេះ រដ្ឋមន្ត្រីដែលធ្លាប់មានទំនាក់ទំនងជាមួយគណបក្ស ត្រូវចាកចេញពីគណបក្ស នៅពេលដែលពួកគេចូលមកក្នុងការិយាល័យរបស់រដ្ឋាភិបាល។

### ១.៤.៦. ដំណើរការនៃការអនុម័តថវិកាជាតិសំខាន់ៗប្រចាំឆ្នាំរបស់កូរ៉េ[12]

គ្រប់កម្រិត ODA ទាំងអស់ត្រូវបានកំណត់ដោយក្រសួងយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ នៅចន្លោះខែ មករា និងមេសា។ ការបែងចែកជាក់លាក់ ត្រូវបានធ្វើនៅចន្លោះខែ កក្កដា និងតុលា។ ក្រសួងយុទ្ធសាស្ត្រនិងហិរញ្ញវត្ថុ (MOSF) បានបង្កើតគោលការណ៍ណែនាំថវិកា ជាមួយនឹងការកំណត់ចំណាយសម្រាប់ក្រសួងនីមួយៗ។

- **ការដាក់ផែនការហិរញ្ញវត្ថុរយៈពេលមធ្យមរបស់ក្រសួង** ៖ រហូតដល់ដំណាច់ខែមករា ក្រសួងនីមួយៗ ត្រូវដាក់ជូនផែនការចំណាយរយៈពេលមធ្យមរបស់ខ្លួនទៅកាន់ ក្រសួងយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ (MOSF)។ នៅលើមូលដ្ឋាននេះ MOSF មានតួនាទីរៀបចំទៅលើគោលការណ៍ណែនាំថវិការួមទាំងដែនកំណត់ចំណាយសម្រាប់ក្រសួងនីមួយៗ។
- **ការបង្កើតថវិការបស់ក្រសួង** ៖ ចន្លោះខែឧសភា និងខែមិថុនា ក្រសួងនានាត្រូវរៀបចំថវិការបស់ខ្លួនសម្រាប់ឆ្នាំខាងមុខ ដោយផ្អែកលើការកំណត់ដោយ MOSF។ នៅក្នុងដំណាក់កាលនេះក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងការបរទេស បានបង្កើតសំណើក្នុងការបែងចែកជំនួយអភិវឌ្ឍន៍តាមវិស័យនិងភូមិសាស្ត្រ។ អ្នកពាក់ព័ន្ធសំខាន់មានរដ្ឋមន្ត្រីនៃក្រសួងនានា មានតួនាទីបញ្ជូនថវិការបស់ក្រសួងដើម្បីពិនិត្យឡើងវិញក្នុងខែមិថុនា។

[12] https://donortracker.org/country/south-korea (ចូលទស្សនាថ្ងៃទី ៣០ មីនា ២០១៩)

- **ការពិភាក្សាការបែងចែករបស់ CIDC** ៖ ចន្លោះខែកក្កដា និងកញ្ញា ក្រសួងដែលមានតួនាទីក្នុងការបែងចែក ODA បានចរចារការបែងចែកជំនួយតាមវិស័យ និងតាមភូមិសាស្ត្ររបស់ពួកគេ។ ដំណើរការនេះត្រូវបានដឹកនាំដោយ គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (CIDC)។ វារួមបញ្ចូលទាំងការពិគ្រោះយោបល់របស់អ្នកជំនាញបន្ទាប់មកការពិនិត្យឡើងវិញដោយគណៈរដ្ឋមន្ត្រី។
- **ការដាក់ចេញនូវសេចក្តីព្រាងថវិការបស់រដ្ឋាភិបាល** ៖ នៅដើមខែកញ្ញា រដ្ឋាភិបាលអាចដាក់ជូនសេចក្តីព្រាងថវិកាខ្លួនដល់សភា (សភាជាតិ) ដើម្បីពិភាក្សា កែប្រែ និងអនុម័ត។ នៅពេលដែលថវិកាត្រូវបានដាក់បញ្ចូល គណៈកម្មាធិការក្នុងរដ្ឋសភាត្រូវពិនិត្យឡើងវិញនូវសេចក្តីព្រាងថវិកា។ គណៈកម្មការកិច្ចការបរទេសនិងបង្រួបបង្រួម ទទួលខុសត្រូវចំពោះថវិកាODA។ បន្ទាប់ពីពិនិត្យមើលឡើងវិញ គណៈកម្មាធិការទទួលបន្ទុកពិសេសលើថវិកា និងគណនេយ្យ ត្រូវធ្វើការពិនិត្យឡើងវិញនូវសេចក្តីព្រាងថវិកា។
- **រដ្ឋសភាអនុម័តថវិកា** ៖ ក្នុងខែធ្នូ រដ្ឋសភានឹងបោះឆ្នោតលើគម្រោងថវិកា ODA នៅក្នុងកិច្ចប្រជុំសម័យពេញអង្គ។

## ១.៥. ប្រវត្តិវិស័យអប់រំនៅកម្ពុជាក្រោយឆ្នាំ ១៩៧៩

ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាសំខាន់មួយ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា ក្នុងការកសាងនិងអភិវឌ្ឍន៍ ទាំងសកម្មភាពសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ជាតិ ឲ្យមានការរីកចម្រើន ជឿនលឿនយ៉ាងឆាប់រហ័ស។ ក៏ប៉ុន្តែអ្វីដែលគួរឲ្យសោកស្តាយនោះគឺ ក្នុងអំឡុងពេលរបបខ្មែរក្រហម ការអប់រំដែលធ្លាប់តែមានការរីកចំរើនបានថយចុះ ការសិក្សាអប់រំអំឡុងពេលពីរទសវត្សរ៍ក្រោយទទួលបានឯករាជ្យពីបារាំងកាលឆ្នាំ១៩៦៣ គឺត្រូវបានលុបបំបាត់ប្រព័ន្ធអប់រំចោល។ សាលារៀនត្រូវបានបិទ មនុស្សម្នា រួមទាំងគ្រូបង្រៀន គឺត្រូវបានបង្ខំឲ្យធ្វើការងារស្រែចំការ ដែលត្រូវបានគ្រប់គ្រងយ៉ាងព្រៃផ្សៃបំផុត រហូតដល់មានការកាប់សម្លាប់ផង។ ជាក់ស្តែង នៅដើមសតវត្សរ៍ឆ្នាំ១៩៧០ នៅក្នុងប្រទេសកម្ពុជាមានគ្រូបង្រៀនជាង ២ ម៉ឺននាក់ ផ្ទុយទៅវិញ ១០ឆ្នាំក្រោយ គ្រូបង្រៀនប្រមាណជា ៥ពាន់នាក់ប៉ុណ្ណោះដែលនៅរស់មានជីវិត។ បើយោងតាមឯកសារសូវៀតបានរាយការណ៍ថា ៩០%នៃគ្រូបង្រៀនទាំងអស់ ត្រូវបានសម្លាប់ក្រោមរបបខ្មែរក្រហម។ សាស្ត្រាចារ្យសាកលវិទ្យាល័យ ៥០នាក់ក្នុងចំណោម ៧២៥នាក់ គ្រូបង្រៀនអនុវិទ្យាល័យ ២០៧នាក់ក្នុងចំណោម ២ ៣០០នាក់ និង គ្រូបឋម ២ ៧១៧នាក់ក្នុងចំណោម ២១ ៣១១នាក់បាននៅមានជីវិត។ ក្នុងចំណោមនិស្សិត ១១ ០០០នាក់ មានតែ ៤៥០

នាក់ដែលរកឃើញ ហើយក្នុងចំណោមសិស្សមធ្យមសិក្សា ១០៦ ០០០នាក់ នៅរស់រានមានជីវិតតែ ៥ ៣០០នាក់ប៉ុណ្ណោះ។ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម ប្រពន្ធ័អប់រំបានងើបឡើងវិញបន្តិចម្តងៗ ដោយចាប់ផ្តើមពីគ្មានអ្វីទាំងអស់។ ពេលនោះ ភាពមិនចេះអក្សរបានកើនឡើងជាង ៤០ភាគរយ ហើយភាគច្រើននៃក្មេងមានអាយុក្រោម ១៤ឆ្នាំ បានខ្វះខាតមូលដ្ឋានការអប់រំ។[13]

ដោយសារតែការបាត់បង់ធនធានមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ក្នុងសម័យនោះហើយ ទើបធ្វើឲ្យកម្ពុជាខ្វះខាតអ្នកដែលមានចំណេះដឹងដើម្បីកសាងប្រទេសឲ្យមានការលូតលាស់។ ក៏ប៉ុន្តែនាពេលបច្ចុប្បន្នប្រមុខរាជរដ្ឋាភិបាល មានការយល់ចិត្តទុកដាក់យ៉ាងខ្ពស់នៅក្នុងការលើកកម្ពស់ការអប់រំនៅកម្ពុជា ដោយយកបញ្ហាអប់រំនេះជាចំណែកមួយក្នុងចំណោមយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤"។[14] ទន្ទឹមនឹងនេះ វិស័យមួយនេះក្នុងពេលបច្ចុប្បន្នត្រូវបានធ្វើកំណែទម្រង់និងមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជារហូតដល់មានការចំណាយថវិកាច្រើនបំផុតចាប់ពីឆ្នាំ ២០១៣ រហូតដល់ឆ្នាំ ២០១៨។ ជាការពិតណាស់ ការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលតែម្ខាងពិតមិនគ្រប់គ្រាន់ទេ ដើម្បីអភិវឌ្ឍន៍វិស័យអប់រំនៅកម្ពុជា ទាមទារការសហការជាមួយដៃគូអភិវឌ្ឍន៍ និងប្រទេសដែលអនុវត្តស្តង់ដាអប់រំកម្រិតខ្ពស់ តាមរយៈការផ្តល់អាហារូបករណ៍ដល់សិស្សនិងនិស្សិតកម្ពុជា ទៅសិក្សានៅបរទេស ការផ្តល់ជំនួយគាំទ្រលើវិស័យអប់រំ ការផ្សព្វផ្សាយដល់សាធារណៈជនពីសារៈប្រយោជន៍នៃការសិក្សា។ ហេតុដូចនេះហើយ ការអភិវឌ្ឍវិស័យអប់រំទៅបានលុះត្រាតែមានការសហការជាមួយនឹងដៃគូអភិវឌ្ឍន៍នានា ស្ថាប័នអន្តរជាតិដែលធ្វើការទាក់ទងនឹងការអប់រំ និងប្រទេសជាម្ចាស់ជំនួយផ្សេងទៀត ដើម្បីផ្តល់ជំនួយក្នុងវិស័យមួយនេះ។

## ១.៦. យុទ្ធសាស្ត្រពង្រឹងគុណភាពអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជា[15]

ក្នុងអណត្តិទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយបានចាត់ទុក ការអភិវឌ្ឍធនធានមនុស្ស ជាអាទិភាពទី១។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានប្តេជ្ញាចិត្តថានឹងសម្រេចឲ្យបាននូវមុំទី១ស្តីពី "ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" ដែលផ្តល់អាទិភាពលើ ៧ ចំណុចសំខាន់ដូចខាងក្រោម ៖

[13] Russel R. Ross, កែសម្រួល. *Education: Cambodia* [ការអប់រំ៖ កម្ពុជា] (Washington, DC: Federal Research Division, 1987)

[14] សម្ព័ន្ធមុំបួននៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ឧបសម្ព័ន្ធទី២

[15] រាជរដ្ឋាភិបាលកម្ពុជា. *យុទ្ធសាស្ត្រចតុកោណ៖ ដំណាក់កាលទី ៤.* ២០១៨.ទំព័រទី ២២-២៣

ទី១- **ការយកចិត្តទុកដាក់លើគ្រូបង្រៀន** ៖ ការបន្តដំឡើងបៀវត្ស និងប្រាក់លើកទឹកចិត្ត ផ្អែកតាមសមិទ្ធកម្មជូនគ្រូបង្រៀន និងបុគ្គលិកអប់រំ ការលើកកម្ពស់សមត្ថភាពគ្រប់គ្រង របស់នាយកសាលាដោយផ្សារភ្ជាប់ទៅនឹងថវិកាសាលារៀន រួមទាំងការបន្តលើកកម្ពស់ គុណវុឌ្ឍិគ្រូបង្រៀន សមត្ថភាពបង្រៀន និងគន្លងអាជីពគ្រូបង្រៀន ដោយបង្កើនការ បណ្តុះបណ្តាល និងរឹតត្បិតការគ្រូបង្រៀនយ៉ាងតិចកម្រិតបរិញ្ញាបត្រ ការពង្រាយគ្រូ បង្រៀនសមត្ថភាពខ្ពស់ទៅតំបន់ខ្វះគ្រូបង្រៀន និងបង្កើតយន្តការជួយសិស្ស ដែលរៀន ខ្សោយ ដោយលើកទឹកចិត្តតាមការជាក់ស្តែង ការស្រាវជ្រាវ និងការអភិវឌ្ឍវិធីសាស្ត្រ បង្រៀន និងរៀនតាមបែបថ្មី ការបន្តអនុវត្តការកែទម្រង់ការប្រឡង និងវាយតម្លៃការ សិក្សាឲ្យបានជាទៀងទាត់ ការបង្កើតការវិនិយោគលើសម្ភារសិក្សា ឧបករណ៍ពិសោធន៍ និងបរិក្ខារបង្រៀន ពិសេសពង្រីកវិសាលភាពសាលារៀនជំនាន់ថ្មី និងលើកកម្ពស់ការ ចូលរួមពីសហគមន៍ និងមាតាបិតាសិស្ស។

ទី២- **ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត** ៖ បន្តការវិនិយោគលើការសាងសង់ សាលាបឋមសិក្សាឲ្យបានដល់ភូមិ និងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំតាមការចាំបាច់ផ្អែក លើស្ថានភាពសេដ្ឋកិច្ចនិងសង្គម ការផ្តល់អាហារូបករណ៍ និងមធ្យោបាយទ្រទ្រង់ ចាំបាច់ផ្សេងទៀតដល់សិស្សក្រីក្រ សិស្សនៅតំបន់ជួបការលំបាក និងសិស្សពិការភាព ការរៀបចំយុទ្ធនាការផ្សព្វផ្សាយនៅទូទាំងប្រទេស ពីសារៈប្រយោជន៍នៃការអប់រំកម្រិត មូលដ្ឋាន ការបង្កើនការវិនិយោគដើម្បីអភិវឌ្ឍន៍កុមារតូច និងការបន្តបង្កើតថ្នាក់មត្តេយ្យ សិក្សាគ្រប់រូបភាព ព្រមទាំងជំរុញការរៀបចំឲ្យមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមដាន ព័ត៌មានសិស្ស សំដៅផ្តល់កិច្ចអន្តរាគមន៍ឲ្យទាន់ពេលវេលាតាមគ្រប់មធ្យោបាយ ដើម្បី ទប់ស្កាត់នូវការបោះបង់ការសិក្សារបស់សិស្ស។

ទី៣- **ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលា** ៖ សំដៅធានាការ បង្រៀនឲ្យបានពេញលេញទៅតាមកម្មវិធីសិក្សា និងបង្កើនគុណភាពអភិបាលកិច្ច សាលា ដោយរៀបចំឲ្យមានយន្តការចូលរួមជាប្រចាំពីអ្នកពាក់ព័ន្ធ និងបង្កើតប្រអប់ ទទួលព័ត៌មាន រៀបចំប្រព័ន្ធពិនិត្យតាមដានដំណើរការសាលា ព្រមទាំងរៀបចំប្រព័ន្ធ ឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាពីកម្រិតជាតិ។ ទន្ទឹមនឹងនេះ ការ ពិនិត្យឡើងវិញ និងការពង្រឹងតួនាទីនៃយន្តការត្រួតពិនិត្យគុណភាពអប់រំនៅគ្រឹះស្ថាន សិក្សាចំណោះទូទៅ ក៏នឹងត្រូវបានយកចិត្តទុកដាក់ផងដែរ។

ទី៤- **ការពង្រឹងការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ** ៖ សំដៅបង្កើនការតម្រង់ទិសការសិក្សាទៅកាន់អាជីព និងពង្រីកការអប់រំបច្ចេកទេសឲ្យមានវិសាលភាពគ្របដណ្ដប់ទូទាំងប្រទេសតាមទស្សនទាន "ខេត្តមួយ មានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិច សម្រាប់រយៈពេលមធ្យម និងស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលវែង" ព្រមទាំងលើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជន ជាពិសេសតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។

ទី៥- **ការអប់រំបំណិនជីវិតឲ្យស្របតាមទីផ្សារការងារ** ៖ ការបង្កើនភាពឆ្លើយតបឲ្យកាន់តែពេញលេញនៃការអប់រំទៅនឹងទីផ្សារការងារ ព្រមទាំងការរស់នៅ តាមរយៈទស្សនទាន "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត" ដោយរៀបចំជាកម្មវិធីបង្កើនគំនិតសហគ្រិនភាព និងភាសាបរទេស ពង្រឹងការអប់រំផ្នែកSTEM ដោយបង្កើតឲ្យមានមជ្ឈមណ្ឌលអប់រំ និងវិទ្យាសាស្ត្រ បន្តជំរុញកម្មវិធីបំណិនជីវិត ពិសេសកម្មវិធីយុវជនក្នុងភាពជាអ្នកដឹកនាំ សីលធម៌និងសុជីវធម៌រស់នៅ ការចូលរួមការងារសង្គម បរិស្ថាន និងការអភិវឌ្ឍ ព្រមទាំងបន្តបង្កើតក្រុមប្រឹក្សាកុមារនិងយុវជនឲ្យបានគ្រប់សាលារៀន។

ទី៦- **ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ** ៖ ការរៀបចំក្របខណ្ឌកម្មវិធីសិក្សាគោលគ្រប់ជ្រុងជ្រោយ រួមទាំងការបញ្ចូល STEM និងវិទ្យាសាស្ត្រសង្គមគន្លឹះៗសម្រាប់ឧត្តមសិក្សាស្របទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដារតំបន់ និងអន្តរជាតិ ការពង្រឹងយន្តការទទួលស្គាល់គុណភាពថ្នាក់ឧត្តមសិក្សា ការបង្កើនចំនួនសាស្ត្រាចារ្យកម្រិតបណ្ឌិតប្រកបដោយគុណភាពនៅឧត្តមសិក្សា បង្កើនការវិនិយោគនៅឧត្តមសិក្សា និងការបង្កើតក្របខណ្ឌគោលនយោបាយជាតិ សំដៅអភិវឌ្ឍន៍មូលនិធិអាហារូបករណ៍ និងឥណទានសម្រាប់និស្សិតនៅឧត្តមសិក្សា ការជំរុញដល់ការអភិវឌ្ឍសមត្ថភាពនិងធនធានសម្រាប់គាំទ្រការរៀន ការបង្រៀន និងការស្រាវជ្រាវ ការបង្កើតមូលនិធិសិក្សាស្រាវជ្រាវ និងយន្តការលើកទឹកចិត្តការប្រកួតប្រជែងស្នាដៃ ព្រមទាំងការបង្កើតក្របខណ្ឌគោលនយោបាយជាតិស្តីពីអភិបាលកិច្ច និងការគ្រប់គ្រងឧត្តមសិក្សា។

ទី៧- **ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣** ៖ ដោយបន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធកីឡា សំខាន់ៗ រៀបចំប្រភេទកីឡាអាទិភាព បណ្ដុះបណ្ដាលគ្រូបង្វឹក និងបច្ចេកទេសកីឡាកម្រិតខ្ពស់ ពង្រឹងការបណ្ដុះបណ្ដាលនិងការហ្វឹកហាត់កីឡាករ-កីឡាការនីថ្នាល

និងជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត" និងរៀបចំឲ្យមានវិទ្យាសាស្ត្រសុខាភិបាលកីឡា ដើម្បីគាំទ្រដំណើរការប្រកួតកីឡាស៊ីហ្គេម។

## ១.៧. គោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា[16]

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៩៦ ដោយអមជាមួយនឹងចក្ខុវិស័យគឺ កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជា ឲ្យក្លាយជាសង្គម រីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ ចំណែកឯង វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺការអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្តុះស្មារតីយុវជន-យុវតីកម្ពុជាគ្រប់រូបឲ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។ ដើម្បីសម្រេចបានតាមចក្ខុវិស័យ ក៏ដូចជាវត្ថុបំណងខាងលើ ក្រសួងមាន បេសកកម្ម ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍន៍លើវិស័យអប់រំដោយខ្លួនឯង តាមរយៈការកំណត់គោលនយោបាយបន្ថែមចំនួន ៣ ដូចជា៖

- **គោលនយោបាយទី ១ ៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌។ កុមារគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សាទុតិយភូមិ និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលពុំមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធ ជម្រើសផ្សេងទៀតនឹងត្រូវផ្តល់លទ្ធភាពឲ្យអ្នកទាំងនោះទទួលបានការអប់រំ។ ការបង្កើនចំនួនកុមារនិងយុវជន ឲ្យទទួលបានការអប់រំនៅគ្រប់កម្រិត ដោយផ្តោតលើសមធម៌ តំបន់និងក្រុមកុមារជួបការលំបាក។ ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់ទី១២ ឲ្យទទួលបាននូវចំណេះដឹងនិងជំនាញនៅក្នុងការគិត និងការស្វែងយល់ពីហេតុផល និងអាចជាមូលដ្ឋានសម្រាប់បន្តការសិក្សានៅក្នុងការបណ្តុះបណ្តាល បច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។
- **គោលនយោបាយទី ២ ៖** លើកកម្ពស់នូវគុណភាព និងភាពឆ្លើយតប។ កុមារនិងយុវជនគ្រប់ៗរូបទទួលបានការអប់រំដែលមានភាពពាក់ព័ន្ធ និងប្រកបដោយគុណភាពខ្ពស់ដែលអាចឲ្យពួកគេអាចចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។ ការធានាថា ការអប់រំប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគម

[16] https://www.moeys.gov.kh/index.php/kh/about-us.html#.XPosQNIzbIU (ចូលទស្សនាថ្ងៃទី ៦ មិថុនា ២០១៩)

ន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាមួយស្តង់ដារនៃផលសម្រេច ការពិនិត្យតាមដាន និងរបាយការណ៍។

– **គោលនយោបាយទី ៣ ៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ការផ្តល់សេវាអប់រំ ប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងវិជ្ជាជីវៈ និងផ្តល់តម្លៃល្អបំផុត(ផ្តោតលើលទ្ធផល) ទាន់ពេលវេលា ពាក់ព័ន្ធនឹងការពិនិត្យតាមដាន និងរបាយការណ៍នៃលទ្ធផលទាំងនោះ ជាមួយនឹងយោបល់ត្រឡប់ និងយន្តការសម្រាប់កែលម្អគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធី។

## ១.៨. បញ្ហាប្រឈម និងដំណោះស្រាយក្នុងវិស័យអប់រំកម្ពុជា

### ១.៨.១. បញ្ហាប្រឈម[17]

បញ្ហាប្រឈមក្នុងប្រព័ន្ធអប់រំនៅកម្ពុជា បាននាំឲ្យមានការរាំងស្ទះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយនេះយ៉ាងខ្លាំង។ ខាងក្រោមនេះ គឺជាបញ្ហាប្រឈមក្នុងប្រព័ន្ធអប់រំកម្ពុជា ដែលបាននិងកំពុងកើតមាន ខណៈពេលដែលរាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធនានា រួមទាំងដៃគូអភិវឌ្ឍន៍ផងនោះ បាននិងកំពុងខិតខំដោះស្រាយក្នុងគោលបំណង ធ្វើយ៉ាងណាឲ្យឈានដល់ចំណុចគោលដៅដែលបានកំណត់។

#### ១.៨.១.១. បញ្ហាពាក់ព័ន្ធនឹងគ្រូបង្រៀន

##### ក. គុណភាពគ្រូបង្រៀន

ការអភិវឌ្ឍការអប់រំនៅកម្ពុជា ប្រឈមនឹងការខ្វះខាតគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលប្រកបដោយគុណភាព។ បើយោងតាមការស្រាវជ្រាវមួយ បានរកឃើញថាគ្រូបង្រៀនមួយចំនួន មិនទាន់ទទួលបានឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យនៅឡើយ។ គ្រូបង្រៀនថ្នាក់មធ្យមសិក្សាទុតិយភូមិប្រហែល៩០%ប៉ុណ្ណោះ ដែលមានសញ្ញាបត្រយ៉ាងទាបត្រឹមបរិញ្ញាបត្រ និងគ្រូកម្រិតមធ្យមសិក្សាបឋមភូមិ មានសញ្ញាបត្រយ៉ាងហោចត្រឹម មធ្យមសិក្សាទុតិយភូមិ។ លើសពីនេះទៅទៀត មានមន្ត្រីរាជការមួយចំនួនតូច ដែលមានសញ្ញាបត្របណ្ឌិត ក៏ប៉ុន្តែពួកគាត់ផ្សេងទៀតគ្រាន់តែបានបញ្ចប់ថ្នាក់បឋមសិក្សាឬមិនទាន់បញ្ចប់ផងនោះ។ ផ្ទុយទៅ

[17] ក្រសួងអប់រំ យុវជន និងកីឡា, *សន្និបាត អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៤-២០១៦* (ភ្នំពេញ៖ MoEYS, ២០១៦), ទំព័រទី ១១០-១១២។

វិញ សម្រាប់ការហ្វឹកហាត់ និងបណ្តុះបណ្តាលគ្រូបង្រៀនបន្ថែម នៅនឹងកន្លែងលើកទី២ ហាក់នៅមិនទាន់មានលក្ខណៈសមស្របនៅឡើយ។[18]

**ខ. ការធ្វើរបាយគ្រូបង្រៀន**

តាំងពីថ្នាក់មត្តេយ្យសិក្សា រហូតដល់មធ្យមសិក្សា រដ្ឋមានការខ្វះខាតធនធានគ្រូបង្រៀន ជាពិសេសនៅតាមតំបន់ជនបទ មិនមានគ្រូបង្រៀនថ្នាក់បឋមសិក្សានិងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រប់គ្រាន់ ដែលជាបញ្ហាចម្បងបានលេចឡើងពេលនេះ។ គ្រូបង្រៀនមួយចំនួនធំមានបំណងចង់តែមកបង្រៀននៅក្នុងទីប្រជុំជន និងទីក្រុង បើទោះបីជានៅតាមបណ្តាសាលារៀនក្នុងតំបន់នោះ មានភាពលើសនៃចំនួនគ្រូហើយក៏ដោយ។ នេះព្រោះតែសិស្សតំបន់នោះរស់នៅក្នុងជីវភាពធូរធារ ដែលអាចផ្តល់ឱកាសពួកគាត់ រកចំណូលបន្ថែមបានតាមរយៈការបង្រៀនបំប៉នក្រៅម៉ោង។ បច្ចុប្បន្ននេះ នៅមិនទាន់មានគោលនយោបាយណាមួយជាក់លាក់ មានឥទ្ធិពលទាក់ទាញបេក្ខជនដែលមានសមត្ថភាពខ្ពស់ ឲ្យចូលបម្រើវិជ្ជាជីវៈគ្រូបង្រៀននៅឡើយទេ។

**គ. គ្រូបង្រៀនបច្ចេកទេស**

ក្នុងបរិបទសមាហរណកម្មអាស៊ាននេះ ចំណេះដឹងភាសាសម្រាប់ទំនាក់ទំនង និងការអប់រំបំណិនជីវិតជាដើម ពិតជាមានសារៈសំខាន់ណាស់សម្រាប់ជាមាគ៌ាឆ្ពោះទៅរកការប្រកួតប្រជែងក្នុងទីផ្សារការងារ។ ផ្ទុយទៅវិញ បច្ចុប្បន្ននេះនៅតាមបឋមសិក្សារដ្ឋ កំពុងប្រឈមកង្វះគ្រូបង្រៀនដែលមានសមត្ថភាពឯកទេសភាសាបរទេស និងគ្រូឯកទេស សម្រាប់អនុវត្តន៍មុខវិជ្ជាអប់រំបច្ចេកទេស និងបំណិនជីវិត ហើយវាក៏បានក្លាយជាការរាំងស្ទះមួយក្នុងប្រព័ន្ធអប់រំក្នុងប្រទេសទាំងមូលដែរ។

**១.៨.១.២. បញ្ហាសមត្ថភាពបុគ្គលិកក្នុងស្ថាប័នអប់រំ**

នៅក្នុងស្ថាប័នអប់រំ មានមន្ត្រីមួយចំនួន ដែលមានការយល់ដឹងនៅមានកម្រិត ជាពិសេសពាក់ព័ន្ធនឹងភាពជាអ្នកដឹកនាំ គ្រប់គ្រង និងការធ្វើផែនការស្រាវជ្រាវ ភាសាបរទេស ហើយនិងបច្ចេកវិទ្យាគមនាគមន៍។ បន្ថែមលើបញ្ហានេះ ទាក់ទងនឹងគុណវុឌ្ឍិសាស្ត្រាចារ្យ និងសមត្ថភាពមន្ត្រីគ្រប់គ្រង គឺនៅមានកម្រិត ហើយគ្រឹះស្ថានឧត្តមសិក្សាភាគច្រើន មិនទាន់បានយកចិត្តទុកដាក់លើការងារស្រាវជ្រាវនៅឡើយទេ។ បើពិនិត្យមើលលើធនធានសាស្ត្រាចារ្យ និងមូលដ្ឋានសម្ភារ ហាក់មិនទាន់សមាមាត្រទៅនឹងចំនួនសិស្សនៅឡើយទេនាពេលបច្ចុប្បន្ន។ បញ្ហាកង្វះ

[18] Pen Vithyda, "Overview of Education in Cambodia: Educationo System and Challenges," (បទបង្ហាញក្នុងកម្មវិធីចែករំលែកចំណេះដឹង (KPS), ការិយាល័យ KOICA ប្រចាំកម្ពុជា, ០១ មិនា ២០១៨) ។

មន្ត្រីជំនាញដើម្បីរៀបចំក្របខណ្ឌកម្មវិធីសិក្សា ប្រព័ន្ធវីក្រឹតការទៀតទាត់សម្រាប់គ្រូបង្រៀននៅមិនទាន់បានអនុវត្តន៍ពេញលេញនៅឡើយ ចំពោះសមត្ថភាពចំណេះដឹងនិងវិធីសាស្ត្របង្រៀនរបស់គ្រូឧទ្ទេសវិញគឺនៅមានកម្រិត ហើយមន្ត្រីជំនាញផ្នែកបច្ចេកទេសវេជ្ជសាស្ត្រក៏មានតិចតួច រីឯមន្ត្រីអធិការកិច្ចមិនទាន់បានបណ្តុះបណ្តាលតាមបែបផែនថ្មីគ្រប់កម្រិតសិក្សានៅឡើយទេ។

**១.៨.១.៣. បញ្ហាការគ្រប់គ្រង**

ទិដ្ឋភាពជាទូទៅក្នុងអង្គភាព និងស្ថាប័នអប់រំនៅកម្ពុជាមួយចំនួនធំ នៅពុំទាន់បានអនុវត្តន៍ផែនការបានពេញលេញតាមការគ្រោងទុកនៅឡើយ។ គេសង្កេតឃើញថា ការបើកផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ និងការផ្តល់គ្រឿងឥស្សរិយយសការងារជូនមន្ត្រីអប់រំនៅខេត្តមួយចំនួននៅមិនទាន់កាលកំណត់នោះទេ។ ចំណែកឯបញ្ហាលើគ្រប់គ្រងរដ្ឋបាល ការទទួលខុសត្រូវរបស់អង្គភាព ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិ ក៏នៅមានកម្រិតទាបនៅឡើយ។ លើសពីនេះ ការស្វែងយល់ពីការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ពីសំណាក់មន្ត្រីដែលមានការពាក់ព័ន្ធ ហាក់នៅមិនទាន់ច្បាស់លាស់ ជាហេតុធ្វើឲ្យការរៀបចំនីតិវិធីក្នុងការផ្ទេរមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពន្យាពេល និងនាំឲ្យរដ្ឋបាលថ្នាក់ក្រោមទាំងនោះ ខកខានក្នុងទទួលការរៀនសូត្រតាមរយៈបទពិសោធការងារនោះ។ ចំណែកឯនីតិវិធីរដ្ឋបាលវិញ ការចម្លងឯកសារហិរញ្ញវត្ថុ និងការយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា របស់មន្ត្រីអប់រំមួយចំនួននៅមានកម្រិតទាបនៅឡើយ។

**១.៨.១.៤. បញ្ហាទាក់ទងនឹងសាលារៀន**

**ក. សម្ភារនិងឧបករណ៍សិក្សា**

នៅក្នុងចំណុចនេះដែរ សាលារៀនមួយចំនួន នៅមានការខ្វះខាតសម្ភារសិក្សា ដែលជាតម្រូវការចាំបាច់សម្រាប់សិស្សានុសិស្ស ហើយចំពោះការប្រើប្រាស់សម្ភារបច្ចេកទេស ព័ត៌មាន និងមន្ទីរពិសោធន៍ក្នុងការបង្រៀនវិញ ក៏នៅមានកម្រិតផងដែរ។ ជាពិសេស គេសង្កេតឃើញថា នៅតំបន់ដាច់ស្រយាល នៅមានភាពខ្វះខាតយ៉ាងខ្លាំងនូវ សៀវភៅ និងសម្ភារសិក្សា និងបង្រៀន ដែលជាហេតុនាំឲ្យការសិក្សារបស់សិស្សនៅមានកម្រិតទាប។

**ខ. បរិស្ថានសាលារៀន**

បរិស្ថានសាលារៀន ជាចំណុចមួយដែលទាមទារការយកចិត្តទុកដាក់ផងដែរ ដើម្បីជំរុញការលើកទឹកចិត្ត និងផ្តល់សុខុមាលភាពដល់សិស្ស ក៏ប៉ុន្តែគេសង្កេតឃើញថា បរិស្ថានសាលារៀនមួយចំនួននៅមានកម្រិតនៅឡើយ។ បរិយាកាសសិក្សា មិនតែងតែអនុគ្រោះដល់ការសិក្សា

របស់កុមារនោះទេ ដោយសារការអនុវត្តមិនសមរម្យនិងការថែទាំកន្លែងមិនសូវបានល្អ។ ការផ្តល់ទឹកស្អាត ប្រើប្រាស់បង្គន់អនាម័យ កន្លែងលាងដៃ និងការរក្សាអនាម័យក្នុងការអប់រំ គឺជាកត្តាកំណត់សំខាន់នៃការអប់រំប្រកបដោយគុណភាពនៅក្នុងសាលារៀន។ កុមារនៅក្នុងសាលារៀនដែលមិនមានទឹកស្អាតនិងអនាម័យគ្រប់គ្រាន់ ដែលនេះអាចងាយទទួលរងពីជំងឺរាគរូសនិងជំងឺឆ្លងផ្សេងៗ ដែលអាចបណ្តាលឲ្យពួកគេ មានបំណងមិនចង់ចូលរៀន និងអាចឈានដល់ការបោះបង់ចោលសាលារៀន។

**គ. តម្រូវការសាលារៀន**

នៅតាមទីជនបទ ជាពិសេសនៅតំបន់ដាច់ស្រយាល ភាគច្រើនមិនទាន់មានអាគារសិក្សាគ្រប់គ្រាន់សម្រាប់សិស្សនៅឡើយ។ បើទោះបីជា កន្លែងខ្លះមានអាគារសិក្សាក៏ដោយ ក៏វានៅតែជាបញ្ហាប្រឈមដដែល ព្រោះទីតាំងរបស់អាគារទាំងនោះស្ថិតនៅឆ្ងាយពីទីស្ថានរបស់សិស្ស នាំឲ្យពិបាកក្នុងការធ្វើដំណើរទៅដល់។ មួយវិញទៀត អាគារទាំងនោះ អាចមានសភាពទ្រុឌទ្រោមទៅហើយ ទាមទារការកែលម្អ ឬសាងសង់ឡើងវិញ។

**ឃ. បញ្ហាសម្ភាររូបវ័ន្ត**

សំណើរទាក់ទងនឹងសម្ភាររូបវ័ន្ត គឺនៅមិនទាន់គ្រប់គ្រាន់សម្រាប់មន្ត្រីអប់រំនៅឡើយ ក្នុងនោះរួមមាន កង្វះផ្ទះគ្រូស្នាក់នៅ និងអន្តេវាសិកដ្ឋានសិស្សតំបន់ជួបការលំបាក បើទោះបីជាមានក៏ភាគច្រើនសម្ភាររូបវ័ន្តផ្នែកអនាម័យ នៅមិនទាន់ឆ្លើយតបស្តង់ដាដែរ។ បើក្រលេកមើលលើប្រអប់សង្គ្រោះបឋមនៅតាមគ្រឹះស្ថានសិក្សាវិញ គឺនៅមានតិចតួច។ វិធានការណ៍ នៃតំហែទាំលើហេដ្ឋារចនាសម្ព័ន្ធតាមគ្រឹះស្ថានសិក្សានៅមានកម្រិត។ សម្ភារមួយចំនួន ត្រូវបានប្រើប្រាស់ដោយគ្មានការយកចិត្តទុកដាក់។ នៅតាមមន្ទីរអប់រំ យុវជន និងកីឡា តាមខេត្តមួយចំនួន នៅមិនទាន់មានទីតាំងសម្រាប់សាងសង់មជ្ឈមណ្ឌលយុវជន បើមាន ក៏ទីតាំងដីមជ្ឈមណ្ឌលយុវជនមួយចំនួនធំទាំងនេះ មិនទាន់មានរបងនិងសាងសង់អគារនៅឡើយដែរ។ ចំពោះលក្ខខណ្ឌបន្ទប់និងសម្ភារសម្រាប់អនុវត្តកម្មវិធីអប់រំបំណិនជីវិតវិញ នៅមានការខ្វះខាត ហើយអគារមានសភាពទ្រុឌទ្រោមដែលនៅមិនទាន់បានជួសជុលនៅឡើយ។

**ខ. ការអនុវត្តកម្មវិធីសិក្សាស្ថិតក្រោមស្តង់ដារ**

កម្មវិធីសិក្សានៅថ្នាក់ឧត្តមសិក្សា នៅមិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅឡើយ។ គួរជម្រាបផងដែរថា មាននិយោជកប្រហែល ៧៣% បានរាយការណ៍ថានិស្សិតបញ្ចប់ការសិក្សានៅកម្ពុជាមិនមានជំនាញត្រឹមត្រូវនោះទេ ហើយជាង ៦២% នៃនិយោជក

ទាំងនោះក៏បានកត់សម្គាល់ថា អ្នកដែលបញ្ចប់ការសិក្សាផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈមិនមានជំនាញច្បាស់លាស់នៅឡើយ។ លើសពីនេះ និយោជកចំនួន ៣១% បានលើកឡើងថាវាពិតជាពិបាកក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ជំនាញដែលមានស្រាប់របស់ពួកគេ។[19] ហេតុនេះ វាឆ្លុះបញ្ចាំងឲ្យឃើញពីកម្មវិធីបណ្តុះបណ្តាលនៅមានគុណភាពទាប ក៏ដូចជាជំនាញជាមូលដ្ឋានគ្រឹះភាពជានិយោជិករបស់ពួកគេនៅមានកម្រិត។

**ច. កង្វះការសហការពីភាគីដែលពាក់ព័ន្ធ**

ក្នុងដំណើរការបណ្តុះបណ្តាលសិស្សានុសិស្ស ការចូលរួមសហការជាមួយមន្ត្រីអប់រំនៅតាមបណ្តាសាលារៀន ជាពិសេសនៅតាមជនបទ ពីសំណាក់ភាគីដែលពាក់ព័ន្ធរួមមានសហគមក៏ដូចជាឪពុកម្តាយ ឬអាណាព្យាបាល ក្នុងការតាមដាន ត្រួតពិនិត្យ និងណែនាំ ពិតជាមានសារៈ-សំខាន់ណាស់ដើម្បីជំរុញការសិក្សាកូនៗ។ ក៏ប៉ុន្តែ ការណ៍ជាក់ស្តែងនាពេលបច្ចុប្បន្ន បានឆ្លុះបញ្ចាំងឲ្យឃើញថា ការចូលរួមក្នុងកិច្ចសហការមួយនេះ ហាក់នៅមានកម្រិតតិចតួច។

**ឆ. គ្មានការប្រឹក្សាការសិក្សាត្រឹមត្រូវ**

នៅតាមបណ្តាគ្រឹះស្ថានអប់រំ ជាពិសេសសាលារៀនសាធារណៈ គេសង្កេតឃើញថា ពុំមានផ្តល់ការប្រឹក្សាការងារ ដែលមានទំនាក់ទំនងនឹងការសិក្សា ឬឱកាសទទួលបានការអប់រំបន្ថែមទៀតសម្រាប់សិស្ស ដើម្បីឲ្យពួកគេអាចស្វែងយល់ពីដំណើរការសិក្សារបស់ខ្លួនត្រឹមត្រូវ និងអាចដឹងពីគុណសម្បត្តិនិងគុណវិបត្តិរបស់ខ្លួន រួមទាំងអាចឲ្យពួកគេមានឱកាសដើម្បីពង្រឹង និងពង្រីកសមត្ថភាពដែលខ្លួនមាននោះទេ ជាពិសេស ចាប់ពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់មធ្យមសិក្សានោះទេ។

**១.៨.២. ដំណោះស្រាយ**

ដើម្បីដោះស្រាយបញ្ហាលើកកម្ពស់គុណភាពអប់រំ អភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន និងកែសម្រួលសៀវភៅស្របទៅនឹងកម្មវិធីសិក្សាថ្មី គោលបំណងឆ្លើយតបគោលដៅប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់វិស័យអប់រំ ផ្តោតសំខាន់លើសសរស្តម្ភចំនួន ៥ ជាមូលដ្ឋាន[20]រួមមាន ៖

[19] Khieng Sothy, Srinivasa Madhur, និង Chhem Rethy, កែសម្រួល. *Cambodia Education 2015: Employment and Empowerment* (ភ្នំពេញ៖ CDRI, ២០១៥), ទំព័រទី ១០។

[20] ឯកឧត្តមសភាចារ្យ ហង់ ជួនណារ៉ុន, "របាយការណ៍បូកសរុបលទ្ធផល សន្និបាតអប់រំ យុវជន និងកីឡា," (បទបង្ហាញនៅក្នុងសន្និបាតអប់រំ, វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ២១ មិនា ២០១៨)។

**សសរស្តម្ភទី ១ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន**

- ការទាក់ទាញអ្នកមានសមត្ថភាពចូលធ្វើជាគ្រូបង្រៀន
- ការបណ្តុះបណ្តាលគ្រូបង្រៀន
- ការគ្រប់គ្រងគ្រូបង្រៀន
- ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន
- ពង្រឹងភាពជាអ្នកដឹកនាំសាលារៀន
- ការពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

**សសរស្តម្ភទី ២ ៖ ការពិនិត្យឡើងវិញ កម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា**

- បញ្ចប់ការអភិវឌ្ឍកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា គ្រប់ភូមិសិក្សា
- ពង្រឹងវិធីសាស្ត្រអំណាននិងវិធីសាស្ត្របង្រៀនលេខនព្វន្តនៅសាលាបឋមសិក្សា និងពង្រឹងវិធីសាស្ត្របង្រៀននៅតាមគ្រឹះស្ថានមធ្យមសិក្សា។
- ពង្រឹងវិធីសាស្ត្រសរសេរតែងសេចក្តី បឋមសិក្សាថ្នាក់ទី ៣ដល់ទី ៦និងមធ្យមសិក្សា
- បណ្តុះទម្លាប់អាននៅក្នុងថ្នាក់រៀននិងនៅក្នុងបណ្ណាល័យ ការប្រារព្ធទិវាជាតិអំណាន និងការកែលម្អបណ្ណាល័យនៅតាមគ្រឹះស្ថានសិក្សា។
- ជំរុញការអនុវត្តគោលនយោបាយអប់រំ STEM
- សាងសង់ជំនួស និងជួសជុលអាគារសិក្សាទ្រុឌទ្រោម រៀបចំទឹកស្អាត កន្លែងលាងដៃ និងបង្គន់អនាម័យ និងសាងសង់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ និងបន្ទប់កុំព្យូទ័រ។

**សសរស្តម្ភទី ៣ ៖ ការដាក់ឲ្យអនុវត្តអធិការកិច្ច**

- បន្តបណ្តុះបណ្តាលអធិការអប់រំបន្ថែម និងធ្វើអធិការកិច្ចតាមកាលកំណត់ នៅតាមគ្រឹះស្ថានសិក្សាទាំង ២៥ រាជធានី-ខេត្ត។
- ធ្វើអធិការកិច្ចតាមប្រធានបទសំខាន់ៗ ទាក់ទងនឹងកំណែទម្រង់អប់រំ។

**សសរស្តម្ភទី ៤ ៖ ការពង្រឹងវាយតម្លៃសិក្សាដូចជា ការប្រឡង វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ**

- បន្តពង្រឹងការប្រឡងគ្រប់ប្រភេទ ជាពិសេសទាំងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។

- ធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សាសិស្ស តេស្តវង្វាយតម្លៃថ្នាក់តំបន់កម្រិតបឋមសិក្សា តេស្តវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ។
- ការគាំទ្ររបស់នាយករដ្ឋមន្ត្រីកម្ពុជា ទាំងខាងស្មារតី អនុសាសន៍ល្អៗ សម្ភារនិងហិរញ្ញវត្ថុ ជាកត្តាកំណត់ ដែលធ្វើឲ្យកំណែទម្រង់ប្រឡងទទួលបានជោគជ័យ ដើម្បីឲ្យគ្រប់មជ្ឈដ្ឋានទាំងអស់គាំទ្រដល់ដំណើរការកំណែទម្រង់ និងការគាំទ្ររបស់សម្តេចតេជោ ក្នុងការតម្លើងប្រាក់បៀវត្ស ការសង់អគារសិក្សា និងផ្ទះគ្រូ កាន់តែជួយលើកទឹកចិត្តឲ្យលោកគ្រូ អ្នកគ្រូបន្តកំណែទម្រង់នេះកាន់តែខ្លាំងថែមទៀត។

**សសរស្តម្ភទី ៥ ៖ ការកែទម្រង់ឧត្តមសិក្សា**

- បញ្ចប់ការរៀបចំផែនការសកម្មភាពឧត្តមសិក្សា ២០១៨-២០២២
- បញ្ចប់ការរៀបចំសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុនៅគ្រឹះស្ថានឧត្តមសិក្សាស្វ័យភាពសាធារណៈ។
- បង្កើនធនធានមនុស្ស សម្រាប់ធ្វើដំណើរការបណ្តុះបណ្តាលលើជំនាញ វិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម សិល្បៈ ច្នៃប្រឌិត និងគណិតវិទ្យា ឆ្លើយតបនឹងការអនុវត្តគោល-នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥។
- បង្កើតមូលនិធិសម្រាប់ការស្រាវជ្រាវ
- ចុះវាយតម្លៃការទទួលស្គាល់គុណភាពអប់រំ តាមគ្រឹះស្ថានឧតម្តសិក្សាសាធារណៈ និងឯកជន និងពិនិត្យតាមដានលើការបណ្តុះបណ្តាលរបស់គ្រឹះស្ថាន។

បើទោះបីជាសសរស្តម្ភទាំង ៥ដែលជាគោលនយោបាយកំណែទម្រង់គុណភាពអប់រំ ជាចំណុចអាទិភាពល្អ ក៏ប៉ុន្តែដើម្បីសម្រេចបានគោលដៅ វាទាមទារការដោះស្រាយបញ្ហាមួយចំនួនជាមុនសិន ដូចជា៖

- ត្រូវបន្តពង្រឹងសមត្ថភាពដល់អ្នកអនុវត្តការងារបច្ចេកទេសពាក់ព័ន្ធ ដូចជា អ្នកអនុវត្តនៅក្រសួង មន្ទីរ ការិយាល័យអប់រំ ស្រុក និងសាលារៀនជាដើម ដើម្បីអនុវត្ត ការងារកម្មវិធីសិក្សានិងបច្ចេកទេស រួមទាំងការងារអធិការកិច្ចផងដែរ។
- ដោះស្រាយទំនាស់ផលប្រយោជន៍ ដែលជាឧបសគ្គធ្វើឲ្យកំណែទម្រង់មិនអាចឆ្ពោះទៅដល់គោលដៅ ដោយទាមទារឲ្យអ្នកគ្រប់គ្រង ហ៊ានធ្វើការសម្រេចចិត្តកាត់សេចក្តីលើបញ្ហាទំនាស់ផលប្រយោជន៍ ដើម្បីសម្រេចឲ្យបាននូវសកម្មភាពធ្វើកំណែទម្រង់។

- កាត់បន្ថយវិសមភាពអប់រំ ដោយ MoEYS ត្រូវជ្រើសរើសគ្រូជាប់កិច្ចសន្យាឲ្យបានច្រើន នឹងអាចជួយដល់កន្លែងដែលមានតម្រូវការបាន ហើយនិងត្រូវមានយន្តការ ពិសេស សម្រាប់គ្រូដែលត្រូវបង្រៀនកុមារពិការ កុមារជនជាតិ កុមារក្រីក្រនៅតំបន់ដាច់ស្រយាល ដោយមានការលើកទឹកចិត្តខ្ពស់ ដើម្បីឲ្យពួកគាត់ពេញចិត្តធ្វើការងារលំបាកអស់នេះ។

## ១.៩. ស្ថានភាពនៃទំនាក់ទំនងរវាងប្រទេសកម្ពុជា និងកូរ៉េ

ទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន និងកូរ៉េខាងត្បូងត្រូវបាន គេសង្កេតឃើញថាទើបតែបង្កើតឡើងកាលពីឆ្នាំ ១៩៩៧ តែប៉ុណ្ណោះ ក៏ប៉ុន្តែបើគេក្រឡេកទៅ មើលប្រវត្តិនៃទំនាក់ទំនងរបស់ប្រទេសទាំងពីរវិញ គេអាចដឹងបានថាវាមានតាំងពីយូរលង់ ណាស់មកហើយ។ តួយ៉ាងអំឡុងសង្គ្រាមកូរ៉េ (១៩៥០-១៩៥៣) ក្រោមក្របខណ្ឌអ.ស.ហ. ប្រចាំ នៅប្រទេសកម្ពុជា បានផ្តល់ជំនួយជាសម្ភារយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់ប្រជាជនកូរ៉េខាងត្បូង។ នាខែកក្កដា ឆ្នាំ១៩៦២ សាធារណរដ្ឋកូរ៉េក៏បានបង្កើតស្ថានកុងស៊ុលដំបូងរបស់ខ្លួននៅរាជធានី ភ្នំពេញ។ មិនយូរប៉ុន្មាន នៅខែមករា ឆ្នាំ១៩៦៧ ស្ថានកុងស៊ុលនោះត្រូវបានដកចេញទៅវិញ ព្រោះតែមានបញ្ហាទំនាក់ទំនងយ៉ាងធ្ងន់ធ្ងរដោយសារសង្គ្រាមត្រជាក់។ រហូតដល់ខែឧសភា ឆ្នាំ ១៩៧០ ទំនាក់ទំនងការទូតជាផ្លូវការប្រទេសទាំងពីរបានចាប់ផ្តើម ហើយមានការបង្កើតស្ថានទូត កូរ៉េប្រចាំនៅកម្ពុជានៅខែសីហា ក្នុងឆ្នាំដដែលនេះ តាមរយៈរដ្ឋាភិបាលលន់ នល់ ដែលគាំទ្រ ដោយអាមេរិក។ ទំនាក់ទំនងដែលជាប់ពាក់ព័ន្ធនឹងរបបនយោបាយនេះ មិនអាចរក្សាបានយូរ អង្វែងទេ ពោលគឺត្រូវបានបញ្ចប់ដោយសារ ពួកខ្មែរក្រហមបានអំណាច ហើយបានកាត់ផ្តាច់ ទំនាក់ទំនងបរទេស ដែលធ្វើឲ្យរដ្ឋាភិបាលកូរ៉េដកស្ថានទូតខ្លួនចេញពីកម្ពុជា (មេសា ១៩៧៥)។

បន្ទាប់ពីការដួលរលំរបបខ្មែរក្រហមនៅខែមករា ឆ្នាំ១៩៧៩ កម្ពុជាបានខិតខំធ្វើយ៉ាងណា ឲ្យសេដ្ឋកិច្ចនិងសង្គមមានស្ថិរភាពឡើងវិញដោយខ្លួនឯង។ ទន្ទឹមនឹងនេះដែរ ប្រទេសកម្ពុជាក៏ បានចាប់ផ្តើមផ្សាភ្ជាប់ទំនាក់ទំនងខ្លួនជាមួយនឹងសហគមន៍អន្តរជាតិ ដើម្បីអាចក្លាយជាសមាជិក នៃអង្គការអន្តរជាតិដូចជា អ.ស.ហ. និងធនាគារពិភពលោក។ ម្យ៉ាងវិញទៀត បន្ទាប់ពីដំណើរ ទស្សនកិច្ចផ្លូវរដ្ឋរបស់នាយករដ្ឋមន្ត្រីទី២ លោក ហ៊ុន សែន នាខែកក្កដា ឆ្នាំ១៩៩៦ បានជំរុញឲ្យ មានការបន្តទំនាក់ទំនងជាផ្លូវការរវាងរាជធានីភ្នំពេញ និងទីក្រុងសេអ៊ូល ដោយមានការបង្កើត ការិយាល័យតំណាងសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជា នៅខែកញ្ញា ឆ្នាំ១៩៩៦។ ក្រោយមកនៅ ខែតុលា ឆ្នាំ១៩៩៧ ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរចាប់ផ្តើមឡើងវិញជាផ្លូវការ ក៏ប៉ុន្តែ កិច្ចសហប្រតិបត្តិការនៅមានតិចតួចនៅឡើយ ដោយមានតែការិយាល័យតំណាងកូរ៉េ១ប៉ុណ្ណោះ

ប្រចាំនៅកម្ពុជា។ កិច្ចសហការកម្រិតនេះបន្តរហូតដល់ខែកុម្ភៈ ឆ្នាំ១៩៩៨ ក្រោយការិយាល័យតំណាងរបស់កូរ៉េត្រូវបានប្តូរទៅជាស្ថានទូត។ ដូចគ្នានេះដែរ កម្ពុជាបានបង្កើតស្ថានទូតរបស់ខ្លួននៅកូរ៉េខាងត្បូងជាលើកដំបូងក្នុងខែមេសា ឆ្នាំ២០០១។

## ១.១០. នីតិវិធីនៃការផ្តល់គម្រោងជំនួយឥតសំណង

ជាទូទៅ គម្រោងនៃការផ្តល់ជំនួយឥតសំណងមានដំណើរការដូចខាងក្រោម ៖




(ប្រភព ៖ KOREA's ODA WHITE PAPER 2017)

ជាបឋម ប្រទេសកូរ៉េត្រូវកំណត់យកគម្រោងដែលមាននិន្នាការអភិវឌ្ឍន៍ខ្លាំង ដោយមានការពិគ្រោះយោបល់ជាមួយបណ្តាប្រទេសជាដៃគូរបស់ខ្លួន ដោយផ្អែកលើយុទ្ធសាស្ត្ររយៈពេលមធ្យមរបស់ រដ្ឋាភិបាលកូរ៉េ និង CPS។ ទីភ្នាក់ងារផ្តល់ជំនួយនានា ត្រូវកំណត់គម្រោងឲ្យស្របទៅតាមយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយអភិវឌ្ឍន៍ថ្នាក់ជាតិរបស់ប្រទេសជាដៃគូ ដោយមានការប្រឹក្សាយោបល់ជាមួយពួកគេតាមរយៈស្ថានទូតកូរ៉េប្រចាំប្រទេសពួកគេ។ ភ្នាក់ងារដែលអនុវត្តន៍នោះ បន្ទាប់មកក៏ចាប់ផ្តើមដាក់ស្នើ PCPs ដែលបានមកពីអង្គភាពដែលពាក់ព័ន្ធ ហើយនិងស្នើសុំជាផ្លូវការនូវគម្រោងដែលបានផ្តល់ឲ្យពីក្រសួងពាក់ព័ន្ធ ដែលទទួល

ខុសត្រូវក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង ODA ក្នុងប្រទេស ដែលចូលរួមចំណែកតាមរយៈបណ្តាញការទូត។

បន្ទាប់ពីពិនិត្យមើលឡើងវិញនូវ PCPs បានដាក់ជូនដោយប្រទេសជាដៃគូរួច ភ្នាក់ងារដែលអនុវត្តន៍បានបញ្ជូនក្រុមជំនាញ ដើម្បីសិក្សាលទ្ធភាពនៃគម្រោងដែលបានដាក់ស្នើ។ បន្ទាប់ពីការសិក្សាទាំងនេះត្រូវបានបញ្ចប់ គម្រោងទាំងនេះត្រូវបានត្រួតពិនិត្យឡើងវិញ ហើយបញ្ជីគម្រោងថ្មីដែលត្រូវចាប់ផ្តើមនឹងត្រូវបានធ្វើសេចក្តីសម្រេច។ ពេលបញ្ជីគម្រោងថ្មីត្រូវបានដាក់បញ្ចូលគ្នា ការអង្កេតលើការអនុវត្តនឹងត្រូវបានដាក់ភ្ជាប់ជាមួយការអនុវត្តជាក់ស្តែងនិងដាក់ចេញនូវសេចក្តីលម្អិតជាចុងក្រោយ។ ផ្អែកលើលទ្ធផលនៃការអង្កេតទាំងនេះ ផែនការអនុវត្តគម្រោងនឹងត្រូវបានបង្កើតឡើង ហើយបន្ទាប់មកដៃគូដែលអនុវត្តន៍គម្រោងនឹងត្រូវបានជ្រើសរើស និងជួលផងដែរ។ លើសពីនេះទៅទៀត មាននីតិវិធីសម្របសម្រួលពិសេសមួយ ដែលត្រូវបានបង្កើតឡើងដើម្បីកំណត់ភាពច្រំដែលនៃគម្រោងដែលត្រូវបានជ្រើសរើស ដោយភ្នាក់ងារអនុវត្តន៍ ឬលទ្ធភាពនៃការសហការគ្នា ជាមួយភាពផ្សាភ្ជាប់គ្នារវាងគម្រោង ដើម្បីសម្រេចបាននូវចំណុចរួមគ្នា។ គណៈកម្មាធិការភ្នាក់ងារផ្តល់ជំនួយឥតសំណង ដើរតួជាយន្តការសម្របសម្រួលគម្រោងដើម្បីបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ គម្រោងជំនួយឥតសំណងរបស់ប្រទេសកូរ៉េ។ គម្រោងដែលត្រូវបានអនុម័តដោយគណៈកម្មាធិការទាំងនេះ នឹងត្រូវស្ថិតក្រោមការដោះស្រាយរបស់ CIDC។ បន្ទាប់ពីថវិកាជាតិត្រូវបានអនុម័តដោយរដ្ឋសភា ភ្នាក់ងារអនុវត្តន៍ត្រូវធ្វើការប្រឹក្សាយោបល់ជាមួយបណ្តាប្រទេសជាដៃគូ និងចាប់ផ្តើមអនុវត្តន៍គម្រោងជំនួយឥតសំណងតែម្តង។

បន្ទាប់ពីបញ្ចប់គម្រោង វាត្រូវឆ្លងកាត់ដំណើរការវាយតម្លៃ ដើម្បីបូកសរុបសមិទ្ធផល និងលទ្ធផលសេដ្ឋកិច្ចនិងសង្គមរបស់ខ្លួន។ លទ្ធផលនៃការវាយតម្លៃ ត្រូវបានឆ្លុះបញ្ចាំងលើគម្រោងនាពេលអនាគត ក្នុងន័យទុកជាមេរៀនក្នុងការអនុវត្ត។ ដើម្បីធានានូវប្រសិទ្ធភាពប្រកបដោយនិរន្តរភាពនៃគម្រោងជំនួយឥតសំណង KOICA តម្រូវឲ្យមានការចុះតាមដានគម្រោងជាចាំបាច់។

## ១.១១. បទពិសោធការផ្តល់ជំនួយឥតសំណងរបស់កូរ៉េក្នុងប្រទេសកំពុងអភិវឌ្ឍន៍

### ១.១១.១. ជំនួយលើការអប់រំរបស់ KOICA នៅវៀតណាម

វៀតណាម ជាប្រទេសដៃគូដំបូងបង្អស់របស់ KOICA នៅអាស៊ី។ ការិយាល័យ KOICA ត្រូវបានបង្កើតឡើងតាំងពី ខែកក្កដា ឆ្នាំ១៩៩៤ មកម្ល៉េះ នៅទីក្រុងហាណូយ ហើយបន្ទាប់មក KOICA ក៏បានបង្កើតការិយាល័យសាខាមួយទៀតនៅទីក្រុងហូជីមិញនៅឆ្នាំ២០១០។ ក្នុងនាមជាភ្នាក់ងារ ដែលទទួលបានការឧបត្ថម្ភពីរដ្ឋាភិបាលកូរ៉េ KOICA បានប្តេជ្ញាផ្តល់នូវកម្មវិធីជំនួយគ្រប់

ប្រភេទដល់ប្រទេសមួយនេះ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយដែលទីភ្នាក់ងារ KOICA បានផ្តោតទៅលើវិស័យអប់រំ និងសុខាភិបាលរបស់វៀតណាម ។

**១.១១.១.១ យុទ្ធសាស្ត្រលើកកម្ពស់ការអប់រំរបស់** KOICA

យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមវៀតណាម (SEDS) ឆ្នាំ ២០១១-២០២០ មានគោលបំណងកសាងសមត្ថភាពក្នុងការធ្វើឧស្សាហូបនីយកម្ម និងការផ្លាស់ប្តូរវៀតណាមឲ្យទៅជាសេដ្ឋកិច្ចដែលពឹងផ្អែកលើចំណេះដឹងទូលំទូលាយនិងខ្លាំងក្លា។ ដើម្បីកសាងការប្រកួតប្រជែងជាថ្នាក់ជាតិនៅក្នុងតំបន់ រដ្ឋាភិបាលវៀតណាមកំពុងបន្តការពង្រឹងបណ្តាញផលិតកម្ម និងខ្សែសង្វាក់ផលិតកម្មសកល ព្រមទាំងលើកកម្ពស់ពាណិជ្ជកម្មអន្តរជាតិផងដែរ។ ទន្ទឹមនឹងនោះរបៀបវារៈសំខាន់មួយនៃវិស័យអប់រំរបស់ប្រទេសមួយនេះ គឺការរួមបញ្ចូលក្រុមងាយរងគ្រោះក្នុងសង្គម តាមរយៈការអប់រំ។ នៅក្នុងបរិបទនេះ រដ្ឋាភិបាលវៀតណាមបានកំណត់ថា ការអភិវឌ្ឍធនធានមនុស្សជាអាទិភាពថ្នាក់ជាតិ។ ហេតុដូចនេះទើប KOICA បានកំណត់យកយុទ្ធសាស្ត្រសំខាន់ ២ ដែលអមជាមួយផែនការអនុវត្តន៍មួយចំនួន មានដូចខាងក្រោមៈ

១) ការបណ្តុះបណ្តាលអ្នកជំនាញដែលមានក្នុងវិស័យពាក់ព័ន្ធនឹងសម័យទំនើបកម្ម និងឧស្សាហូបនីយកម្មវៀតណាមដោយរួមទាំង វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា បរិស្ថាន ក៏ដូចជាច្បាប់អន្តរជាតិនិងការដោះស្រាយវិវាទ

- កូរ៉េនឹងលើកកម្ពស់បណ្តាញសហប្រតិបត្តិការនៃឧស្សាហកម្ម សាកលវិទ្យាល័យ រួមទាំងវិទ្យាស្ថានស្រាវជ្រាវនានា ដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍របស់វៀតណាមក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា បរិស្ថាន និងឧស្សាហកម្មសំខាន់ៗដទៃទៀត ដោយគាំទ្រហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ និងគោលនយោបាយអភិវឌ្ឍន៍។
- មួយវិញទៀត កូរ៉េក៏មានគម្រោងក្នុងការចូលរួមចំណែកក្នុងកម្មវិធី TVET ផងដែរ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម។
- ឆ្លើយតបទៅនឹងតម្រូវការរបស់រដ្ឋាភិបាលវៀតណាម កូរ៉េនឹងគាំទ្រទៅដល់ការកសាងសមត្ថភាពផ្នែកច្បាប់អន្តរជាតិ និងការដោះស្រាយវិវាទផងដែរ។

២) ការដាក់បញ្ចូលក្រុមងាយរងគ្រោះក្នុងសង្គម តាមរយៈការអប់រំ

- កូរ៉េនឹងលើកកម្ពស់ភាពជាដៃគូឯកជន និងសាធារណៈ ដើម្បីបង្កើនលទ្ធភាពការចូលរួមរបស់ក្រុមងាយរងគ្រោះក្នុង TVET និងពង្រឹងសមត្ថភាពតាមរយៈការបង្កើនបរិក្ខារអប់រំ។

### ១.១១.១.២. គម្រោងក្នុងវិស័យអប់រំដែល KOICA បាននិងកំពុងអនុវត្តន៍

ទាក់ទងនឹងវិស័យអប់រំ គម្រោងរបស់ KOICA ប្រចាំវៀតណាម បានផ្តោតលើការអប់រំនិងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ដែលវាមានសារៈសំខាន់សម្រាប់ វៀតណាម នៅពេលដែលប្រទេសមួយនេះបានឆ្លងកាត់ការផ្លាស់ប្តូរពីសេដ្ឋកិច្ចកសិកម្ម ក្លាយទៅជាសេដ្ឋកិច្ចឧស្សាហកម្ម។ សេដ្ឋកិច្ចវៀតណាមកំពុងតែមានតម្រូវការកម្មករ និយោជិត ដែលមានការអប់រំ និងមានជំនាញបច្ចេកទេសកម្រិតខ្ពស់ ដើម្បីបំពេញតាមតម្រូវការនៃការវិនិយោគទុនពីបរទេស និង ODA។

អស់រយៈពេលជិត ១០ឆ្នាំកន្លងមក KOICA បាននិងកំពុងអនុវត្តន៍គម្រោងលើវិស័យអប់រំសំខាន់ៗជាច្រើនរួមមាន ៖

- ការបង្កើតមហាវិទ្យាល័យបច្ចេកវិទ្យា កូរ៉េ-វៀតណាម នៅខេត្តបាកចាង (២០១០-២០១៤/ USD ១០លានដុល្លារ)។
- ការបង្កើតវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា វៀតណាម-កូរ៉េ (២០១៤-២០២០/ USD ៣៥លានដុល្លារ)។
- ការកែលម្អសាកលវិទ្យាល័យហាណូយ (២០១៤-២០១៩/ USD ៣លានដុល្លារ)
- ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលសុវត្ថិភាពការងារនិងសុខភាព (២០១៣-២០១៧/ USD ៣,៨លានដុល្លារ)។
- ការកែលម្អមហាវិទ្យាល័យវិជ្ជាជីវៈបច្ចេកវិទ្យាកូរ៉េ-វៀតណាម (២០១៤-២០១៨/ USD ៦ លានដុល្លារ)។
- ការពង្រឹងសមត្ថភាពមហាវិទ្យាល័យ ថាញ់ហ័រ (២០១៦/ USD ០,៥លានដុល្លារ)
- ការពង្រឹងសមត្ថភាពមហាវិទ្យាល័យ គ័ងប៊ិញ (២០១៦/ USD ០,៥លានដុល្លារ)
- ការកែប្រែមហាវិទ្យាល័យព័ត៌មានវិទ្យាមិត្តភាព វៀតណាម-កូរ៉េ ទៅជាសាកលវិទ្យាល័យ (២០១៣-២០២០/ USD ៥,២លានដុល្លារ)។
- ការកែលម្អមហាវិទ្យាល័យវិជ្ជាជីវៈខ្ពង់រាបកណ្តាល សម្រាប់យុវជនជនជាតិភាគតិចនៅខេត្តអូកឡាក់ (២០១៣-២០១៧/ USD ៥លានដុល្លារ)។

ជាសរុបមានចំនួន ៩គម្រោងដែល KOICA ប្រចាំវៀតណាម បាននិងកំពុងតែអនុវត្តន៍ទៅលើវិស័យអប់រំវៀតណាម ដែលចំណាយអស់ថវិកាសរុប USD ៦៨,៦លានដុល្លារ។

#### ១.១១.១.៣. សមិទ្ធផលដែលទទួលបាន

សមិទ្ធផលដ៏អស្ចារ្យបំផុតមួយ ក្នុងចំណោមសមិទ្ធផលជាច្រើន លើវិស័យអប់រំវៀតណាម គឺភាពច្នៃប្រឌិតត្រូវបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិថា វិស័យអប់រំវៀតណាម មានការរីកចំរើនទាំងបរិមាណ និងគុណភាព។ វៀតណាមមិនត្រឹមតែសំរេចបានគោលដៅ ឲ្យកុមារគ្រប់អាយុភាគច្រើនបានទៅសាលារៀនតែប៉ុណ្ណោះទេ ថែមទាំងរហូតមកទល់ពេលនេះការអប់រំនៅថ្នាក់មធ្យមសិក្សាបឋមភូមិ ក៏បានអនុវត្តនៅតាមគ្រប់តំបន់លើទូទាំងប្រទេសជាសារវន្តដែរ។ ជាមួយគ្នានេះ គុណភាពអប់រំកំពុងតែកើនឡើងយ៉ាងវិជ្ជមានចំពោះសិស្សានុសិស្សទាំងអស់នៅគ្រប់កម្រិតថ្នាក់ដែរ។ ប្រការនេះហើយបានជាអង្គការ អប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ (UNESCO) វាយតំលៃខ្ពស់លើវឌ្ឍនភាពអប់រំវៀតណាម ពិសេសលើសមិទ្ធផលការបណ្តុះបណ្តាលគ្រូបង្រៀន និងការជំរុញឲ្យមានយុត្តិធម៌ សមភាពក្នុងការអប់រំផងដែរ។

មកទល់បច្ចុប្បន្ននេះ បណ្តាមហាវិទ្យាល័យវៀតណាម មានកម្មវិធីបណ្តុះបណ្តាលអន្តរជាតិជាង ៥០០ ជាមួយនឹងមហាវិទ្យាល័យនានានៅលើពិភពលោក ដោយនេះមិនទាន់រាប់បញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាល វិស្វករគុណភាពខ្ពស់ បរិញ្ញាបត្រឆ្នើម និងកម្មវិធីជឿនលឿនទៅតាមស្តង់ដាអន្តរជាតិនៅឡើយ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ វៀតណាមបានក្លាយទៅជាចំណុចលេចធ្លោលើផែនទីអប់រំពិភពលោក បន្ទាប់ពីប្រទេសមួយនេះបានធ្វើជាម្ចាស់ផ្ទះរៀបចំនូវព្រឹត្តិការណ៍ជាអន្តរជាតិសំខាន់ៗជាច្រើនដូចជា ការប្រឡង អូឡាំពិករូបវិជ្ជាអាស៊ី ២០០៩, អូឡាំពិកគណិតវិទ្យាអន្តរជាតិ ២០០៧, អូឡាំពិកគីមីសាស្ត្រអន្តរជាតិ ២០១២, អូឡាំពិកជីវសាស្ត្រអន្តរជាតិ ២០១៦ ជាដើម។ ទន្ទឹមនឹងនោះ លទ្ធផលក្នុងការប្រឡងទាំងនេះរបស់សិស្សានុសិស្សវៀតណាម បានសម្រេចជាផ្លែផ្កាយ៉ាងច្រើន ដែលបានបង្ហាញពីសន្ទុះកំណើនធនធានមនុស្សគួរឲ្យកត់សម្គាល់[21] ស្របពេលពួកគេក៏ទទួលបានការកោតសរសើរយ៉ាងខ្លាំងពីសំណាក់មិត្តភ័ក្រ្តអន្តរជាតិដែរ ។

ចំពោះគ្រូបង្រៀន ប្រជាជាតិវៀតណាមមានប្រពៃណី គោរពសីលធម៌ ប្រជាជនគ្រប់រូបគោរពគ្រូបង្រៀនជានិច្ច។ ហេតុនេះ គ្រូបង្រៀនមានភាពទឹកចិត្តប្រកបវិជ្ជាជីវៈបណ្តុះបណ្តាលមនុស្ស ដើម្បីរួមចំណែកក្នុងការរីកលូតលាស់ក្នុងបុព្វហេតុអប់រំនៃប្រទេសជាតិរបស់ខ្លួន។

#### ១.១១.២.បទពិសោធជំនួយលើការអប់រំរបស់ KOICA នៅឡាវ

KOICA បានបញ្ជូនអ្នកស្ម័គ្រចិត្ត ៣នាក់មកប្រទេសឡាវនាឆ្នាំ ២០០០ ហើយបន្ទាប់មកបានបង្កើតការិយាល័យអ្នកស្ម័គ្រចិត្តជនជាតិកូរ៉េក្រៅប្រទេសកាលពីឆ្នាំ ២០០១។ លុះដល់ឆ្នាំ

[21] ឧបសម្ព័ន្ធទី៣

២០០៦ ការិយាល័យមួយនេះត្រូវបានប្តូរឈ្មោះជាការិយាល័យ KOICA ប្រចាំសាធារណៈរដ្ឋប្រជាមានិតឡាវ (KOICA Laos PDR) ស្របពេលដែលទីភ្នាក់ងារមួយនេះបានពង្រីកខ្លួនដើម្បីបង្កើនប្រតិបត្តិនូវជំនួយឥតសំណងកាន់តែមានទំហំធំឡើង។ មកទល់នឹងពេលនេះ KOICA បាន និងកំពុងខិតខំគាំទ្រដល់ការអភិវឌ្ឍជនបទ ក៏ដូចជាការអប់រំ និងសុខាភិបាលរបស់ប្រទេសឡាវយ៉ាងខ្លាំង ដើម្បីធ្វើយ៉ាងណាជួយឲ្យប្រទេសនេះសម្រេចបាន ផែនការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិប្រទេសឡាវ (NSEDP) ដោយក្លាយខ្លួនទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមត្រឹមឆ្នាំ ២០២០ តាមរយៈការអភិវឌ្ឍប្រកបដោយការរួបរួមគ្នានិងនិរន្តភាព និងពង្រឹងភាពប្រកួតប្រជែងថ្នាក់ជាតិផងដែរ។

**១.១១.២.១. យុទ្ធសាស្ត្រលើកកម្ពស់ការអប់រំរបស់** KOICA

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ប្រទេសកូរ៉េបានទទួលងារជាប្រទេសដែលមានការអប់រំគ្រប់កម្រិតមានលក្ខណៈជាសកល។ តាមរយៈបទពិសោធ ប្រទេសអភិវឌ្ឍន៍មួយនេះបានចែករំលែក ដើម្បីលើកកម្ពស់ប្រព័ន្ធអប់រំប្រកបដោយប្រសិទ្ធភាព និងអាចសម្របគ្រប់ស្ថានភាពនៅប្រទេសឡាវ។ KOICA មានយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសឡាវក្នុងវិស័យអប់រំដូចជា៖

១) លើកកម្ពស់ការចូលរៀន និងការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅក្នុងកម្រិតអប់រំមធ្យមសិក្សានិងឧត្តមសិក្សា ព្រមទាំងការកែលម្អគុណភាពនិងប្រសិទ្ធភាពនៃការអប់រំកម្រិតថ្នាក់វិទ្យាល័យនិងឧត្តមសិក្សា និងការអភិវឌ្ឍរចនាសម្ព័ន្ធការអប់រំដូចជា ការអប់រំដែលមានមូលដ្ឋានគ្រឹះលើ ICT សម្ភារចាំបាច់សម្រាប់ការអប់រំ បរិក្ខារចាំបាច់សម្រាប់ការស្រាវជ្រាវ បណ្ណាល័យព័ត៌មានវិទ្យា និងការរួមចំណែកផ្សេងៗទៀតដូចជា អាហារូបករណ៍ ការបណ្តុះបណ្តាលគ្រូបង្រៀន សម្ភារបង្រៀន និងការអភិវឌ្ឍកម្មវិធីសិក្សាផងដែរ។

២) ពង្រឹង TVET ដើម្បីអភិវឌ្ឍន៍កម្លាំងពលកម្មឧស្សាហកម្មនិងប្រកួតប្រជែងថ្នាក់ជាតិ។

៣) អភិវឌ្ឍន៍ការអប់រំសាកលវិទ្យាល័យ សមត្ថភាពស្រាវជ្រាវ និងកម្មវិធីអាហារូបករណ៍សម្រាប់កម្មវិធីអនុបណ្ឌិតនិងបណ្ឌិត។

៤) ពង្រឹងអភិបាលកិច្ចអប់រំ និងសមត្ថភាពរដ្ឋបាលរបស់វិទ្យាស្ថានអប់រំ រួមទាំង ការកសាងសមត្ថភាពអ្នកគោលនយោបាយ គ្រូបង្រៀន និងបុគ្គលិករដ្ឋបាល ការបញ្ជូនអ្នកជំនាញ ការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុនិងហេដ្ឋារចនាសម្ព័ន្ធ និងកុងស៊ុលសម្រាប់អភិបាលកិច្ចស្ថាប័ន។

**១.១១.២.២. ការអនុវត្តរបស់** KOICA

កន្លងមក រដ្ឋាភិបាលកូរ៉េ បានគាំទ្រដល់គម្រោងអប់រំជាច្រើននៅក្នុងប្រទេសឡាវ រួមទាំងគម្រោងលើការបោះពុម្ពសៀវភៅសិក្សាកម្រិតអនុវិទ្យាល័យ រួមទាំង ការកសាងសមត្ថភាពនៅសាកលវិទ្យាល័យ ហើយ KOICA នឹងបន្តគាំទ្រការអប់រំនៅគ្រប់កម្រិតទាំងអស់។

– **គម្រោងផ្គត់ផ្គង់សៀវភៅសិក្សាដល់សាលារៀនអនុវិទ្យាល័យ**

គម្រោងនេះត្រូវបានអនុវត្តជា ៣ដំណាក់កាល រួមទាំងការបោះពុម្ពផ្សាយសៀវភៅសិក្សាថ្នាក់អនុវិទ្យាល័យ និងសៀវភៅសិក្សាថ្នាក់វិទ្យាល័យនៅប្រទេសឡាវ ដែលមាន ១៣មុខវិជ្ជា។ ដំណាក់កាលដំបូងនៃការចែកចាយសៀវភៅនេះ ត្រូវបានធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០០៨ ជាលើកទី២ នៅខែធ្នូ ឆ្នាំ២០០៨ ហើយនិងលើទី៣ ត្រូវបានបញ្ចប់នៅខែកញ្ញា ឆ្នាំ២០០៩។ សៀវភៅសរុបមានចំនួន ២,៦៦លានក្បាលត្រូវបានចែកចាយដល់សិស្សចំនួន ៣៩០ ០០០ នាក់ចាប់ពីថ្នាក់ទី ៦ ដល់ថ្នាក់ទី ១១។

ម៉្យាងវិញទៀត KOICA មិនត្រឹមតែគាំទ្រការបោះពុម្ពផ្សាយសៀវភៅនិងការចែកចាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគាំទ្រការអភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រផងដែរ។ ភ្នាក់ងារ KOICA ក៏បានបញ្ជូនអ្នកឯកទេសផ្នែកអភិវឌ្ឍន៍កម្មវិធីជាច្រើន ដើម្បីអភិវឌ្ឍកម្មវិធីសិក្សានិងកសាងសមត្ថភាពនិងធនធានមនុស្សក្នុងវិស័យបោះពុម្ព និងបោះពុម្ពផ្សាយផងដែរ។ សិក្ខាកាមក្នុងវិស័យនេះ ក៏ត្រូវបានគេអញ្ជើញឲ្យចូលរួមកម្មវិធីហ្វឹកហ្វឺននៅក្នុងប្រទេសកូរ៉េដែរ។

– **គម្រោងការពង្រឹងការអភិវឌ្ឍជំនាញនៅវិទ្យាស្ថានឡាវ-កូរ៉េ**

គម្រោងនេះ KOICA បានផ្តល់នូវថវិកាចំនួន USD ៥លានដុល្លារ ដើម្បីជួយសម្រួលទៅដល់ការអភិវឌ្ឍជំនាញនៅប្រទេសឡាវ ដែលមានរយៈពេល ៥ឆ្នាំ គិតចាប់ពីឆ្នាំ ២០១៧-២០២០។ សម្រាប់ការអនុវត្តគម្រោង នឹងមានការជួសជុលនិងកែលម្អឡើងវិញនៃបន្ទប់សិក្សានិងបន្ទប់អន្តេវាសិកដ្ឋានដែលមានស្រាប់ ព្រមទាំងសាងសង់អគារសិក្សាថ្មី ការិយាល័យ និងកន្លែងស្នាក់នៅបន្ថែមទៀត។

**១.១១.២.៣. សមិទ្ធផលដែលទទួលបាន**

ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសឡាវបានធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំគ្រប់កម្រិត។

– អត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់ការសិក្សាថ្នាក់បឋមសិក្សាបានកើនឡើងពី ៦៥% ក្នុងឆ្នាំ១៩៩០ ដល់ ៩៨% ក្នុងឆ្នាំ២០១៥។

- ប្រទេសឡាវ បានសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ភាគច្រើនក្នុងវិស័យអប់រំជាពិសេសគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី២ (ការសម្រេចបាននូវការអប់រំបឋមសិក្សាជាសកល) និង MDG ៣ (សមភាពយេនឌ័រ)។

ហេតុដូចនេះ ប្រជាជននិងរដ្ឋាភិបាលឡាវ បានវាយតម្លៃខ្ពស់ចំពោះផែនការយុទ្ធសាស្ត្រដែលបានអនុវត្តន៍កន្លងមក ហើយបានទទួលស្គាល់ថាវាពិតជាបានចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សឡាវយ៉ាងពិតប្រាកដមែន។

## ១.១២. គម្រោងជំនួយឥតសំណងទ្វេភាគី កម្ពុជា-កូរ៉េ តាមវិស័យ[22]

ក្នុងរយៈពេលជិត២ទសវត្សន៍ គិតចាប់តាំងពីពេលដែល KOICA បានដាក់ការិយាល័យរបស់ខ្លួននៅកម្ពុជាមក ទីភ្នាក់ងារមួយនេះ បានក្លាយជាដៃគូអភិវឌ្ឍន៍របស់កម្ពុជាធំបំផុតទី៣ ដោយផ្តល់នូវជំនួយឥតសំណង សរុបជាទឹកប្រាក់ចំនួន USD ២២៥លាន។[23] នាប៉ុន្មានឆ្នាំចុងក្រោយនេះ KOICA ផ្តល់ថវិកាអភិវឌ្ឍន៍ប្រមាណ USD ២០លានជារៀងរាល់ឆ្នាំ មកលើការអនុវត្តគម្រោងថ្មីពី ៤ទៅ៥គម្រោង ដោយចំណាយថវិកា ពីUSD៥ទៅ១០លាន ក្នុងគម្រោងនីមួយៗ។

ខាងក្រោមនេះជាបញ្ជីគម្រោងទ្វេភាគីរបស់ KOICA ប្រចាំកម្ពុជាដែលមាននាពេលកន្លងមករហូតដល់ឆ្នាំ ២០១៨ ៖

### ១.១២.១. វិស័យសុខាភិបាល

- ការស្រាវជ្រាវពីការបង្ការជំងឺឆ្លងក្នុង ៦ប្រទេសដែលជាសមាជិកអាស៊ាន ក្នុងក្របខណ្ឌនៅទូទាំងប្រទេស(២០០២-២០០៦/ USD ២,៥ លានដុល្លារ)។
- ការកសាងមន្ទីរពេទ្យទំនើបកុមារនៅភ្នំពេញ(២០០៥-២០០៦/ USD ២,៦ លានដុល្លារ)
- ការកសាងមន្ទីរពេទ្យមិត្តភាពកូរ៉េ-កម្ពុជាកំពង់ឆ្នាំង (២០០៧-២០០៨/ USD ១ លានដុល្លារ)។
- ការពង្រឹងសេវាសុខភាពមន្ទីរពេទ្យ សៀមរាប (២០១០-២០១២/ USD ៣,៣ លានដុល្លារ)
- ការកសាងមន្ទីរពេទ្យភ្នែកព្រះអង្គឌួង ក្នុងរាជធានីភ្នំពេញ (២០១១-២០១៤/ USD ៥,៥ លានដុល្លារ)។
- ការពង្រឹងសមត្ថភាពមន្ទីរពេទ្យបង្អែកស្រុកបាធាយ ខេត្តកំពង់ចាម (២០១១-២០១៤/ USD៣,៥ លានដុល្លារ)។

[22] KOICA Cambodia

[23] ឧបសម្ព័ន្ធទី៤

- ការកែលម្អមុខងារអាគារមិត្តភាពអាគារកម្ពុជា-កូរ៉េ នៅមន្ទីរពេទ្យកុមារជាតិ ភ្នំពេញ (២០១៣-២០១៧/ USD ៦,៩លានដុល្លារ)។
- កម្មវិធីទ្រទ្រង់វិស័យសុខាភិបាលនៅកម្ពុជា (HSSP) គ្របដណ្តប់ទូទាំងប្រទេស (២០១៤-២០១៥/ USD ៥លានដុល្លារ)។
- កម្មវិធីសមធម៌និងការកែលម្អគុណភាពវិស័យសុខាភិបាលកម្ពុជា ដែលគ្របដណ្តប់នៅទូទាំងប្រទេស (២០១៧-២០១៩/ USD ៧លានដុល្លារ)។
- ការអភិវឌ្ឍនិងការអនុវត្តដំបូងនៃផែនការរយៈពេល ៥ ឆ្នាំនៃរបៀបវារៈសន្តិសុខសុខភាពសកល (GHSA) គ្របដណ្តប់ទូទាំងប្រទេស (២០១៧-២០១៩/ USD ៣លានដុល្លារ)។
- គម្រោងការពង្រឹងវិស័យសុខាភិបាល មាតានិងទារកតាមតំបន់ដាច់ស្រយាលនៃភូមិភាគឦសានប្រទេសកម្ពុជា (២០១៧-២០២១/ USD ៧ លានដុល្លារ)។
- ការពង្រឹងសមត្ថភាពវះកាត់ ត្រចៀក ច្រមុះ បំពង់ក ក្បាល និងក នៅមន្ទីរពេទ្យអង្គឌួងភ្នំពេញ (២០១៨-២០២០/ USD ៧លានដុល្លារ)។

គិតជាចំនួនសរុបមាន ១២គម្រោងទ្វេភាគីក្នុងវិស័យសុខាភិបាល ដែលចំណាយទឹកប្រាក់អស់ USD ៥៤,១លានដុល្លារ។

**១.១២.២. វិស័យអប់រំ**

- ការបង្កើតក្របខណ្ឌគុណវុឌ្ឍិថ្នាក់ជាតិនៅកម្ពុជា គ្របដណ្តប់ទូទាំងប្រទេស (២០០៧-២០០៩/ USD ១,២លានដុល្លារ)។
- ការពង្រឹងសមត្ថភាព CLMV សម្រាប់សាកលវិទ្យាល័យអ៊ិនធឺរៀអាស៊ាន នៅភ្នំពេញ (២០១០-២០១២/ USD ១លានដុល្លារ)។
- គម្រោងកសាងមជ្ឈមណ្ឌលធនធានមនុស្សនៅកម្ពុជា ក្នុងរាជធានីភ្នំពេញ (២០១០-២០១៤/ USD ៧,៤៥លានដុល្លារ)។
- ការអភិវឌ្ឍន៍ផ្នែកបច្ចេកទេសនៅកម្រិតមធ្យមសិក្សា គ្របដណ្តប់ទូទាំងប្រទេស (២០១៣ - ២០១៤/ USD ២លានដុល្លារ)។

ជាសរុបមាន ៤គម្រោងទ្វេភាគីក្នុងវិស័យអប់រំ ដែលគិតជាទឹកប្រាក់សរុបចំនួន USD ១១,៦៥លានដុល្លារ។

ក្រៅពីគម្រោងខាងលើ KOICA អញ្ជើញមន្ត្រីរាជការកម្ពុជាប្រមាណ ១២០នាក់ជារៀងរាល់ឆ្នាំ ដើម្បីបន្តការសិក្សាកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី និងថ្នាក់អនុបណ្ឌិត។ អ្នកស្ម័គ្រចិត្ត

ប្រហែល ១០០ នាក់ធ្វើការជារៀងរាល់ឆ្នាំនៅក្នុងប្រទេសកម្ពុជា ដែលមានរយៈពេល ២ ឆ្នាំ។ អ្នកស្ម័គ្រចិត្តខិតខំចែករំលែកចំណេះដឹង និងជំនាញក្នុងវិស័យដូចជា ភាសាកូរ៉េ ជំនាញកុំព្យូទ័រ និងការអប់រំកុមារ។

### ១.១២.៣. វិស័យដឹកជញ្ជូន

- ការសិក្សាពីលទ្ធភាពស្តារឡើងវិញនៃផ្លូវកំពត-ត្រពាំងរពៅ នៅខេត្តកំពត (២០០១-២០០២/ USD ០,៦លានដុល្លារ)។
- ការសិក្សាជាមូលដ្ឋានលើការបោះបង្គោលការពារដីធ្លីដំណាក់កាលទី១ នៅក្នុងក្របខណ្ឌទូទាំងប្រទេស (២០០៣-២០០៤/ USD ១លានដុល្លារ)។
- ការស្ថាបនាផ្លូវវាងខេត្តសៀមរាប (២០០៥-២០០៦/ USD ១,៦លានដុល្លារ)
- ការសិក្សាជាមូលដ្ឋានលើការបោះបង្គោលការពារដីធ្លីដំណាក់កាលទី២ នៅក្នុងក្របខណ្ឌទូទាំងប្រទេស (២០០៥-២០០៦/ USD ១,២លានដុល្លារ)។
- ការបោះបង្គោលការពារដីថ្នាក់ជាតិនៅកម្ពុជា (២០១០-២០១១/ USD ២,៥លានដុល្លារ)
- ការក្រាលថ្មចិញ្ចើមផ្លូវវាងខេត្តសៀមរាប (២០០៨-២០០៩/ USD ៤,៣លានដុល្លារ)
- ការកសាងផែនទីគោល និង ការបង្កើតផែនការមេ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ទិន្នន័យភូមិសាស្ត្រកម្ពុជា ក្របខណ្ឌទូទាំងប្រទេស (២០១០-២០១១/ USD ២,៥លានដុល្លារ)។
- ការពង្រីកផ្លូវវាងសៀមរាប (ផ្លូវក្រវ៉ាត់កូរ៉េ) ដំណាក់កាលទី២ (២០១០-២០១២/ USD ១១,៥លានដុល្លារ)។
- គម្រោងប្លង់មេសម្រាប់ការអភិវឌ្ឍបណ្តាញផ្លូវដែកនៅកម្ពុជាក្នុងក្របខណ្ឌទូទាំងប្រទេស (២០១១-២០១៣/ USD ២,៨លានដុល្លារ)។
- គម្រោងផ្តល់សម្ភារនិងឧបករណ៍ធានាសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងការអប់រំស្តីពីវិធានការសុវត្ថិភាពនៅតាមបណ្តោយផ្លូវជាតិលេខ៣ លេខ៦ និងលេខ៤៨ នៅខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុង (២០១១-២០១៣/ USD ៣,២លានដុល្លារ)។
- ការកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលអាកាសចរណ៍ស៊ីវិល នៅរាជធានីភ្នំពេញ កម្ពុជា (២០១១-២០១៣/ USD ១០,១លានដុល្លារ)។
- គម្រោងសម្រាប់លទ្ធភាពសិក្សាលើផ្លូវទឹក សម្រាប់ធ្វើឲ្យប្រសើរឡើងការអភិវឌ្ឍកំពង់ផែដឹកជញ្ជូននៅកម្ពុជា ក្នុងរាជធានីភ្នំពេញ និងខេត្តក្រចេះ (២០១៤-២០១៧/ USD ៥,៥លានដុល្លារ)។

ជាសរុបនៃគម្រោងទ្វេភាគីក្នុងវិស័យដឹកជញ្ជូន មានចំនួន១២គម្រោងដែលគិតជាទឹកប្រាក់សរុបចំនួន USD ៥៦,៨លានដុល្លារ។

### ១.១២.៤. វិស័យទឹក

- គម្រោងស្តារឡើងវិញនូវ អាងស្តុកទឹកតាមោក នៅខេត្តកណ្តាល (២០០២ - ២០០៤/ USD ១ ៤០០ ០០០ដុល្លា)។
- ការសិក្សាពីលទ្ធភាពលើការអភិវឌ្ឍទន្លេក្រាំងពន្លៃ ខេត្តកំពង់ចាម (២០០៤ - ២០០៥/ USD ៧០០ ០០០ដុល្លា)។
- ផែនការមេស្តីពីការអភិវឌ្ឍន៍ធនធានទឹកទូទាំងប្រទេស (២០០៦-២០០៨ / USD ១,៥ លានដុល្លារ)។
- ការគ្រប់គ្រងទឹកជំនន់នៅស្រុកបាធាយ ខេត្តកំពង់ចាម (២០០៧-២០០៨/ USD ២លានដុល្លា)។
- ការគ្រប់គ្រងទឹកជំនន់នៅស្រុកបាធាយ ខេត្តកំពង់ចាម ដំណាក់កាលទី២ (២០០៩-២០១០/ USD ២,៥លានដុល្លារ)។
- គម្រោងរួមគ្នារវាង KOICA-JICA ស្តីពីការសាងសង់ធារាសាស្ត្រនិងការអភិវឌ្ឍជនបទ ខេត្តកំពង់ចាម (២០០៩/ USD ០,២លានដុល្លារ)។

ជារួមមានចំនួន ៦គម្រោងក្នុងវិស័យទឹក ដែលបានចំណាយទឹកប្រាក់អស់ប្រមាណ USD ១០,១លានដុល្លារ។

### ១.១២.៥. វិស័យថាមពល

- គម្រោងសម្រាប់ការបង្កើតប្រព័ន្ធថាមពលប្រើប្រាស់ពន្លឺព្រះអាទិត្យនៅកម្ពុជា ក្នុងភូមិកោះស្លា ខេត្តកំពត និងភ្នំគូលែន ខេត្តសៀមរាប (២០០៩-២០១១/ USD ២,២លានដុល្លារ)។

ជាសរុបមានតែ ១គម្រោងក្នុងវិស័យថាមពល ដែលបានចំណាយអស់ទឹកប្រាក់ចំនួន USD ២,២លានដុល្លារ)។

### ១.១២.៦. វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (STI)

- ផែនការមេស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិកម្ពុជា ឆ្នាំ ២០១៤-២០២០ (២០១១-២០១៣/ USD ៣,៥លានដុល្លារ)។

- គម្រោងផែនការមេ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានកម្ពុជា (២០១២-២០១៤/ USD ២ លានដុល្លារ)។

ជារួមមានចំនួន ២គម្រោងដែលបានអនុវត្តន៍ក្នុងវិស័យវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងភាពច្នៃប្រឌិត (STI) ដោយគិតជាទឹកប្រាក់ចំនួន USD ៥,៥លានដុល្លារ។

**១.១២.៧. វិស័យកសិកម្មនិងការអភិវឌ្ឍជនបទ**

- គម្រោងអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម (២០០៦-២០០៨/ USD ១លានដុល្លារ)
- ការបង្កើតគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ គ្របខណ្ឌទូទាំងប្រទេស (២០០៧-២០០៨/ USD ១,៨លានដុល្លារ)។
- គម្រោងអភិវឌ្ឍន៍ជនបទចម្រុះក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (២០១០-២០១២/ USD ២,៥លានដុល្លារ)។
- ការបង្កើតផែនការមេនៃភ្នាក់ងារសហប្រតិបត្តិការសម្រាប់វិនិយោគនៅក្នុងវិស័យកសិកម្មកម្ពុជា (២០១១-២០១៣/ USD ១លានដុល្លារ)។
- គម្រោងអភិវឌ្ឍន៍ជនបទដោយការគាំទ្រខ្លួនឯង តាមរយៈការប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មី (SMU) គ្របខ័ណ្ឌទូទាំងប្រទេស (២០១៤-២០១៨/ USD ៨លានដុល្លារ)។
- គម្រោងលើកកម្ពស់គុណភាពសិក្សា-កែលម្អសាលាជាតិកសិកម្មខេត្តកំពង់ចាម(KCNSA) ដោយផ្តោតលើវិធីសាស្ត្រចលនាភូមិថ្មី (២០១៦-២០១៧/ USD ២លានដុល្លារ)។

ជារួមមានចំនួន ៦គម្រោងដែលបានអនុវត្តន៍ក្នុងវិស័យកសិកម្មនិងការអភិវឌ្ឍជនបទដោយគិតជាទឹកប្រាក់ចំនួន USD ១៦,៣លានដុល្លារ។

មិនតែប៉ុណ្ណោះ KOICA ក៏កំពុងអនុវត្តគម្រោងបង្កើនប្រាក់ចំណូលនៅក្នុងភូមិគោលដៅចំនួន ៣០ នៃខេត្តចំនួន ៣ រួមមានខេត្តកំពង់ស្ពឺ ត្បូងឃ្មុំ និងខេត្តតាកែវ។ ម្យ៉ាងវិញទៀត មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ ត្រូវបានកសាងនៅខេត្តកំពង់ស្ពឺ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលអ្នកដឹកនាំភូមិនិងអ្នកជំនាញផ្នែកកសិកម្មនៅកម្ពុជា។

**១.១២.៨. វិស័យសេដ្ឋកិច្ច**

- ការបង្កើតសមត្ថភាពក្នុងការធ្វើពាណិជ្ជកម្មទំនិញនិងសេវាកម្មគ្របដណ្តប់ទូទាំងប្រទេស (២០០៤-២០០៥/ USD ០,៩លានដុល្លារ)។
- ការកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា គ្របខណ្ឌទូទាំងប្រទេស (២០០៧-២០០៩/ USD ១,៨លានដុល្លារ)។

- ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា ក្របខណ្ឌទូទាំងប្រទេស (២០១៤-២០១៧/ USD ២,៥ លានដុល្លារ)។
- ការអភិវឌ្ឍប្រព័ន្ធទូទាត់រាយសម្រាប់កម្ពុជា ក្របខ័ណ្ឌទូទាំងប្រទេស (២០១៥-២០១៩/ USD ៨លានដុល្លារ)។

ជារួមមាន ៩គម្រោងដែលបានអនុវត្តន៍ក្នុងវិស័យសេដ្ឋកិច្ច ដោយគិតជាទឹកប្រាក់ចំនួន USD ១៣,២លានដុល្លារ។

**១.១២.៩. វិស័យបរិស្ថាន**

- ការសិក្សាពីលទ្ធភាពសាងសង់ទីលានចាក់សំរាមនៅសៀមរាប (២០១០/ USD ០,២៥ លានដុល្លារ)។

ដូចនេះមានតែ ១គម្រោងដែលបានអនុវត្តន៍ក្នុងវិស័យបរិស្ថាន ដោយគិតជាទឹកប្រាក់ចំនួន USD ០,២៥លានដុល្លារ)។

**១.១២.១០. វិស័យវប្បធម៌**

- ការស្តារឡើងវិញនៃប្រាសាទព្រះពិធូរក្នុងបរិវេណប្រាសាទអង្គរវត្ត (២០១៥-២០១៨/ USD ៤លានដុល្លារ)។

ដូច្នេះមានតែ ១គម្រោងដែលបានអនុវត្តន៍ក្នុងវិស័យវប្បធម៌ ដោយគិតជាទឹកប្រាក់ចំនួន USD ៤លានដុល្លារ។

សរុបជារួមមកមាន ៥០គម្រោងទ្វេភាគីដែលបានអនុវត្តន៍នាពេលកន្លងមក ហើយគិតជាទឹកប្រាក់ចំនួន USD ១៦៣,១លានដុល្លារ។

# ជំពូកទី២

# ស្ថានភាពទូទៅនៃការផ្តល់ជំនួយ
# អភិវឌ្ឍន៍ផ្លូវការតាមរយៈKOICA
# លើវិស័យអប់រំកម្ពុជា

# ជំពូកទី ២ ស្ថានភាពទូទៅនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ តាមរយៈ KOICA លើវិស័យអប់រំកម្ពុជា

## ២.១. ទិដ្ឋភាពទូទៅរបស់ KOICA

### ២.១.១. ប្រវត្តិរបស់ KOICA

#### ២.១.១.១. KOICA ការិយាល័យកណ្តាល

ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការផ្តល់ជំនួយឥតសំណងរបស់ប្រទេសកូរ៉េដែលធ្លាប់តែត្រូវបានចាត់ចែងដោយក្រសួងនានានោះ រដ្ឋាភិបាលកូរ៉េក៏បានបង្កើតនូវទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ឡើងនៅខែមេសា ឆ្នាំ១៩៩១ ក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសនៃសារធារណៈរដ្ឋកូរ៉េ។ ក្នុងនាមជាស្ថាប័នរដ្ឋាភិបាល ទទួលបន្ទុកចាត់ចែងជំនួយឥតសំណង ដល់ប្រទេសកំពុងអភិវឌ្ឍន៍ KOICA មានគោលដៅសម្របសម្រួលការអភិវឌ្ឍ សេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសដៃគូអភិវឌ្ឍន៍ និងលើកកម្ពស់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងកូរ៉េ និងប្រទេសកំពុងអភិវឌ្ឍន៍ជុំវិញពិភពលោក។ មិនតែប៉ុណ្ណោះ KOICA បានដាក់មូលដ្ឋានរបស់ខ្លួននៅបរទេសដោយបង្កើតការិយាល័យរបស់ខ្លួន ដើម្បីអនុវត្តន៍គម្រោង ODA ទៀតផង។ បន្ទាប់ពីប្រទេសកូរ៉េ បានក្លាយជាសមាជិករបស់ OECD DAC នៅឆ្នាំ ២០០៩ មក KOICA បានបន្តអនុវត្តន៍គម្រោង ODA យ៉ាងសកម្ម។ តួយ៉ាង KOICA បានកំណត់យកវិស័យអាទិភាពដូចជា វិស័យសុខាភិបាល អប់រំ អភិបាលកិច្ច កសិកម្មនិងអភិវឌ្ឍន៍ជនបទព្រមទាំងបច្ចេកវិទ្យា បរិស្ថាន និងថាមពល តាមរយៈគម្រោងអភិវឌ្ឍន៍ កម្មវិធីផ្លាស់ប្តូរបទពិសោធកម្មវិធីអ្នកស្ម័គ្រចិត្តកូរ៉េ និងកម្មវិធីអាហារូបករណ៍ ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ កិច្ចសហប្រតិបត្តិការ ពហុភាគី។ល។ នៅចន្លោះឆ្នាំ ១៩៩១ និង ២០១៧ KOICA បានផ្តល់ជំនួយគិតជាទឹកប្រាក់សរុបប្រមាណ ៦,២៧៥ ពាន់លានវ៉ុន ដល់ ១៥៩ប្រទេស។ មកទល់នឹងពេលបច្ចុប្បន្ននេះ KOICA បានបង្កើតការិយាល័យចំនួន ៤៧ការិយាល័យ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៤៦ប្រទេស នៅទូទាំងពិភពលោក។ ម្យ៉ាងវិញទៀតទីភ្នាក់ងារ KOICA បាននិងកំពុងក្លាយជាវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍ តាមរយៈការបង្កើតភាពជាដៃគូ ជាមួយអ្នកពាក់ព័ន្ធជាច្រើនមាន ក្រសួង ស្ថាប័នសាធារណៈ សង្គមស៊ីវិល អ្នកធុរៈកិច្ច និងអ្នកសិក្សាស្រាវជ្រាវនានា។ ទន្ទឹមនឹងនេះ វាត្រូវបានបង្កើតបណ្តាញទំនាក់ទំនងជាសកល តាមរយៈគម្រោងរួមគ្នាជាមួយភ្នាក់ងារអភិវឌ្ឍន៍របស់អ.ស.ហ.ដើម្បីពង្រឹងជំហរថ្នាក់ជាតិរបស់ប្រទេសកូរ៉េ នៅលើឆាកអន្តរជាតិ។ មួយវិញទៀត KOICA បានចូលរួមជាមួយនឹងសមាគមអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាសកលដូចជា

ភាពក្រីក្រ បរិស្ថាន ប្រជាជន ការរីករាលដាលជំងឺឆ្លងផ្សេងៗ និងបញ្ហាសិទ្ធិមនុស្ស។ ដោយសារការអភិវឌ្ឍនិងលើកកម្ពស់សិទ្ធិមនុស្ស ក្នុងការប្រកួតប្រជែងពិភពលោក និងជួយពង្រីកទីផ្សារក្រៅប្រទេសដោយប្រយោល ដល់អ្នកធុរកិច្ចជនជាតិកូរ៉េ KOICA ក៏កំពុងខិតខំប្រឹងប្រែងបង្កើតទំនាក់ទំនង ប្រកបដោយសុខដុមរមនា និងយ៉ាងជិតស្និតជាមួយប្រទេសដៃគូផងដែរ។

**២.១.១.២.** KOICA **ប្រចាំប្រទេសកម្ពុជា**

នៅឆ្នាំ ១៩៩១ KOICA បានចាប់ផ្តើមកម្មវិធីសហប្រតិបត្តិការរបស់ខ្លួន ដែលបានផ្តល់ជំនួយមនុស្សធម៌ ពោលគឺ គ្រឿងបរិក្ខារការិយាល័យ ដល់ប្រទេសកម្ពុជា ដែលគិតជាទឹកប្រាក់ប្រមាណ USD២២ពាន់ដុល្លារ។ លុះដល់ឆ្នាំ ១៩៩៤ KOICA បានចាប់ផ្តើមអញ្ជើញកម្មសិក្សាការីកម្ពុជា ចូលរួមកម្មវិធីបណ្តុះបណ្តាល ក្នុងគោលបំណងអភិវឌ្ឍន៍ធនធានមនុស្ស សំដៅអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា។ បន្ទាប់មកនៅឆ្នាំ ១៩៩៦ KOICA បានចាប់ផ្តើមបញ្ជូនអ្នកជំនាញមកកាន់ប្រទេសកំពុងអភិវឌ្ឍន៍មួយនេះជាលើកដំបូង។ ដោយឃើញថា កិច្ចសហការអភិវឌ្ឍន៍បានកើនឡើងយ៉ាងឆាប់រហ័ស រវាងប្រទេសទាំងពីរ KOICA ក៏បានបង្កើតការិយាល័យរបស់ខ្លួន នៅរាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៣ ស្របពេលដែលប្រទេសជាម្ចាស់ជំនួយមួយនេះ ចាប់ផ្តើមបញ្ជូនអ្នកស្ម័គ្រចិត្តលើកដំបូងមកប្រទេសកម្ពុជាដែរ។ ក្រោយមក កិច្ចសហប្រតិបត្តិការបានដើរតួនាទីយ៉ាងសំខាន់ ក្នុងទំនាក់ទំនងរវាងប្រជាជនប្រទេសទាំងពីរ តាមរយៈកម្មវិធីអភិវឌ្ឍន៍ជាច្រើន។

**២.១.២. ទីតាំងរបស់ការិយាល័យ** KOICA **ប្រចាំកម្ពុជា**

រូបភាពទី១ ៖ ទីតាំងរបស់ KOICA ប្រចាំកម្ពុជា




(ប្រភព៖ koicacambodia.org)

ការិយាល័យ KOICA ប្រចាំកម្ពុជាជាការិយាល័យមួយក្នុងចំណោមការិយាល័យនៅក្រៅប្រទេសទាំង ៤៧ របស់ KOICA។ ការិយាល័យ KOICA បានផ្លាស់ប្តូរទីតាំងរបស់ខ្លួនកាលពីឆ្នាំ ២០១៨ មកតាំងទីនៅអាគារបូរីគ្រា ជាន់ទី៤ ដែលមានអាស័យដ្ឋាននៅផ្ទះលេខ៦១-៦៤ មហាវិថីព្រះនរោត្តម (ផ្លូវលេខ៤១) កែងផ្លូវ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**២.១.៣. ចក្ខុវិស័យ និងបេសកកម្ម**

**២.១.៣.១.** KOICA **ការិយាល័យកណ្តាល**

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ បានបង្កើតឡើងអស់រយៈពេលជិត ២០ឆ្នាំមកហើយ ដែលបានផ្តល់នូវកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាដៃគូជាច្រើន។ ជារួមនៃកិច្ចសហប្រតិបត្តិការទាំងនោះ KOICA បានបង្កើតចក្ខុវិស័យ និងបេសកកម្មក្នុងការបំពេញ ដើម្បីសម្រេចឲ្យបានភាពជោគជ័យដូចខាងក្រោម ៖

– **ចក្ខុវិស័យ ៖** ការបំពេញភារៈកិច្ច ជាវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍ ទាំងក្នុងប្រទេសនិងអន្តរជាតិ ដើម្បីរួមចំណែកក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព (SDGs)។
– **បេសកកម្ម ៖** ការលើកកម្ពស់ទំនាក់ទំនងសម្ព័ន្ធមិត្ត កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរបទពិសោធអភិវឌ្ឍន៍ តាមរយៈការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

✍ គួរបញ្ជាក់ផងដែរថា ទិសដៅរបស់អង្គភាពមួយនេះ កំពុងពង្រឹងសមត្ថភាពក្នុងការសម្រេចឲ្យបាននូវ SDGs រួមទាំងប្រសិទ្ធភាពនិងការគ្រប់គ្រងដោយអ្នកប្រើប្រាស់ចុងក្រោយ ការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាព ដែលអាចពឹងផ្អែកលើខ្លួនឯងបាន របស់ប្រទេសកំពុងអភិវឌ្ឍន៍ និងបង្កើនចំនួនដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍។

**២.១.៣.២.** KOICA **លើវិស័យអប់រំ**

ប្រទេសកូរ៉េមានចក្ខុវិស័យ និងបេសកកម្មលើវិស័យអប់រំដើម្បីជំរុញលទ្ធភាពនៃការទទួលបានការអប់រំរបស់ប្រទេសជាដៃគូដូចតទៅ ៖

– **ចក្ខុវិស័យ ៖** ការអភិវឌ្ឍរួមគ្នាតាមរយៈការអប់រំប្រកបដោយគុណភាព។
– **បេសកកម្ម ៖** ដើម្បីធានាសិទ្ធិទទួលបានការអប់រំសម្រាប់មនុស្សគ្រប់គ្នា ដោយពង្រឹងប្រព័ន្ធអប់រំនៅក្នុងប្រទេសជាដៃគូអភិវឌ្ឍន៍ ព្រមទាំងលើកទឹកចិត្តឲ្យមានការចូលរួមពីសំណាក់ភាគីដែលពាក់ព័ន្ធផ្សេងទៀត។

## ២.១.៤. រចនាសម្ព័ន្ធគ្រប់គ្រង[24]




*(ប្រភព ៖ OECD Development Co-operation Peer Reviews KOREA 2018)*

## ២.២. យុទ្ធសាស្ត្រភាពជាដៃគូរបស់សាធារណៈរដ្ឋកូរ៉េសម្រាប់ព្រះរាជាណាចក្រកម្ពុជា[25]

សេចក្ដីសង្ខេបខ្លឹមសារ នៃយុទ្ធសាស្ត្រភាពជាដៃគូមានដូចតទៅ ៖

| **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣** |
|---|
| យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ រួមបញ្ចូលការអភិវឌ្ឍវិស័យដូចជា កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍវិស័យឯកជននិងការងារ និងការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស |

| **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់កម្ពុជា** (NSDP) **ឆ្នាំ ២០១៤ - ២០១៨** |
|---|
| ស្របទៅនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់យុទ្ធសាស្ត្រដំណាក់កាលទី ៣ NSDP បានផ្តោតសំខាន់លើអនុវិស័យចំនួន ៤ នៃគោលដៅអាទិភាពទី ២ រួមមាន (១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងការដឹកជញ្ជូន (២) ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ (៣) ការអភិវឌ្ឍថាមពលអគ្គីសនី (៤) ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) |

| **កម្មវត្ថុនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សាធារណៈរដ្ឋកូរ៉េសម្រាប់ព្រះរាជាណាចក្រកម្ពុជា** |
|---|
| រដ្ឋាភិបាលកូរ៉េនឹងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ និងផែនការ |

[24] ឧបសម្ព័ន្ធ

[25] ឧបសម្ព័ន្ធ

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដោយផ្តោតលើគោលបំណងដូចខាងក្រោម ៖

- ការសាងសង់និងពិគ្រោះយោបល់លើបណ្តាញផ្លូវថ្នល់ ហេដ្ឋារចនាសម្ព័ន្ធព្រលានយន្តហោះ និងកំពង់ផែ
- កសាងសមត្ថភាពក្នុងការគ្រប់គ្រងធនធានទឹក និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ព្រមទាំងពង្រីកសេវាកម្មសុខភាពជាសាកល
- ការកែលម្អ និងការបង្កើតប្រព័ន្ធការអប់រំដើម្បីការអភិវឌ្ឍធនធានមនុស្ស
- ការអភិវឌ្ឍជនបទ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ប្រាក់ចំណូល និងការយល់ដឹងជាសាធារណៈរបស់ប្រជាជន

**វិស័យ សហប្រតិបត្តិការ អាទិភាព និង ផែនការគាំទ្រ**

**ការដឹកជញ្ជូន**

- គាំទ្រការពង្រីកនិងការស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- គាំទ្រដល់ការសាងសង់និងការពិគ្រោះយោបល់លើព្រលានយន្តហោះនិងកំពង់ផែ

**ការគ្រប់គ្រងទឹក និងសុខភាពសាធារណៈ**

- គាំទ្រការពង្រឹងសមត្ថភាព គ្រប់គ្រងធនធានទឹក និងឆ្លើយតបនឹងគ្រោះមហន្តរាយ
- គាំទ្រការធ្វើឲ្យប្រសើរឡើងសេវាសុខភាពសាធារណៈ

**ការអប់រំ**

- គាំទ្រគុណភាព និងលទ្ធភាពទទួលបានការអប់រំ
- គាំទ្រឱកាសអប់រំសម្រាប់កុមារ និងស្ត្រី

**ការអភិវឌ្ឍជនបទ**

- គាំទ្រការអភិវឌ្ឍជនបទដែលផ្តោតសំខាន់លើស្ថានភាពរស់នៅ ការបង្កើនប្រាក់ចំណូល និងការយល់ដឹងសាធារណៈ
- គាំទ្រផ្នែកផ្លូវឆ្លងកាត់នៅតំបន់ជនបទ

(ប្រភព ៖ The Republic of Korea's Country Partnership Strategy for the Kingdom of Cambodia 2016 – 2020)

យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស (CPS) កំណត់នូវវិស័យសហប្រតិបត្តិការអាទិភាព ដោយមិនឲ្យប៉ះពាល់ដល់ឱកាសសហប្រតិបត្តិការលើគម្រោងក្នុងវិស័យដទៃទៀត ដែលបានព្រមព្រៀងគ្នារវាងរដ្ឋាភិបាលកម្ពុជា និងកូរ៉េ។ ដោយផ្អែកលើការអភិវឌ្ឍចាំបាច់ដែលត្រូវបានកំណត់ដោយ រដ្ឋាភិបាលកូរ៉េបានព្រាងយុទ្ធសាស្ត្រអនុវត្តលើវិស័យសហប្រតិបត្តិអាទិភាព និងប្រភេទនៃកិច្ចសហប្រតិបត្តិការដូចជា សហប្រតិបត្តិការបច្ចេកទេសនិងហិរញ្ញវត្ថុ ភាពជាដៃគូសាធារណៈ និងឯកជន និងកិច្ចសហប្រតិបត្តិការត្រីភាគី។

ដោយផ្អែកលើការយោគយល់ និងការគោរពគ្នាទៅវិញទៅមក ប្រទេសកូរ៉េនឹងប្រឹងប្រែងដើម្បីការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព តាមរយៈបទពិសោធអភិវឌ្ឍន៍ និងផលប្រយោជន៍ផ្សេងទៀតរបស់ខ្លួន ព្រមទាំងផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤ - ២០១៨។

១. **ចក្ខុវិស័យ ៖** សាធារណៈរដ្ឋកូរ៉េនឹងគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយអភិវឌ្ឍឧស្សាហកម្ម (IDP)។

២. **វិស័យអាទិភាព ៖** វិស័យអាទិភាពត្រូវបានជ្រើសរើសដោយផ្អែកលើការអភិវឌ្ឍចាំបាច់ដែលមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិរបស់ប្រទេសកម្ពុជា ក៏ដូចជាផលប្រយោជន៍ទាក់ទងនឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ជាមួយនឹងម្ចាស់ជំនួយ និងកិច្ចពិភាក្សាទៅលើគោលនយោបាយទ្វេភាគីរបស់កូរ៉េ។

- **វិស័យដឹកជញ្ជូន** ៖ រួមទាំងការសាងសង់ និងការពិគ្រោះយោបល់ ទៅលើបណ្តាញផ្លូវថ្នល់ ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និងកំពង់ផែ។
- **វិស័យគ្រប់គ្រងធនធានទឹក និងសុខភាពសាធារណៈ ៖** រួមទាំងការកសាងសមត្ថភាពក្នុងការគ្រប់គ្រងធនធានទឹក និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ព្រមទាំងការពង្រីកការផ្តល់សេវាសុខភាពទូទៅ។
- **វិស័យអប់រំ ៖** រួមទាំងការកែលម្អ និងការបង្កើតប្រព័ន្ធអប់រំដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស។
- **វិស័យអភិវឌ្ឍន៍ជនបទ៖** រួមទាំងការអភិវឌ្ឍជនបទដើម្បីបង្កើនជីវភាពរស់នៅ ប្រាក់ចំណូល និងកម្រិតការយល់ដឹងសាធារណៈរបស់ប្រជាជន។

៣. **យុទ្ធសាស្ត្រអនុវត្តន៍ ៖** ប្រសិទ្ធភាព និរន្តភាព និងសុខដុមនីយកម្ម ជាគុណតម្លៃបី ដែលនឹងត្រូវសង្កត់ធ្ងន់ក្នុងការបង្កើនប្រសិទ្ធភាពនៃគម្រោងជំនួយដល់ប្រទេសកម្ពុជា។

៤. **មូលដ្ឋានគ្រឹះយុទ្ធសាស្ត្រ ៖** ដំណើរការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវតែស្របតាមគោលការណ៍ប្រសិទ្ធភាពនៃជំនួយ ឆ្លុះបញ្ចាំងពីបទដ្ឋាននិងស្តង់ដារអន្តរជាតិរួមទាំងSDGs កិច្ចព្រមព្រៀងភាពជាដៃគូប៊ូសាន អនុសាសន៍របស់DAC និងយុទ្ធសាស្ត្រដើម្បីវឌ្ឍនភាព ODA។

## ២.៣. គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍ប្រទេសកម្ពុជា ( CRDB/CDC )

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) មានគណៈកម្មាធិការពីរគឺ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (CRDB) និងគណៈកម្មាធិការវិនិយោគកម្ពុជា។ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិឌ្ឍន៍កម្ពុជា គឺជាស្ថាប័នស្នូលរបស់រាជរដ្ឋាភិបាល សម្រាប់កៀរគរជំនួយអភិវឌ្ឍន៍ផ្លូវការ ធ្វើការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ (រួមមានដៃគូរអភិវឌ្ឍន៍

ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) និងសម្របសម្រួលជាមួយក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងការតម្រង់ទិសបែងចែក និងប្រើប្រាស់ជំនួយ។

អនុលោមតាមមាត្រា១៣ នៃអនុក្រឹត្យលេខ ១៤៧អនក្រ. បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥ តួនាទីនិងភារកិច្ចរបស់ CRDB នៅក្នុងកិច្ចការវិនិយោគសាធារណៈ មានដូចតទៅៈ

ក. ធ្វើជា "ចំណុចប្រមូលផ្តុំ" និងជា "ច្រកចេញ-ចូលតែមួយ" នៅក្នុងទំនាក់ទំនងរវាងរាជរដ្ឋាភិបាលជាមួយនឹងប្រទេស អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលផ្តល់ជំនួយដល់កម្ពុជានិងជា "ចំណុចប្រមូលផ្តុំ" និងជា "ច្រកចេញ-ចូលតែមួយ" ក្នុងទំនាក់ទំនងរវាងក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួលជំនួយ និង/ឬការបែងចែកជំនួយ។

ខ. តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាល ជាមួយនឹងអ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគី និង/ឬបែងចែកជំនួយ។

គ. សហការជាមួយនឹងបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធ ដឹកនាំការរៀបចំឯកសារ ដែលចាំបាច់សម្រាប់កិច្ចប្រជុំអន្តរជាតិសម្រាប់កសាងប្រទេសកម្ពុជាឡើងវិញ ដូចជា "ក្រុមពិគ្រោះយោបល់សម្រាប់កម្ពុជា" ជាដើម។

## ២.៤. នីតិវិធីនៃការស្នើជំនួយលើគម្រោង និងវដ្តនៃការអនុម័តគម្រោងពី KOICA

### ២.៤.១. នីតិវិធីនៃការស្នើជំនួយលើគម្រោងពី KOICA

| នីតិវិធី | សេចក្តីលម្អិត |
|---|---|
| ជំហានទី ១៖ កំណត់គម្រោងដែលមានតម្រូវការ | ក្រសួងនិងទីភ្នាក់ងារដែលពាក់ព័ន្ធនៅកម្ពុជា ត្រូវការពិនិត្យឡើងវិញនូវគម្រោងអាទិភាព [26] សម្រាប់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួនពួកគេ និងកំណត់គម្រោងឬវិស័យជាក់លាក់ដោយខ្លួនឯង។ |

| | |
|---|---|
| ជំហានទី ២៖ បង្កើតវិសាលភាពការងារគម្រោង/កម្មវិធី | បើសិនគម្រោង/កម្មវិធី ឬវិស័យជាក់លាក់ ត្រូវបានជ្រើសរើស ក្រសួងនិងទីភ្នាក់ងារពាក់ព័ន្ធនៅកម្ពុជា ត្រូវទាមទារឲ្យរៀបចំសំណើ ដែលរួមមានទំហំថវិកា វិសាលភាពការងារជាដើម ដោយមានការពិគ្រោះយោបល់ជាមួយ ការិយាល័យ KOICA |

[26] ឧបសម្ព័ន្ធ

| | |
|---|---|
| | ប្រចាំប្រទេសកម្ពុជា អំពីសំណុំបែបបទឯកសារគោលគំនិតគម្រោង (PCP)។[27] ការបំពេញសំណុំបែបបទទាំងនេះ ទាមទារការផ្តល់ជូនព័ត៌មានឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ដើម្បីឲ្យ KOICA ធ្វើការស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីតម្រូវការ និងសំណើនេះ។ |

| | |
|---|---|
| ជំហានទី 3៖ ដាក់ជូនសំណើគម្រោង/កម្មវិធីរបស់អ្នក | សំណុំបែបបទដែលបានរៀបរាប់ខាងលើ ត្រូវផ្តល់ជូន KOICA ប្រចាំកម្ពុជា តាមរយៈបណ្តាញផ្លូវការនិងការទូត។ ចាប់តាំងពី KOICA ផ្តល់ជូនគម្រោង/កម្មវិធីសហប្រតិបត្តិការ ដោយផ្អែកលើគោលការណ៍ សំណើរបស់រាជរដ្ឋាភិបាល ក្រសួង និង ទីភ្នាក់ងារពាក់ព័ន្ធនៅកម្ពុជា បានទទួលជំហានល្អៗ ពីការផ្តល់ជូនសំណុំបែបបទស្នើសុំរបស់ខ្លួន ទៅការិយាល័យ KOICA ប្រចាំកម្ពុជា តាមរយៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MFA.IC) នៃព្រះរាជាណាចក្រកម្ពុជា។ នីតិវិធីនេះ ជាការគោរពតួនាទីរបស់រដ្ឋាភិបាលកម្ពុជា ក្នុងភាពជាម្ចាស់កម្មសិទ្ធិ និងសម្របសម្រួលគម្រោង/កម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលអនុវត្តនៅតំបន់របស់ខ្លួន។ សំណើគម្រោងនឹងត្រូវពិនិត្យឡើងវិញជាលើកដំបូងនៅការិយាល័យ KOICA ប្រចាំកម្ពុជា ហើយបញ្ជូនទៅទីស្នាក់ការកណ្តាលរបស់ KOICA ដើម្បីសិក្សាបន្ថែមទៀតលើភាពសមស្របរបស់គម្រោង។ |

*(ប្រភព ៖ KOICA Cambodia)*

### ២.៤.២. វដ្តគម្រោងជំនួយឥតសំណងរបស់ KOICA

| | |
|---|---|
| **១. ដំណើរការ** | • ការជួបពិភាក្សាជាមួយដៃគូរដ្ឋាភិបាលលើការកំណត់អត្តសញ្ញាណនៃគម្រោង<br>• ការដាក់សំណើគម្រោងផ្លូវការដោយដៃគូរដ្ឋាភិបាលជាដៃគូដើម្បីការិយាល័យ KOICA នៅបរទេស |

[27] ឧបសម្ព័ន្ធ

| | |
|---|---|
| | • គម្រោងត្រូវបានត្រួតពិនិត្យដោយ KOICA នៅបរទេស |
| | • ការពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនៅប្រទេសកូរ៉េ ដោយក្រសួងការបរទេស និងពាណិជ្ជកម្ម (MOFAT) និង KOICA |
| | • ការបញ្ជូនអ្នកជំនាញដើម្បីបង្កើតគម្រោងដោយ KOICA ការិយាល័យកណ្តាល<br>• ការសិក្សាលើលទ្ធភាពនៃគម្រោង |
| **២. ផែនការគម្រោង** | • ពិនិត្យ និងរៀបចំផែនការគម្រោងដោយ KOICA ការិយាល័យកណ្តាល |
| | • រៀបចំគណៈគម្មាធិការពិគ្រោះយោបល់លើគម្រោងនីមួយៗដោយ KOICA ការិយាល័យកណ្តាល |
| **៣. ការសម្របសម្រួលគម្រោង** | • ការដាក់បញ្ជូបផែនការគម្រោងទៅ MOFAT ដោយ KOICA |
| | • ការកែសម្រួលគម្រោងដែលច្រំដែលរបស់ក្រសួង និងទីភ្នាក់ងារដែលពាក់ព័ន្ធដោយ MOFAT |
| **៤. ផែនការថវិកា** | • ការវិភាគថវិកាដោយ MOSF |
| | • ការដាក់សំណើថវិកាទៅកាន់រដ្ឋសភា |
| | • ការពិចារណាលើសំណើថវិការបស់រដ្ឋសភា |
| | • ការអនុម័តថវិកាដោយរដ្ឋសភា |
| **៥. ការអនុម័ត** | • ការដាក់ផែនការជំនួយឥតសំណងប្រចាំឆ្នាំ ដល់គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (CIDC) |
| | • ការបញ្ចប់គម្រោងផែនការដោយ CIDC |
| | • ការអនុម័តផែនការគម្រោងរបស់ KOICA ប្រចាំឆ្នាំដោយ MOFAT |
| | • ការជូនដំណឹងអំពីផែនការគម្រោង KOICA ទៅដៃគូរដ្ឋាភិបាល |
| **៦. ការអនុវត្តគម្រោង** | • ការរៀបចំអ្នកទទួលការងារគម្រោង |
| | • ការអញ្ជើញសិក្ខាកាម បញ្ជូនអ្នកជំនាញ ការសាងសង់។ល។ |
| **៧. ការវាយតម្លៃ និងការគ្រប់គ្រងគម្រោងដែលបញ្ចប់** | • ការត្រួតពិនិត្យ និងការវាយតម្លៃគម្រោង (ការវាយតម្លៃបណ្តោះអាសន្ន ការបញ្ចប់ការវាយតម្លៃនៃគម្រោង និងការវាយតម្លៃគម្រោងដែលបានបញ្ចប់) |
| | • ការគ្រប់គ្រងគម្រោងដែលបានបញ្ចប់ |

(ប្រភព ៖ www.odakorea.go.kr )

## ២.៥. ជំនួយឥតសំណងលើវិស័យអប់រំកម្ពុជាតាមរយៈ KOICA

ចាប់តាំងពីបង្កើត KOICA តាំងពីឆ្នាំ ១៩៩១មក ប្រទេសកូរ៉េបានផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការជាច្រើនដល់ប្រទេសកម្ពុជា ប៉ុន្តែចំពោះការផ្តល់ជំនួយលើការអភិវឌ្ឍធនធានមនុស្សវិញ ទើបតែមាននៅក្នុងឆ្នាំ ១៩៩៩ទេ។ ជាការពិតណាស់ ការផ្តល់ជំនួយប្រភេទនេះ មានគោលបំណងធំបំផុតគឺដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សនៅកម្ពុជា ពោលគឺធ្វើយ៉ាងណាឲ្យអ្នកទាំងនោះមានសមត្ថភាពនិងលទ្ធភាពខ្ពស់ ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមនៅក្នុងប្រទេស នេះ។ គោលដៅចម្បងមួយដែលរដ្ឋាភិបាលកូរ៉េ បាននិងកំពុងជួយដល់ការអភិវឌ្ឍធនធានមនុស្សនោះគឺ ការផ្តល់កម្មវិធីបណ្តុះបណ្តាល ដែលមានទីភ្នាក់ងារ KOICA ជាអ្នកទទួលបន្ទុកអនុវត្តផែនការ និងសម្របសម្រួល។

### ២.៥.១. ជំនួយជាសម្ភារ ឧបករណ៍សិក្សា

#### ក. ការឧបត្ថម្ភសៀវភៅ

កាលពីឆ្នាំ ២០១៣ KOICA បានឧបត្ថម្ភសៀវភៅចំនួន ១៥០ក្បាលដល់បណ្ណាល័យរបស់វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI) ។ សៀវភៅទាំងនេះមាន ៩៩ក្បាលជាសៀវភៅផ្នែកវិស្វកម្មសំណង់ស៊ីវិល(ជាភាសាអង់គ្លេស) និងសៀវភៅជាភាសាកូរ៉េចំនួន ៥១ក្បាល ដែលគិតជាទឹកប្រាក់សរុបចំនួន ១៩ ៧២៥ដុល្លារសហរដ្ឋអាមេរិក។

#### ខ. ការផ្គត់ផ្គង់សម្ភារបង្រៀន

នៅឆ្នាំ ២០១៥ KOICA បានផ្គត់ផ្គង់សម្ភារបង្រៀន និងគ្រឿងបរិក្ខារទំនើបៗដល់ CKCC ក្នុងគោលបំណងបង្កើនភាពប្រកួតប្រជែងថ្នាក់ជាតិ តាមរយៈកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងមជ្ឈមណ្ឌលមួយនេះ។ គម្រោងនៃការផ្តល់ជូនសម្ភារនេះ បានចំណាយអស់ថវិកាចំនួន USD ៧៩៥ ០០០ ដុល្លារ ។

#### គ. ការផ្តល់គ្រឿងសម្ភារបរិក្ខារោងជាង និងម៉ាស៊ីនកសិកម្ម

កាលពីថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៨ KOICA បានផ្តល់ជំនួយគ្រឿងសម្ភារបរិក្ខាររោងជាង និងម៉ាស៊ីនកសិកម្មដល់សាកលវិទ្យាល័យភូមិន្ទកសិកម្ម។ សម្ភារបរិក្ខារ និងម៉ាស៊ីនកសិកម្មដែលនឹងត្រូវប្រគល់ជូនសាកលវិទ្យាល័យរួមមាន៖ ម៉ាស៊ីនម៉ាស៊្លូតចំនួន ៥គ្រឿង ម៉ាស៊ីនស្លុង ១គ្រឿង ម៉ាស៊ីនពូនរង និងគ្របប្លាស្ទិក ១គ្រឿង ម៉ាស៊ីនពត់បំពង់ទីប ១គ្រឿង តុសម្រាប់ជួសជុលម៉ាស៊ីនចំនួន៥គ្រឿង សម្ភារជួសជុល ៥២១មុខ និងបានជួសជុលលាបថ្នាំ ព្រមទាំងសាងសង់នូវជណ្តើរជូនមហាវិទ្យាល័យផងដែរ។ គួរបញ្ជាក់ផងដែរថា លោក Jo Kue Won អ្នកជំនាញការ

KOICA ប្រចាំនៅ មហាវិទ្យាល័យវិស្វកម្មកសិកម្មនៃសាកលវិទ្យាល័យមួយនេះ ជាអ្នកជួយលើគម្រោងស្នើសុំទៅ KOICA ដើម្បីទទួលបានគ្រឿងសម្ភារកសិកម្មមួយចំនួនជូនមហាវិទ្យាល័យ។

**ឃ. ការផ្តល់សម្ភារហ្វឹកហាត់តៃក្វាន់ដូ**

កាលពីថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៩ KOICA បានផ្តល់ឧបករណ៍ការពារស្មង ការពារប្រអប់ជើង ម៉ាស់ពាក់ដើមទ្រូងសម្រាប់ពេលប្រកួត និងឧបករណ៍សម្រាប់ទាត់ចំនួន ១០០ សម្រាប់ ដល់ វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

**២.៥.២. ជំនួយលើគម្រោងការអប់រំ**

**២.៥.២.១. គម្រោងអប់រំទ្វេភាគីទូទៅ**

**ក. គម្រោងបង្កើតក្របខណ្ឌគុណវុឌ្ឍិថ្នាក់ជាតិនៅកម្ពុជា**

គម្រោងនេះមានរយៈពេល ២ឆ្នាំ ដែលចាប់ផ្តើមតាំងពីខែមីនា ឆ្នាំ២០០៧ ដល់ខែកុម្ភៈ ឆ្នាំ ២០០៩ បានចំណាយទឹកប្រាក់សរុប USD ១,២លានដុល្លារ។ គោលបំណងនៃគម្រោងនេះគឺ ៖

- អភិវឌ្ឍន៍គុណវុឌ្ឍិនៃអ្នកជំនាញបច្ចេកទេស ឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច
- ប្រឹក្សាយោបល់លើការរៀបចំ និងអនុវត្តន៍ប្រព័ន្ធគុណវុឌ្ឍិវិជ្ជាជីវៈថ្នាក់ជាតិ សម្រាប់ TVET នៅកម្ពុជា (សំដៅដល់ "ផែនការមេ") ។

**ខ. គម្រោងពង្រឹងសមត្ថភាព CLMV សម្រាប់សាកលវិទ្យាល័យអ៊ិនធឺរៀអាស៊ាន**

គម្រោងដែលបានចំណាយទឹកប្រាក់អស់ ១លានដុល្លារមួយនេះ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់លេខាធិការដ្ឋានអាស៊ាន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន-កូរ៉េ កាលពីឆ្នាំ ២០០៩ នៅប្រទេសកូរ៉េ ក្នុងគោលបំណងកសាងសមត្ថភាពធនធានមនុស្សផ្នែក ICT នៅប្រទេសកម្ពុជា តាមរយៈការបង្កើតមជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិចនៅ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ព្រមទាំងការផ្ទេរចំណេះដឹង ក៏ដូចជាបទពិសោធនានារបស់កូរ៉េ ដើម្បីរួមចំណែកកាត់បន្ថយគម្លាតបច្ចេកវិទ្យាឌីជីថល។

ក្នុងអំឡុងពេល ៣ឆ្នាំដែលគិតចាប់ឆ្នាំ ២០១០-២០១២ គម្រោងនេះមានចំនួន ៤ផែនការដូចខាងក្រោម៖

១. បង្កើតមជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិចដែលមានប្រព័ន្ធគ្រប់គ្រងការសិក្សា និងកម្មវិធីសិក្សាអេឡិចត្រូនិចនៅ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

២. ផ្គត់ផ្គង់សម្ភារ និងឧបករណ៍ចាប់បាច់សម្រាប់ការអនុវត្តគម្រោង។

៣. អញ្ជើញមន្ត្រី និងអ្នកដែលពាក់ព័ន្ធនានាទៅប្រទេសកូរ៉េ ដើម្បីទទួលបានចំណេះដឹង និងបទពិសោធពីការគ្រប់គ្រងនិងការអភិវឌ្ឍការសិក្សាអេឡិចត្រូនិច។

៤. បញ្ជូនអ្នកឯកទេសកូរ៉េមកកាន់ប្រទេសកម្ពុជា ដើម្បីរៀបចំសកម្មភាពគ្រប់គ្រងនិងផ្តល់ការណែនាំបច្ចេកទេសលើការអនុវត្តគម្រោង។

គួរបញ្ជាក់ផងដែរថា ការពង្រឹងសមត្ថភាព CLMV នៃសាកលវិទ្យាល័យអ៊ិនធឺរៀអាស៊ាន គឺជាកត្តាដ៏សំខាន់ដើម្បីឲ្យ ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ទទួលបាននូវបច្ចេកទេស និងចំណេះដឹងពាក់ព័ន្ធទៅនឹងអេឡិចត្រូនិច ព្រមទាំងលើកកម្ពស់សាកលវិទ្យាល័យអ៊ីនធឺរៀ ដើម្បីឆ្ពោះទៅរកការអប់រំប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ដូចបណ្តាប្រទេសដទៃទៀតក្នុងតំបន់អាស៊ាន។ លើសពីនេះទៅទៀត គម្រោងនេះក៏បានក្លាយជាឱកាសដ៏វិសេសវិសាលមួយ សម្រាប់ប្រទេសកូរ៉េ ដើម្បីចែករំលែកបទពិសោធនិងចំណេះដឹង ដែលខ្លួនមានទៅលើការអភិវឌ្ឍប្រព័ន្ធសិក្សាអេឡិចត្រូនិចជាមួយប្រទេសទាំង ៤ នេះ ស្របពេលដែលប្រទេសកូរ៉េអាចធ្វើការជំរុញភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំផងដែរ។

### គ. គម្រោងអភិវឌ្ឍន៍ផ្នែកបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ

KOICA បានអនុវត្តគម្រោងអភិវឌ្ឍការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិកាលពីឆ្នាំ២០១៣។ ក្របខ័ណ្ឌនៃគម្រោងសហប្រតិបត្តិការអប់រំបច្ចេកទេសនេះ រដ្ឋាភិបាលកូរ៉េបានផ្តល់ជំនួយជាថវិកា តាមរយៈ KOICA ចំនួន USD ២លានដុល្លារ សម្រាប់ការអនុវត្តគម្រោងរយៈពេល ១៨ខែ ចាប់ពីឆ្នាំ ២០១៣-២០១៤ ហើយគម្រោងនេះផ្តោតសំខាន់លើការងារដូចខាងក្រោម ៖

- ការកសាងផែនការមេ និងផែនការសកម្មភាព
- ការរៀបចំកម្មវិធី និងសៀវភៅសិក្សា
- ការបណ្តុះបណ្តាលគ្រូនៅក្នុងប្រទេសកម្ពុជា និងនៅសាធារណរដ្ឋកូរ៉េ
- កម្មវិធីទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ
- ការអភិវឌ្ឍសមត្ថភាពមន្ត្រីផ្នែកអប់រំបច្ចេកទេស តាមរយៈសិក្ខាសាលា
- ការវាយតម្លៃ ។

គម្រោងនេះ ត្រូវបានចាប់ផ្តើមអនុវត្តកម្មវិធីសាកល្បងនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ឆ្នាំង។ ហេតុនេះ វាជាការរួមចំណែកការអភិវឌ្ឍលើវិស័យអប់រំកម្ពុជាប្រកបដោយគុណភាព និងប្រសិទ្ធភាព ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគត។

**២.៥.២.២. គម្រោងសាងសង់អគារសិក្សា**

**ក. គម្រោងអគារមជ្ឈមណ្ឌលសហប្រតិបត្តិការមិត្តភាព កម្ពុជា-កូរ៉េ** (CKCC)

នៅឆ្នាំ ២០១៣ អគារមជ្ឈមណ្ឌលសហប្រតិបត្តិការមិត្តភាព កម្ពុជា-កូរ៉េ ដែលមានទីតាំងនៅក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវបានដាក់ឲ្យប្រើប្រាស់ផ្លូវការ។ បន្ទាប់ពីបានចុះហត្ថលេខាលើកំណត់កិច្ចពិភាក្សាស្តីពី ការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេសកម្ពុជា រវាងក្រសួងអប់រំ យុវជន និងកីឡា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ រួចមក អគារមជ្ឈមណ្ឌលនេះ បានចាប់ផ្តើមសាងសង់នៅខែតុលា ឆ្នាំ២០១១ និងបានបញ្ចប់ការសាងសង់រួចរាល់ជាស្ថាពរនៅខែឧសភា ឆ្នាំ២០១៣ លើផ្ទៃដី ៥ ៥៥៧ ម៉ែត្រការ៉េ ជាអគារថ្ម ១ខ្នង កម្ពស់ ៣ ជាន់ ចែកចេញជា បន្ទប់សាស្ត្រាចារ្យចំនួន៣ បន្ទប់សិក្សាចំនួន៧ បន្ទប់កុំព្យូទ័រចំនួន៣ ដែលមានកុំព្យូទ័រចំនួន ៧០គ្រឿង បន្ទប់សោតទស្សន៍ចំនួន ១ បន្ទប់ប្រជុំចំនួន១ បន្ទប់ប្រឹក្សាយោបល់ចំនួន១ បន្ទប់ការិយាល័យចំនួន ៥ សាលពហុប្រយោជន៍ចំនួន១ ដែលអាចទទួលអ្នកចូលរួមបានចំនួន ៦៥០នាក់ បណ្ណាល័យចំនួន១ បន្ទប់សិក្ខាសាលាចំនួន២ ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យអភិវឌ្ឍន៍នូវកម្មវិធីសិក្សា ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស ការិយាល័យទំនាក់ទំនងវប្បធម៌ ព្រមទាំងអាហារដ្ឋានចំនួន១ និងចំណតរថយន្ត ដែលចំណាយថវិកាសរុប USD ៧ ៩៥០ ០០០ ដុល្លារ។ គោលបំណងនៃអគារមជ្ឈមណ្ឌលនេះ គឺដើម្បីរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស និងពង្រឹងគុណភាពអប់រំនៅកម្ពុជា ពង្រីកការកសាងសមត្ថភាព វិជ្ជាជីវៈ ចំណេះដឹងសាស្ត្រាចារ្យ មន្ត្រីអប់រំ និងនិស្សិត តាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លីលើជំនាញបច្ចេកវិទ្យាព័ត៌មាន កម្មវិធីបង្ហាញវប្បធម៌របស់ប្រទេសទាំងពីរ កម្ពុជា-កូរ៉េ ព្រមទាំងផ្តល់ការប្រឹក្សាអំពីការសិក្សានៅសាធារណរដ្ឋកូរ៉េផងដែរ។

**ខ. គម្រោងអគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរណ៍ស៊ីវិល** (CATC)

KOICA បានបញ្ចប់គម្រោង និងប្រគល់អគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរណ៍ស៊ីវិលដំបូងតម្លៃ USD ១០,១លានដុល្លារ ដល់កម្ពុជា ដើម្បីបណ្តុះបណ្តាលធនធានមនុស្សបំរើឲ្យវិស័យអាកាសចរណ៍នៅកម្ពុជា។ ការណ៍នេះ ជាលើកដំបូងរបស់ប្រទេសកម្ពុជា ដែលទទួលបាននូវមជ្ឈមណ្ឌលបណ្តុះបណ្តាលអាកាសចរណ៍ស៊ីវិលជារបស់ខ្លួន។ គម្រោងសាងសង់អគារនេះ ត្រូវបានអនុវត្តន៍អស់រយៈពេល ៥ឆ្នាំ គិតចាប់ពីឆ្នាំ ២០១៣-២០១៨ ដែលត្រូវបានសាងសង់នៅក្នុងបរិវេនអាកាសយានដ្ឋានភ្នំពេញ លើក្រលាផ្ទៃ ២ ៧០០ ម៉ែត្រការ៉េ ដែលមានចំនួនបួនជាន់ (រួម

ទាំងជាន់ផ្ទាល់ដី) ក្នុងនោះមានដូចជា ការិយាល័យគ្រប់គ្រង ការិយាល័យអប់រំ ការិយាល័យផ្តល់សេវាកម្ម និង ទីកន្លែងសាធារណៈផ្សេងៗ ហើយនិងបំពាក់គ្រឿងបរិក្ខាទំនើបៗទៀតផង។

គួររំលឹកផងដែរថា ការបណ្តុះបណ្តាលធនធានមនុស្សបំរើឲ្យវិស័យអាកាសចរណ៍ស៊ីវិលកន្លងមក ប្រទេសកម្ពុជាតែងបញ្ជូនអ្នកសិក្សាទៅក្រៅប្រទេស ដែលចំណាយធនធានច្រើននិងមានចំនួនតិចតួចនៅឡើយ។ ម្យ៉ាងទៀត ធនធានមនុស្សដែលទទួលការបណ្តុះបណ្តាលកន្លងទៅ មានវ័យចំណាស់ និងចូលនិវត្តន៍ជាបន្តបន្ទាប់។ តែពេលនេះ កម្ពុជាអាចបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យនេះ ក្នុងប្រទេសបានហើយ ដែលនេះ ជាប្រវត្តិសាស្ត្រថ្មីមួយទៀត ។

**គ. គម្រោងសាលហ្វឹកហាត់តៃក្វាន់ដូ កម្ពុជា-កូរ៉េ** (CKTTC)

សាលហ្វឹកហាត់មួយនេះ ជាគម្រោងរបស់អ្នកស្ម័គ្រចិត្តមិត្តភក្តិពិភពលោកកូរ៉េ ដែលបានចាប់ផ្តើមការសាងសង់កាលពីខែ កញ្ញា ឆ្នាំ ២០១៦ និងបញ្ចប់នៅខែ ធ្នូ ឆ្នាំ ដដែល។ សាលមួយនេះមានទំហំ ១២មX១៧ម ដែលសាងសង់ក្នុងវិទ្យាស្ថានជាតិអប់រំ និងកីឡា (NIPES) ។ គម្រោងនេះចំណាយថវិកាសរុបចំនួន USD ៧១ ០៧៥ ដុល្លារ ដែលជាជំនួយឥតសំណងរបស់ KOICA ប្រចាំកម្ពុជា។ សាលហ្វឹកហាត់នេះ បានបើកវគ្គហ្វឹកហាត់បណ្តុះបណ្តាលតៃក្វាន់ដូផងដែរ ដោយមានគោលបំណងសំខាន់ៗចំនួន ៣គឺ ៖

១) ដើម្បីផ្សព្វផ្សាយអត្តសញ្ញាណតៃក្វាន់ដូ ដល់សិស្ស-និស្សិត ប្រជាពលរដ្ឋកម្ពុជា

២) ដើម្បីផ្តល់ជំនាញការពារខ្លួនដល់និស្សិត

៣) ដើម្បីឲ្យនិស្សិតបានចូលរួមសកម្មភាពកីឡា ក្នុងគោលបំណងចៀសឲ្យឆ្ងាយពីការប្រើ-ប្រាស់គ្រឿងញៀន។

គួរបញ្ជាក់ផងដែរថា វគ្គហ្វឹកហាត់នេះត្រូវបានបែងចែកជា ២ផ្នែកធំៗគឺ វគ្គមូលដ្ឋានសម្រាប់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវគ្គជំនាញសម្រាប់និស្សិតនិងសាធារណៈជនទូទៅ។ ចំពោះវគ្គមូលដ្ឋានសម្រាប់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និស្សិតអាចហ្វឹកហាត់បានដោយមិនចាំបាច់បង់ថ្លៃសិក្សាទេ។

### ២.៥.៣. គម្រោងអភិវឌ្ឍន៍វិស័យអប់រំកម្ពុជានាពេលបច្ចុប្បន្ន

គម្រោងជំនួយទ្វេភាគីនាពេលបច្ចុប្បន្ន ដែល KOICA ប្រចាំកម្ពុជា កំពុងអនុវត្តន៍មានចំនួនមួយគម្រោងដែល ស្តីពី ការលើកកម្ពស់គុណភាពសិក្សា និង ការកែលម្អសាលាជាតិកសិកម្មខេត្តកំពង់ចាម (KCNSA) ដោយផ្សាភ្ជាប់ជាមួយនឹងគោលបំណងសំខាន់ចំនួន៣គឺ

- លើកកម្ពស់គុណភាព KCNSA ដើម្បីពង្រឹងមុខងារអប់រំដែលមានស្រាប់ ព្រមទាំងដាក់ចេញនូវផែនការមេសម្រាប់អភិវឌ្ឍន៍សាលា។

- គាំទ្រដល់ការអភិវឌ្ឍកម្មវិធីសិក្សាថ្មីដោយផ្តោតទៅលើវិធីសាស្ត្រចលនាភូមិថ្មី សម្រាប់អភិវឌ្ឍន៍ជនបទនៅកម្ពុជា។
- ជួយបណ្តុះបណ្តាលដល់អ្នកសិក្សាផ្នែកកសិកម្មជំនាន់ក្រោយ ដែលនឹងធ្វើឲ្យពួកគេអាចបង្កើនឱកាសការងារតាមរយៈការផ្តល់នូវបច្ចេកទេសនិងចំណេះដឹងជាក់ស្តែង។

គួរបញ្ជាក់ផងដែរថាគម្រោងនេះបានចាប់ផ្តើមពីឆ្នាំ ២០១៦ និងបញ្ចប់កាលពីឆ្នាំ ២០១៧ ដោយចំណាយអស់ថវិកា USD ១ ៥២៧ ១១៧ ដូចបានបង្ហាញនៅក្នុង ចំណុច ១.១២.៧.។ ដោយសារKCNSAនៅតែមានតម្រូវការលើការបណ្តុះបណ្តាលធនធានមនុស្ស និងការស្រាវជ្រាវ ការអភិវឌ្ឍកម្មវិធីសិក្សា ឧបករណ៍ និងសម្ភារសម្រាប់ការបង្រៀនផ្នែកកសិកម្ម អ្វីដែលសំខាន់នោះ បើតាមអ្នកនាំពាក្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានប្រសាសន៍ថា សាលាមួយនេះនៅមានតម្រូវការថវិកាបន្ថែមទៀត ដើម្បីធ្វើការសាងសង់សាកលវិទ្យាល័យកសិកម្មមួយនៅក្នុងខេត្តកំពង់ចាម ទើបធ្វើឲ្យគម្រោងមួយនេះនៅតែបន្តរហូតដំណាច់ឆ្នាំ ២០១៩។

### ២.៥.៤. គម្រោងសាងសង់អគារមជ្ឈមណ្ឌលសិក្សានៅកម្ពុជានាពេលអនាគត

គម្រោងនាពេលអនាគតនៃជំនួយឥតសំណងរបស់ KOICA មកលើវិស័យអប់រំនៅកម្ពុជា គឺទៅលើការសាងសង់អគារមជ្ឈមណ្ឌលសិក្សា។ ស្ថិតក្រោមពិធីចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចពិភាក្សារវាង ក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹង KOICA កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ស្តីពី " គម្រោងបង្កើតប្រព័ន្ធបណ្តុះធុរកិច្ចថ្មីរវាងសាលានិងវិស័យឧស្សាហកម្មនៅប្រទេសកម្ពុជា" (២០១៩-២០២៣) ដែលគម្រោងនេះមានគោលបំណង៖

- បង្កើតការងារមានគុណភាពខ្ពស់ និងលើកកម្ពស់ជំនាញវិជ្ជាជីវៈ ក្នុងវិស័យឧស្សាហកម្មនៅប្រទេសនេះ ដើម្បីពង្រឹងលទ្ធភាពប្រកួតប្រជែងថ្នាក់ជាតិ ពីចក្ខុវិស័យរយៈពេលវែង។
- អាចរួមចំណែកក្នុងការផ្សាភ្ជាប់គម្លាតរវាង សមត្ថភាពសិក្សា និងតម្រូវការទីផ្សារ ដើម្បីលើកកម្ពស់ឧស្សាហូបនីយកម្ម ប្រកបដោយនិរន្តរភាព។
- បង្កើតការចាប់ផ្តើមប្រព័ន្ធអេកូ និង បណ្តាទីផ្សារនៅកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធមួយដើម្បីជំរុញការបង្កើតថ្មី តាមបណ្តាសាកលវិទ្យាល័យដែលឈានមុខគេនៅកម្ពុជា។

គម្រោងដែលមានរយៈពេល ៥ឆ្នាំនេះ រដ្ឋាភិបាលកូរ៉េ នឹងផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់ចំនួន USD ៧លាន ហើយនឹងត្រូវមានការបណ្តុះបណ្តាលដល់បុគ្គលិកនៅ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីធ្វើការស្វែងយល់លើការអនុវត្តន៍គម្រោង និងបន្តអនុវត្តគម្រោង

រហូតដល់ពេលបញ្ចប់ដោយខ្លួនឯង។ គម្រោងនេះ នឹងមានការលេចចេញជារូបភាពពីរ គឺកសាងអាគារមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីកម្ពុជា-កូរ៉េ(CKIC) និងបង្កើតប្រព័ន្ធបណ្តុះធុរកិច្ចថ្មី។

- **ការកសាងអាគារមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីកម្ពុជា-កូរ៉េ (CKIC)៖** នៅដើមឆ្នាំ ២០២០ នឹងមានបើកការដ្ឋានសាងសង់ CKIC ក្នុងបរិវេណ RUPP ដែលនឹងត្រូវបានធ្វើការស្ថាបនាឡើងនៅលើផ្ទៃដី ១ ៦០០ ម៉ែត្រការេ។ ក្នុងអាគារនោះរួមមាន បន្ទប់ប្រជុំប្រមាណជា ៥ បន្ទប់ សាលប្រជុំសម្រាប់ក្រុមធុរៈជនថ្មីមកពីបណ្តាក្រុមហ៊ុននានា សាលសម្រាប់រៀបចំកម្មវិធីផ្សេងៗ កន្លែងចតរថយន្ត និងអាហារដ្ឋាន។ ក្នុងបន្ទប់ទាំងនោះ នឹងមានការបំពាក់គ្រឿងបរិក្ខារទំនើបៗ ដែលអាចជួយដល់ធុរៈជនកម្ពុជាធ្វើការសិក្សា និងអនុវត្ត។ អាគារ CKIC នេះ គ្រោងនឹងធ្វើការបញ្ចប់ការសាងសង់នៅក្នុងឆ្នាំ ២០២០នេះតែម្តង។
- **ការបង្កើតប្រព័ន្ធបណ្តុះធុរកិច្ចថ្មី៖** នឹងមានគ្រូបណ្តុះបណ្តាលបច្ចេកទេស និងអ្នកជំនាញដែលមានបទពិសោធក្នុងវិស័យធុរកិច្ចពីប្រទេសកូរ៉េ រួមទាំងប្រទេសដទៃ ដល់សិក្ខាកាម និងមានការបញ្ជូនសិក្ខាកាម ទៅដកស្រង់យកបទពិសោធក្នុងវិស័យធុរកិច្ចនៅប្រទេសកូរ៉េផងដែរ។

## ២.៥.៥. កិច្ចសហប្រតិបត្តិការបច្ចេកទេស

### ២.៥.៥.១. ការផ្តល់កម្មវិធីបណ្តុះបណ្តាល

#### ក. ប្រវត្តិនៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលកូរ៉េ ត្រូវបានចាប់ផ្តើមឡើងតាំងពីឆ្នាំ ១៩៦៣មកម្ល៉េះ ដែលនាពេលនោះ ប្រទេសកូរ៉េ បានទទួលការឧបត្ថម្ភថវិកាពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ។ វាជាការគាំទ្រប្រភេទទី ១ ដែលប្រទេសកូរ៉េបានផ្តល់ដល់បណ្តាប្រទេសជាដៃគូរបស់ខ្លួន។ មិនយូរប៉ុន្មាន នៅក្នុងឆ្នាំ ១៩៦៥ រដ្ឋាភិបាលកូរ៉េក៏បានចាប់ផ្តើមដំណើរការកម្មវិធីនេះដោយប្រើថវិកាជាតិរបស់ខ្លួនវិញ។ បើទោះបីជា កម្មវិធីមួយនេះបានបង្កើតឡើងតាំងពីសម័យសង្គមរាស្ត្រនិយមក៏ដោយ ធនធានមនុស្សកម្ពុជាហាក់នៅមិនទាន់ឃើញមានវត្តមានក្នុងកម្មវិធីនេះនៅឡើយ។ ផ្ទុយទៅវិញ រហូតដល់ឆ្នាំ ១៩៩៤ ទើបមានវត្តមានសិក្ខាកាមចំនួន ៨រូប ត្រូវបានអញ្ជើញទៅចូលរួម ដើម្បីទទួលបានការសិក្សាក៏ដូចជាការបណ្តុះបណ្តាលអំពីបទពិសោធទៅលើការអភិវឌ្ឍរបស់ប្រទេសកូរ៉េ និងជំនាញទាក់ទងទៅនឹងវិស័យសំខាន់ៗក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកម្ពុជា។ នាឆ្នាំ ២០១២ កម្មវិធីបណ្តុះបណ្តាលមួយនេះ ត្រូវបានដាក់ឈ្មោះជាផ្លូវការថា Capacity Improvement and Advancement for Tomorrow ដែលហៅកាត់ថា CIAT

ហើយកម្មវិធីនេះ ត្រូវបានផ្តល់ជូននូវការបណ្តុះបណ្តាលជាច្រើនប្រភេទ ដើម្បីជំរុញការអភិវឌ្ឍប្រទេសកំពុងអភិវឌ្ឍន៍ ។

**ខ. អំពី** CIAT

ពាក្យកាត់ CIAT មានការបញ្ចេញសម្លេងដូច **គ្រាប់ពូជ** ក្នុងភាសាកូរ៉េ ហើយតាមរយៈពាក្យនេះ រដ្ឋាភិបាលកូរ៉េ សង្ឃឹមថានឹងអាចចែករំលែកនូវគ្រាប់ពូជនៃក្តីសង្ឃឹមសម្រាប់ថ្ងៃស្អែកដល់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ ។ CIAT ដូចជាកម្មវិធីកិច្ចសហប្រតិបត្តិការមួយ ដែលអ្នកបង្កើតគោលនយោបាយ មន្ត្រីរដ្ឋបាល និងអ្នកជំនាញមកពីប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានអញ្ជើញទៅប្រទេសកូរ៉េ ដើម្បីទទួលការបណ្តុះបណ្តាលបច្ចេកទេស និងការចែករំលែកចំណេះដឹង។ កម្មវិធីនេះ បានបង្កើតចំណងមិត្តភាពជាមួយអង្គការសាធារណៈ ស្ថាប័នស្រាវជ្រាវ សាកលវិទ្យាល័យ និងអង្គភាពផ្សេងៗទៀតក្នុងប្រទេសកូរ៉េ ដើម្បីផ្តល់នូវកម្មវិធីបណ្តុះបណ្តាលដ៏មានគុណភាពដល់អ្នកដែលអញ្ជើញចូលរួម។ ក្នុងកិច្ចខិតខំប្រឹងប្រែងបែបនេះ បានធ្វើឲ្យអ្នកចូលរួមក្នុងកម្មវិធីនេះកាន់តែមានភាពពេញចិត្តថែមមួយកម្រិតទៀត។ បន្ទាប់ពីអ្នកទាំងអស់នោះ បានវិលត្រលប់ទៅកាន់ប្រទេសកំណើតរបស់ខ្លួនវិញ ពួកគាត់ដើរតួនាទីជាអ្នកផ្សព្វផ្សាយ បង្ហាញពីការប្តេជ្ញាចិត្តនិងសុច្ឆន្ទៈទៅក្នុងសង្គមរបស់គាត់ ។

**គ. គោលបំណងរបស់** CIAT

គោលបំណងចម្បងរបស់កម្មវិធីមួយនេះគឺ ដើម្បីផ្តល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមក្នុងប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការចែករំលែកចំណេះដឹងបទពិសោធការអភិវឌ្ឍ និងចំណេះធ្វើរបស់ប្រទេសកូរ៉េ ដែលបានប្រមូលផ្តុំនៅក្នុងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន ព្រមទាំងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេ។ មិនតែប៉ុណ្ណោះ CIAT ក៏មានគោលបំណងមួយចំនួនទៀត ដូចខាងក្រោម ៖

- **ការពង្រឹងសមត្ថភាពធនធានមនុស្ស** ៖ ដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងគោលបំណងបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។
- **ការពង្រឹងសមត្ថភាពប្រព័ន្ធអប់រំ និងគុណភាព** ៖ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ននៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងគោលបំណងជួយដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍរបស់ប្រទេសទាំងនោះ ។

- **ភាពជាដៃគូ និងចំណងមិត្តភាព** ៖ ដើម្បីពង្រឹងបណ្តាញទំនាក់ទំនងមនុស្សនិងស្ថាប័ន ក៏ដូចជាដើម្បីលើកកម្ពស់ចំណងមិត្តភាពរវាងប្រទេសកូរ៉េ និងបណ្តាប្រទេសជាដៃគូ ។

**ឃ. ប្រភេទនៃកម្មវិធីបណ្តុះបណ្តាលរបស់** KOICA

កម្មវិធីបណ្តុះបណ្តាលរបស់ KOICA នេះត្រូវបានបែងចែកតាមប្រភេទដូចខាងក្រោម ៖

**១) តាមប្រទេសដែលចូលរួម**

- កម្មវិធីបណ្តុះបណ្តាលប្រទេសជាក់លាក់ ៖ កម្មវិធីនេះត្រូវបានរៀបចំឡើងដើម្បីឆ្លុះបញ្ចាំងពីតម្រូវការ និងភាពជាក់ស្តែងនៃប្រទេសជាដៃគូ ។
- កម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់ ៖ កម្មវិធីនេះរៀបចំឡើង ដើម្បីដោះស្រាយបញ្ហារាំងស្ទះដល់ការអភិវឌ្ឍន៍ នៅក្នុងតំបន់ជាក់លាក់ណាមួយ។
- កម្មវិធីបណ្តុះបណ្តាលជាសកល ៖ កម្មវិធីនេះមានការចូលរួមពីប្រទេសជាច្រើន។

**២) តាមរយៈពេល**

- កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី ៖ វគ្គសិក្សាដែលមានរយៈពេលតិចជាង ១ ខែ។
- កម្មវិធីបណ្តុះបណ្តាលរយៈពេលមធ្យម ៖ វគ្គបណ្តុះបណ្តាលចាប់ពី ២ ទៅ ៦ ខែ។
- កម្មវិធីបណ្តុះបណ្តាលច្រើនឆ្នាំ ៖ វគ្គបណ្តុះបណ្តាលរយៈពេល ៣ឆ្នាំជាប់ៗគ្នា។
- កម្មវិធីបណ្តុះបណ្តាលរយៈពេលវែង ៖ វគ្គជំនាញវិជ្ជាជីវៈដែលមានរយៈពេលមួយឆ្នាំឬច្រើនជាងនេះដូចជាមុខវិជ្ជាអនុបណ្ឌិតជាដើម។

**៣) តាមវិធីកិច្ចសហប្រតិបត្តិការ**

- កម្មវិធីបណ្តុះបណ្តាលជាទៀងទាត់ ៖ វគ្គបណ្តុះបណ្តាលនេះត្រូវប្រគល់ឲ្យអង្គការក្នុងស្រុកមួយនៅក្នុងប្រទេសកូរ៉េ ដែលទទួលបានការឧបត្ថម្ភជាទូទៅពីKOICA។
- កម្មវិធីបណ្តុះបណ្តាលរួមគ្នា ៖ វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្តដោយ KOICA និងប្រទេសជាម្ចាស់ជំនួយផ្សេងទៀត ។
- កម្មវិធីបណ្តុះបណ្តាលកិច្ចសហប្រតិបត្តិការ ៖ វគ្គបណ្តុះបណ្តាលនេះបានធ្វើឡើងដោយ KOICA និងអង្គការអន្តរជាតិ ។

**ង. ការចំណាយថវិកាក្នុងកម្មវិធីបណ្តុះបណ្តាល**

ដូចដែលបានបង្ហាញនៅក្នុងចំណុច ឃ. កម្មវិធីបណ្តុះបណ្តាលត្រូវបានបែងចែកទៅតាមប្រភេទនីមួយៗ ជាទូទៅមន្ត្រីរាជការកម្ពុជា អញ្ជើញចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល តាមរយៈពេលជាលក្ខណៈអាហារូបករណ៍។ កន្លងមក កម្មវិធីអាហារូបករណ៍បែបនេះ មានការចេញលិខិត

អញ្ជើញចូលរួមពីសំណាក់ភ្នាក់ងារKOICA ប្រចាំកម្ពុជាទៅកាន់ក្រសួងឬស្ថាប័នដែលពាក់ព័ន្ធ។[28] គួរបញ្ជាក់ផងដែរថា ដើម្បីទទួលបានអាហារូបករណ៍នេះ មន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវទាមទារឆ្លងកាត់ដំណើរការជ្រើសរើសបេក្ខភាពដោយ KOICA ជាមុនសិន។[29] ក្រោយពេលដែលមន្ត្រីរាជការត្រូវបានជ្រើសរើស ពួកគាត់នឹងទទួលបានអត្ថប្រយោជន៍ដែលមានក្នុងកម្មវិធីអាហារូបករណ៍ដូចខាងក្រោម ៖

| ការឧបត្ថម្ភ | ចំនួនទឹកប្រាក់ | កំណត់សម្គាល់ |
|---|---|---|
| ថ្លៃសំបុត្រយន្តហោះ | អាស្រ័យលើការចំណាយជាក់ស្តែង | – មិនត្រូវបានឧបត្ថម្ភដោយ KOICA ជាពិសេសក្នុងករណីដែលសិក្ខាកាមបំពានលើបទបញ្ញត្តិសិក្សា<br>– មិនត្រូវបានឧបត្ថម្ភដោយ KOICA នៅពេលអ្នកចូលរួមចាកចេញទៅប្រទេសកំណើតរបស់ខ្លួនជាបណ្ដោះអាសន្នក្នុងអំឡុងពេលបណ្ដុះបណ្ដាល<br>– ក្រៅពីករណីខាងលើ KOICA ជាអ្នកទទួលបន្ទុកទាំងអស់ ។ |
| ថ្លៃសិក្សា | អាស្រ័យលើចំនួនទឹកប្រាក់ដែលតម្រូវដោយសាកលវិទ្យាល័យនីមួយៗ | – ត្រូវបានឧបត្ថម្ភដោយវិទ្យាស្ថានបណ្ដុះបណ្ដាល |
| សកម្មភាពក្រៅម៉ោងសិក្សា | ត្រូវបានចំណាយជាក់ស្តែងក្នុងទស្សនកិច្ចសិក្សា សិក្ខាសាលា ថ្នាក់ភាសាកូរ៉េ និងផ្សេងៗទៀតលើកលែងតែថ្នាក់ធម្មតា | – ចំនួនទឹកប្រាក់មានការប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង<br>– ការចំណាយមួយចំនួននឹងមានការចេញដោយអ្នកដែលចូលរួមផ្ទាល់ ។ |
| ប្រាក់ឧបត្ថម្ភប្រចាំខែ | ៩៩៩ ០០០ វ៉ុនក្នុងមួយខែ | – ចំនួនទឹកប្រាក់នេះរួមបញ្ចូលទាំងការចំណាយសម្រាប់អាហារ សៀវភៅនិងការផ្គត់ផ្គង់សិក្សាដែលចាំបាច់<br>– ប្រសិនបើសិក្ខាកាមមិនអាចចូលរួមក្នុងវគ្គសិក្សាដោយមូលហេតុជាក់លាក់ដូចជាការឈប់សម្រាកបណ្ដោះអាសន្នទៅប្រទេសកំណើតរបស់ខ្លួននោះប្រាក់ឧបត្ថម្ភសម្រាប់ខែនោះនឹងត្រូវបានកំណត់តាមចំនួនថ្ងៃសិក្សាដែលត្រូវគ្នានៅក្នុងប្រទេសកូរ៉េ (៣៣ ៣០០ វ៉ុនក្នុងមួយថ្ងៃ) ។<br>– * បរិមាណដកចេញ (៣៣ ៣០០វ៉ុន/ថ្ងៃ) គឺដូចគ្នាមិនគិតពីចំនួនថ្ងៃដែលមាននៅក្នុងខែ ។ |

[28] ឧបសម្ព័ន្ធ

[29] ឧបសម្ព័ន្ធ

| | | |
|---|---|---|
| ការស្នាក់នៅ | អាស្រ័យលើការចំណាយជាក់ស្តែង | – ថ្លៃប្រើប្រាស់អគ្គីសនី និងការប្រើប្រាស់ទឹកភ្លើងផ្សេងទៀតមិនត្រូវបានរាប់បញ្ចូលទេ<br>– ការចំណាយលើការសំអាត ការបោកគក់ និងការផ្លាស់ប្តូរកម្រាលពូកក៏មិនត្រូវបានរាប់បញ្ចូលដែរ<br>– ក្រៅពីការចំណាយខាងលើ អ្វីផ្សេងទៀតជាការឧបត្ថម្ភដោយវិទ្យាស្ថានបណ្តុះបណ្តាល ។ |
| ការធ្វើដំណើរ | ៦០០ ០០០វ៉ុន | – ការចំណាយដែលចាំបាច់ត្រូវចូលទៅក្នុងប្រទេសកូរ៉េដូចជាថ្លៃទិដ្ឋាការ ថ្លៃចុះឈ្មោះជនបរទេសនិងផ្សេងៗ<br>– ត្រូវបានឧបត្ថម្ភដោយវិទ្យាស្ថានបណ្តុះបណ្តាល ។ |
| ប្រាក់ឧបត្ថម្ភបន្ថែម | ៣០០ ០០០វ៉ុន | – ការប្រើសេវាប្រៃសណីយ៍ និងការចំណាយផ្សេងទៀតដែលត្រូវការដើម្បីផ្ញើដំណើរមកប្រទេសកំណើតវិញ (ឧ.ការចំណាយសម្រាប់ផ្ញើឯកសារ)<br>– ត្រូវបានឧបត្ថម្ភដោយវិទ្យាស្ថានបណ្តុះបណ្តាល ។ |
| ធានារ៉ាប់រង | អាស្រ័យលើការចំណាយជាក់ស្តែង | – ការចំណាយលើធានារ៉ាប់រងអំឡុងពេលស្នាក់នៅប្រទេសកូរ៉េ<br>– ត្រូវបានឧបត្ថម្ភដោយ KOICA ។ |

*(ប្រភព ៖ 2019 KOICA Scholarship Program Application Guideline: For Master's Degrees)*

✍ **ចំណាំ ៖**

- KOICA នឹងរៀបចំ និងចំណាយសម្រាប់អ្នកចូលរួម ក្នុងការធ្វើដំណើរទៅ និងមកពីប្រទេសកូរ៉េ។ KOICA នឹងទទួលបន្ទុកការចំណាយក្នុងថ្នាក់ និងការហោះហើរទៅមក។
- ប្រសិនបើអ្នកចូលរួមចង់ប្តូរផ្លូវហោះហើរ ពួកគេនឹងត្រូវបង់ថ្លៃសំបុត្រយន្តហោះបន្ថែមដោយខ្លួនឯង។
- អ្នកចូលរួមទទួលខុសត្រូវលើការចំណាយក្នុងការចេញទិដ្ឋាការសមស្រប ដែលចាំបាច់សម្រាប់កម្មវិធីអាហារូបករណ៍នេះ។

បច្ចុប្បន្ន KOICA បានធ្វើកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យនៅប្រទេសកូរ៉េប្រមាណ ២០ សាកលវិទ្យាល័យ ដើម្បីបើកវគ្គបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិត ដែលមានមុខវិជ្ជាផ្តោតសំខាន់ៗជាច្រើនដូចជា អភិបាលកិច្ច កសិកម្មនិងការអភិវឌ្ឍជនបទ ការអប់រំ សុខាភិបាល បច្ចេកវិទ្យា បរិស្ថាននិងថាមពលជាដើម។ គិតចាប់ពីឆ្នាំ ១៩៩៤ រហូតដល់ឆ្នាំ ២០១៧ ចំនួនមន្ត្រីរាជការដែលបម្រើការងារតាមស្ថាប័នរដ្ឋផ្សេងៗ បានអញ្ជើញទៅសិក្សានៅប្រទេសកូរ៉េ តាមរយៈកម្មវិធីបណ្តុះបណ្តាលនេះមានចំនួន ២ ៩៤៦ នាក់ហើយ។ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ KOICA ចេញក្នុងឆ្នាំ ២០១៧ បានបង្ហាញឲ្យឃើញថា មានមន្ត្រីរាជការកម្ពុជាប្រមាណ ១២០ នាក់គិតជាមធ្យមក្នុងមួយឆ្នាំ បានអញ្ជើញចូលរួមក្នុងកម្មវិធីនេះ។

តារាងទី២.១ ៖ ចំនួនថវិកាដែលបានចំណាយដោយរដ្ឋាភិបាលកូរ៉េលើកម្មវិធីអាហារូបករណ៍

| ឆ្នាំ | បរិយាយ | ការចំណាយសរុប | |
|---|---|---|---|
| | | KRW | USD |
| ១៩៩៤ | វគ្គសិក្សា ១ សិក្ខាកាម : ៤ | ៦ ៦១០ ៧២៦ | ៨ ២២៦ |
| ១៩៩៥ | វគ្គសិក្សា ១ សិក្ខាកាម : ២ | ៥ ៩២៥ ៤៥០ | ៧ ៦៨៥ |
| ១៩៩៦ | វគ្គសិក្សា ១ សិក្ខាកាម : ៤ | ១២ ៧៤៦ ៦១៦ | ១៥ ៨៣៩ |
| ១៩៩៧ | វគ្គសិក្សា ៦ សិក្ខាកាម : ១៧ | ៦៨ ២៩៣ ៨១៦ | ៧១ ៨០៤ |
| ១៩៩៨ | វគ្គសិក្សា ១៣ សិក្ខាកាម : ៣០ | ១២០ ៩០៩ ៩០២ | ៨៦ ៤៣៣ |
| ១៩៩៩ | វគ្គសិក្សា ១៧ សិក្ខាកាម :៣៦ | ១១៨ ១០៥ ៧៤៦ | ៩៩ ២៩២ |
| ២០០០ | វគ្គសិក្សា ៤០ សិក្ខាកាម : ៨៧ | ៤៤២ ៦៨០ ៣២៩ | ៣៩១ ៥៤៥ |
| ២០០១ | វគ្គសិក្សា ៤០ សិក្ខាកាម : ១១២ | ៤៧២ ៥៦២ ៩៤៨ | ៣៦៦ ០៩២ |
| ២០០២ | វគ្គសិក្សា ៥២ សិក្ខាកាម : ១២៨ | ៧៣៨ ១៥១ ៨៥០ | ៥៨៩ ៩៣៦ |
| ២០០៣ | វគ្គសិក្សា ៦៨ សិក្ខាកាម : ១៣៦ | ៦៣៧ ២៧៤ ៣៤២ | ៥៣៤ ៦៧៥ |
| ២០០៤ | វគ្គសិក្សា ៥១ សិក្ខាកាម : ១០៨ | ៥០០ ៦៥៣ ៧៨២ | ៤៣៧ ៣៧៨ |
| ២០០៥ | វគ្គសិក្សា ៥២ សិក្ខាកាម : ៩២ | ៤៨៩ ២៤៩ ៤២១ | ៤៧៧ ៦៣៨ |
| ២០០៦ | វគ្គសិក្សា ៥៣ សិក្ខាកាម : ១១៣ | ៥៩១ ៨០៩ ៧៦៣ | ៦១៩ ៣៦៥ |
| ២០០៧ | វគ្គសិក្សា ៥៣ សិក្ខាកាម : ១២០ | ៧៩៣ ៦០៣ ២៥៣ | ៨៥៤ ០៧២ |
| ២០០៨ | វគ្គសិក្សា ៥៥ សិក្ខាកាម : ១៧០ | ១ ៣១៣ ៣៣៨ ៦៥៧ | ១ ១៨៣ ០៨១ |
| ២០០៩ | វគ្គសិក្សា ៤៩ សិក្ខាកាម : ១៤០ | ៩៧៧ ២១២ ៣៤១ | ៧៦៧ ១០៣ |
| ២០១០ | វគ្គសិក្សា ៥៨ សិក្ខាកាម : ១៧២ | ១ ១២១ ៩៣៦ ០៣៥ | ៩៧១ ០៣៧ |
| ២០១១ | វគ្គសិក្សា ៨៥ សិក្ខាកាម : ១៨៥ | ១ ៥៨៤ ៩៥៧ ៨០០ | ១ ៤៣១ ៣៧២ |
| ២០១២ | វគ្គសិក្សា ៦៥ សិក្ខាកាម : ១៩៥ | ១ ៧៦៦ ១៤១ ៩០៤ | ១ ៥៦៨ ៦៤៩ |
| ២០១៣ | វគ្គសិក្សា ៥៦ សិក្ខាកាម : ១៩៩ | ១ ៩៦៩ ៩៦១ ៣៣៣ | ១ ៧៩៩ ៦៤៦ |
| ២០១៤ | វគ្គសិក្សា ៥០ សិក្ខាកាម : ២០៦ | ១ ៧៥១ ១២៧ ៧២៧ | ១ ៦៦២ ៨៨៤ |
| ២០១៥ | វគ្គសិក្សា ៣៧ សិក្ខាកាម : ១៧១ | ១ ៧៤១ ៣៧២ ២០០ | ១ ៥៣៩ ២៥៥ |

| | | | |
|---|---|---|---|
| ២០១៦ | វគ្គសិក្សា ៦១ សិក្ខាកាម : ២១០ | ១ ៧០១ ២៧៤ ៧២០ | ១ ៤៦៥ ៨៧១ |
| ២០១៧ | វគ្គសិក្សា ៣២ សិក្ខាកាម : ១៣០ | ១ ១១៦ ៧៣៦ ៣៤៧ | ៩៨៧ ៧០៧ |
| សរុប | សិក្ខាកាម: ២ ៩៤៦ | ២០ ០៤២ ៦៣៧ ០០៨ | ១៧ ៩៣៦ ៥៨៩ |

(*ប្រភព ៖* http://stat.koica.go.kr)

ក្រាហ្វិកទី២.១ ៖ សមាមាត្រសិក្ខាកាមតាមវិស័យ




(*ប្រភព ៖ www.koica.go.kr* )

### ២.៥.៥.២. ការបញ្ជូនអ្នកជំនាញ

តាំងពីឆ្នាំ១៩៩៦មក KOICA បានបញ្ជូនអ្នកជំនាញទៅកម្ពុជាក្នុងរយៈពេលកំណត់មួយ ដើម្បី ផ្ទេរចំណេះដឹង និងបទពិសោធរបស់កូរ៉េ។ តាមរយៈអ្នកជំនាញជនជាតិកូរ៉េ ប្រទេសកំពុងអភិវឌ្ឍន៍មួយនេះ អាចមានឱកាសរៀនសូត្រពីបទពិសោធ និងជំនាញអភិវឌ្ឍន៍របស់ប្រទេសកូរ៉េបាន។ អ្នកជំនាញទាំងនោះមានឯកទេសក្នុងវិស័យ កសិកម្ម កីឡា អប់រំ និងកម្មន្តសាលជាដើម។ លើសពីនេះ ពួកគេក៏ផ្តល់ជំនួយក្នុងរូបភាពដូចជា ការពិគ្រោះយោបល់ ការណែនាំ ការស្រាវជ្រាវ ការផ្តល់ប្រឹក្សា ការធ្វើសកម្មភាពស្ទង់មតិ និងការបណ្តុះបណ្តាលផងដែរ។

អ្នកជំនាញ ដែលធ្វើការជាមួយមន្ត្រីរាជរដ្ឋាភិបាល បានផ្ទេរបទពិសោធ និងចែករំលែកចំណេះដឹងរបស់ប្រទេសកូរ៉េក្នុងកម្រិតតំបន់។ តាមរយៈការចែករំលែកចំណេះដឹង ចំណេះធ្វើ ការធ្វើសិក្ខាសាលា និងការពិគ្រោះយោបល់ទាក់ទងនឹងគោលនយោបាយ បានធ្វើឲ្យមានការលើ

កម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងធនធានមនុស្សកម្ពុជាកាន់តែប្រសើរ។ គួរបញ្ជាក់ផងដែរថា អ្នកជំនាញដំបូងគេដែលបានបញ្ជូនមកកាន់ប្រទេសកម្ពុជា គឺជាគ្រូបង្រៀនតែក្វាន់ដូ ដែលមានចំនួន ១នាក់ប៉ុណ្ណោះ ។

តារាងទី២.២ ៖ ទិន្នន័យការបញ្ជូនអ្នកជំនាញចាប់តាំងពីឆ្នាំ ១៩៩៦-២០១០

| ឆ្នាំ | ចំនួនអ្នកជំនាញ | ចំនួនទឹកប្រាក់ចំណាយ | | សេចក្តីលម្អិត |
|---|---|---|---|---|
| | | KRW | USD | |
| **១៩៩៦** | ១ | ៩ ១៨០ ២២៨ | ១១ ៨០៧ | គ្រូបង្រៀនតែក្វាន់ដូ ១ នាក់ |
| **១៩៩៧** | ១ | ៣១ ៣០៨ ៩៤២ | ៣២ ៩១៨ | គ្រូបង្រៀនតែក្វាន់ដូ ១ នាក់ |
| **១៩៩៨** | ១ | ៥៦ ៧៥៣ ៨៦៣ | ៤០ ៥៧១ | គ្រូបង្រៀនតែក្វាន់ដូ ១ នាក់ |
| **១៩៩៩** | ៥ | ៦៨ ៦០៨ ៨៨៩ | ៥៧ ៦៧៩ | អ្នកជំនាញផ្នែកទីផ្សារ ៤ នាក់ និង គ្រូបង្រៀនតែក្វាន់ដូ ១ នាក់ |
| **២០០០** | ៤ | ១០៣ ០៩១ ៥២៧ | ៩១ ១៨៣ | អ្នកជំនាញផ្នែកបរិស្ថាន ២នាក់ អ្នករុករករ៉ែត្បូងថ្ម ១នាក់ និងគ្រូបង្រៀនតែក្វាន់ដូ ១នាក់ |
| **២០០១** | ៥ | ១៦៨ ៧៨៥ ០៨៣ | ១៣០ ៧៥៧ | គ្រូបង្រៀនតែក្វាន់ដូ ១នាក់ អ្នកជំនាញផ្នែកទំនាក់ទំនងព័ត៌មានវិទ្យា ១នាក់ ឱសថការី ១នាក់ អ្នកសេដកិច្ចកសិកម្ម១នាក់ និងអ្នកសេដ្ឋកិច្ចទីផ្សារ ១នាក់ |
| **២០០២** | ៤ | ២៨៨ ១៩៥ ៦៥៣ | ២២៧ ១៣១ | អ្នកជំនាញផ្នែកអភិវឌ្ឍន៍និងគ្រប់គ្រង ១នាក់ ឱសថការី ១នាក់ គ្រូបង្រៀនតែក្វាន់ដូ ១នាក់ និង អ្នករៀបចំផែនការសេដ្ឋកិច្ច ១នាក់ |
| **២០០៣** | ៤ | ២៧៨ ៨១២ ៨០៩ | ២៣០ ៥៦៩ | ឱសថការី ១នាក់ អ្នកជំនាញផ្នែកដំណើរការផលិតកម្មកសិកផល ១ នាក់ គ្រូបង្រៀនតែក្វាន់ដូ ១នាក់ និងអ្នកធ្វើការក្នុងចលនាភូមិថ្មី ១នាក់ |
| **២០០៤** | ៥ | ៤៥០ ០៥៨ ៥០៥ | ៣៩៣ ១៧៨ | ឱសថការី ១នាក់ អ្នកជំនាញផ្នែកដាំដុះ ១នាក់ គ្រូបង្រៀនតែក្វាន់ដូ ១នាក់ អ្នកធ្វើការក្នុងចលនាភូមិថ្មី ១នាក់ និងអ្នករៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច ១នាក់ |

| | | | | |
|---|---|---|---|---|
| **២០០៥** | ២ | ២៣៣ ៧៧៣ ៩៣៩ | ២២៨ ២២៦ | ឱសថការី ១នាក់ និងគ្រូបង្រៀនតៃក្វាន់ដូ ១នាក់ |
| **២០០៦** | ៤ | ២៤២ ៧២១ ០៥៧ | ២៥៤ ០២៣ | ឱសថការី ១នាក់ អ្នកបណ្តុះបណ្តាលវិជ្ជាជីវៈ ១នាក់ អ្នកជំនាញផ្នែកទូរគមនាគមន៍១នាក់ និងគ្រូបង្រៀនតៃក្វាន់ដូ ១នាក់ |
| **២០០៧** | ២ | ២១៧ ៦១១ ០២៧ | ២៣៤ ១៩២ | ឱសថការី ១នាក់ និងគ្រូបង្រៀនតៃក្វាន់ដូ ១នាក់ |
| **២០០៨** | ២ | ១៦៩ ២២៨ ៨១៦ | ១៥២ ៩៤៥ | ឱសថការី ១នាក់ និងគ្រូបង្រៀនតៃក្វាន់ដូ ១នាក់ |
| **២០០៩** | N/A | | | |
| **២០១០** | ៣ | ១៧២ ២២៤ ១០១ | ១៤៩ ០៦០ | អ្នកជំនាញផ្នែកឡាន ១នាក់ អ្នកជំនាញផ្នែកមេកានិច ១នាក់ និងវិស្វករស៊ីវិល ១នាក់ |
| **សរុប** | ៤៣ នាក់ | ២ ៤៨២ ៣៥៤ ០៣៩ | ២ ២៣៣ ៣៣៨ | |

(*ប្រភព ៖* 통합사업관리 stat.koica.go.kr)

### ២.៥.៥.៣. ការបញ្ជូនគ្រូបង្រៀនតៃក្វាន់ដូ

KOICA បានបញ្ជូនគ្រូបង្រៀនតៃក្វាន់ដូ ដើម្បីជួយឲ្យប្រជាពលរដ្ឋនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ អាចរក្សាបានភាពរឹងមាំខាងរាងកាយនិងស្មារតី និងលើកកម្ពស់ការរស់នៅពួកគាត់ប្រកបដោយសុខភាពល្អ តាមរយៈការធ្វើលំហាត់ប្រាណ ដែលស្របពេលនោះពួកគេអាចផ្សព្វផ្សាយវប្បធម៌កូរ៉េផងៗ មនុស្សកាន់តែច្រើន ចាប់ផ្តើមមានចំណាប់អារម្មណ៍ នៅក្នុងសិល្បៈក្បាច់គុណប្រភេទនេះ បន្ទាប់ពីកីឡាប្រភេទនេះ ត្រូវបានគេយកទៅដាក់ប្រកួតជាផ្លូវការដំបូងក្នុងព្រឹត្តិការណ៍កីឡាអូឡាំពិច ដែលបានប្រព្រឹត្តិទៅនៅឯ ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលីៗ

តារាងទី២.៣ ៖ ចំនួននៃការបញ្ជូនគ្រូបង្រៀនតៃក្វាន់ដូគិតចាប់ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២០០៨

| គ្រូបង្រៀនតៃក្វាន់ដូ | | | | |
|---|---|---|---|---|
| **ឆ្នាំ** | **ចំនួនទឹកប្រាក់** | | **ភេទ** | |
| | KRW | USD | **ប្រុស** | **ស្រី** |
| **១៩៩៦** | ៩ ១៨០ ២២៨ | ១១ ៩០៧ | ១ | ០ |
| **១៩៩៧** | ៣១ ៣០៨ ៩៤២ | ៣២ ៩១៨ | ១ | ០ |

| | | | | |
|---|---|---|---|---|
| ១៩៩៨ | ៥៦ ៧៥៣ ៨៦៣ | ៩០ ៥៧១ | ១ | ០ |
| ១៩៩៩ | ៥១ ៥៩០ ១៧៨ | ៩៣ ៣៧២ | ១ | ០ |
| ២០០០ | ៥៤ ១៣៥ ៣៤៨ | ៨៧ ៨៨២ | ១ | ០ |
| ២០០១ | ៦៣ ៨៨៦ ៩០៨ | ៨៩ ៨៩៣ | ១ | ០ |
| ២០០២ | ៧៤ ៩៥៨ ២៩៣ | ៥៩ ៥០៨ | ១ | ០ |
| ២០០៣ | ៨២ ៥៥៤ ១២៨ | ៦៩ ២៦៣ | ១ | ០ |
| ២០០៤ | ១០៨ ៧៤៩ ៣៧៤ | ៩៥ ០០៥ | ១ | ០ |
| ២០០៥ | ៧៩ ៨១៦ ៩២៦ | ៧៧ ៥៣២ | ១ | ០ |
| ២០០៦ | ៧១ ៥៧៣ ៣២៣ | ៧៤ ៩០៦ | ១ | ០ |
| ២០០៧ | ៩០ ០៧១ ៣០១ | ៨៦ ៩៣៤ | ១ | ០ |
| ២០០៨ | ៩៣ ៥៦២ ០៦០ | ៨៤ ២៨៣ | ១ | ០ |
| **សរុប** | ៨៦៧ ២៤០ ៣៧២ | ៧៨៣ ០៧៤ | ១៣ | ០ |

*(ប្រភព ៖ 통합사업관리 stat.koica.go.kr)*

**២.៥.៥.៤. កម្មវិធីអ្នកស្ម័គ្រចិត្តរបស់ KOICA**

កម្មវិធីអ្នកស្ម័គ្រចិត្ត KOICA ជាកម្មវិធីមួយដែលមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋកូរ៉េជាច្រើន ដែលត្រូវបានបញ្ជូនទៅប្រទេសជាដៃគូអភិវឌ្ឍន៍ ដើម្បីចែករំលែកបទពិសោធ ជំនាញ និងចំណេះដឹង ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសទាំងនោះ។ រដ្ឋាភិបាលកូរ៉េ បានអនុម័តកម្មវិធីអ្នកស្ម័គ្រចិត្តជនជាតិកូរ៉េនៅក្រៅប្រទេស (KOVs) ចាប់តាំងពីឆ្នាំ ១៩៨៩ ហើយបន្ទាប់មកគណៈកម្មាធិការកូរ៉េ បានចាប់ផ្ដើមកម្មវិធីមួយនេះ ដោយការបញ្ជូនអ្នកស្ម័គ្រចិត្តដែលជាជនជាតិកូរ៉េចំនួន ៤៤នាក់ទៅកាន់ប្រទេស ៤ក្នុងទ្វីបអាស៊ីជាលើកដំបូង។ ចាប់តាំងពីពេលនោះមក កម្មវិធីនេះបានរួមចំណែកក្នុងអង្គភាពជាច្រើនរួមទាំង KOICAផងដែរ ដែលបានទទួលយកកម្មវិធីអ្នកស្ម័គ្រចិត្តរបស់ UNESCO។ ក្រោយមកនៅឆ្នាំ ២០០៩ ក្រុមអ្នកស្ម័គ្រចិត្តទាំងនោះ ត្រូវបានប្រសិទ្ធិនាមថា មិត្តភក្តិពិភពលោកកូរ៉េ (WFK)។ អ្នកទាំងនោះបានចែករំលែកចំណេះដឹង រួមទាំងបទពិសោធន ដែលពួកគេមាន ក៏ដូចជាបានជំរុញការកែប្រែសហគមន៍នីមួយៗ ព្រមទាំងបានលើកកម្ពស់ការផ្លាស់ប្ដូរវប្បធម៌រវាងប្រទេសកូរ៉េ ជាមួយប្រទេសជាដៃគូអភិវឌ្ឍន៍ផង។

កម្មវិធីអ្នកស្ម័គ្រចិត្តរបស់ KOICA ត្រូវបានបែងចែកចេញជា ២ គឺ ៖

- **កម្មវិធីមិត្តភក្តិពិភពលោក KOICA (ឬកម្មវិធី KOVs) ៖** សំដៅលើយុវជនកូរ៉េ ដែលមានអាយុច្រើនជាង ២០ឆ្នាំ ហើយពួកគេតម្រូវឲ្យធ្វើការស្ម័គ្រចិត្តរយៈពេល ២ឆ្នាំក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ មួយវិញទៀត ពួកគេរស់នៅនិងធ្វើការជាមួយប្រជាជនក្នុងតំបន់ ព្រមទាំងចែករំលែកចំណេះដឹងនិងជំនាញបច្ចេកទេសផងដែរ។
- **កម្មវិធីមិត្តភក្តិពិភពលោកទីប្រឹក្សា KOICA (WFK Advisors) ៖** សំដៅលើជនចូលនិវត្តន៍ (ឬចូលនិវត្តន៍មុន) ដែលមានបទពិសោធការងារយ៉ាងតិច ១០ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រក្នុងវិស័យដែលពាក់ព័ន្ធ។ ពួកគាត់តម្រូវឲ្យធ្វើការងារស្ម័គ្រចិត្ត ក្នុងប្រទេសអភិវឌ្ឍន៍រយៈពេលពី៦ខែ ទៅ១ឆ្នាំ ដែលមានតួនាទីផ្តល់ប្រឹក្សា លើគោលនយោបាយ និងផ្ទេរជំនាញបច្ចេកវិទ្យា តាមក្រសួងរដ្ឋាភិបាលនិងអង្គការសាធារណៈ។

អ្នកស្មគ្រ័ចិត្តកូរ៉េ ទទួលការបណ្តុះបណ្តាលចំនួន ១២ សប្តាហ៍ មុនពេលត្រូវបានបញ្ជូនទៅកាន់តំបន់ការងារ របស់ពួកគេ ដើម្បីបំពេញបេសកកម្មក្នុងរយៈពេល ២ឆ្នាំ។ តាមរយៈកម្មវិធីទាំងពីរខាងលើនេះ អ្នកស្ម័គ្រចិត្តដែលបានទទួលការហ្វឹកហ្វឺនទាំងនេះ រួមចំណែកធ្វើឲ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជាកាន់តែប្រសើរឡើង ដោយជួយកែលម្អសេវាសុខុមាលភាពសង្គម និងជួយអភិវឌ្ឍតំបន់ជនបទ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងនាំមកនូវការអភិវឌ្ឍប្រកបដោយចេរភាព។ ក្នុងវិស័យសុខាភិបាល គិលានុបដ្ឋាយិកានិងវេជ្ជបណ្ឌិតដែលមាននៅកិច្ចសហការអន្តរជាតិជាច្រើនរូប ត្រូវបានបញ្ជូនមកកាន់ប្រទេសកម្ពុជា។ ចំនែកឯវិស័យអប់រំ អ្នកស្មគ្រ័ចិត្តបានបង្រៀនភាសាកូរ៉េ អប់រំ កុមារតូច ការអប់រំកាយ និងហ្វឹកហ្វឺនកុំព្យូទ័រ។

កម្មវិធីនេះ មានចក្ខុវិស័យ និងបេសកកម្មដូចតទៅ ៖

**ចក្ខុវិស័យ ៖** ការជួយឲ្យពិភពលោកកាន់តែរីកចម្រើនតាមរយៈការចែករំលែកនិងរៀនសូត្រ។

**បេសកកម្ម ៖** មានចំនួន ២គឺ៖

- ការជួយពង្រឹងនូវគុណភាពនៃជីវិតកាន់តែប្រសើរឡើងនៅក្នុងប្រទេសជាដៃគូ
- ការបង្កើនកិច្ចសហប្រតិបត្តិការ និងការយល់ដឹងកាន់តែប្រសើរឡើងរវាងប្រទេសជាដៃគូនិងប្រទេសកូរ៉េ។

### ក. កម្មវិធីមិត្តភក្តិពិភពលោក KOICA (ឬកម្មវិធី KOVs)

កម្មវិធីអ្នកស្ម័គ្រចិត្តកូរ៉េក្រៅប្រទេស (KOVs) លើកកម្ពស់ការអភិវឌ្ឍបច្ចេកទេសនិងការផ្ទេរបច្ចេកវិទ្យាទំនើបតាមរយៈការផ្តល់ជំនួយបច្ចេកទេស ដោយមានការបញ្ជូនអ្នកស្ម័គ្រចិត្តឲ្យរស់

នៅនិងធ្វើការជាមួយសហគមន៍ក្នុងស្រុកនៅក្នុងប្រទេសកម្ពុជា។ កាលឆ្នាំ២០០១ កិច្ចព្រមព្រៀងបញ្ជូនអ្នកស្ម័គ្រចិត្តត្រូវបានចុះហត្ថលេខារវាងរដ្ឋាភិបាលកូរ៉េនិងរាជរដ្ឋាភិបាលកម្ពុជា។ លុះដល់ឆ្នាំ២០០៣ ទើបមានការបញ្ជូនអ្នកស្ម័គ្រចិត្តជនជាតិកូរ៉េ មកកម្ពុជាជាលើកដំបូង ដើម្បីមកចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធ ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកម្ពុជា។ គិតត្រឹមឆ្នាំ ២០១៧ មានអ្នកស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីនេះចំនួន ៥១៧នាក់ ត្រូវបានបញ្ជូនមកកម្ពុជា ដោយបានធ្វើការក្នុងវិស័យដូចជា ការអប់រំនិងបណ្តុះបណ្តាល ទៅលើផ្នែកសុខាភិបាល ការអភិវឌ្ឍជនបទ និងព័ត៌មាននិងទំនាក់ទំនងបច្ចេកវិទ្យា (ICT)។

**អត្ថប្រយោជន៍សម្រាប់ WFK – KOV[30]៖**

**១. ផ្នែកហិរញ្ញវត្ថុ**

- KOICA ផ្តល់ជូនអ្នកស្ម័គ្រចិត្តនូវប្រាក់ឧបត្ថម្ភការស្នាក់នៅ រួមនិងថ្លៃកន្លែងស្នាក់នៅ។ ការចំណាយនេះ មានការប្រែប្រួលទៅតាមភាពជាក់ស្តែងនៃតម្លៃការស្នាក់នៅ តាមទីតាំងដែលពួកគាត់បំពេញការងារ។
- KOICA ផ្តល់មូលនិធិក្នុងការបំពេញការងាររបស់អ្នកស្ម័គ្រចិត្ត នៅពេលដែលពួកគាត់បានបញ្ចប់ភារកិច្ច ដើម្បីជួយសម្រួលដល់ការវិលត្រលប់ទៅកាន់ប្រទេសកំណើតវិញ។ ក្នុងអំឡុងពេលបំពេញការងារនេះ ពួកគាត់អាចទទួលបានទឹកប្រាក់ចំនួន USD ៣៥០ ក្នុងមួយខែ។ ហេតុនេះ បើអ្នកស្ម័គ្រចិត្តបានបញ្ចប់កិច្ចសន្យារយៈពេល ២ឆ្នាំ ពួកគាត់អាចទទួលបាន USD ៨ ៤០០។
- KOICA ផ្តល់សំបុត្រយន្តហោះធ្វើដំណើរទៅ-មក ការចំណាយសម្រាប់ការចាកចេញ ការសម្របខ្លួន និងការវិលត្រលប់ (ស្មើនឹងប្រាក់ធានាសម្រាប់ការស្នាក់នៅពួកគាត់មួយខែ)។

**២. ផ្នែកសុខភាព**

- អ្នកស្ម័គ្រចិត្តអាចទទួលបានអត្ថប្រយោជន៍ពីគ្រូពេទ្យយ៉ាងទូលំទូលាយ រាប់ពីការចាក់ថ្នាំបង្ការនិងចូលមន្ទីរពេទ្យ រហូតការវាយតម្លៃសុខភាពតាមវេជ្ជសាស្ត្រ។ ដូចនេះអ្នកស្ម័គ្រ-ចិត្ត អាចទទួលបានការពិគ្រោះជំងឺ ២៤/៧ តាមរយៈការសង្គ្រោះបន្ទាន់ជាអន្តរជាតិ។

**៣. ផ្នែកសុវត្ថិភាព**

- KOICA ផ្តល់ការបណ្តុះបណ្តាលជំនាញការពារខ្លួនដល់អ្នកស្ម័គ្រចិត្ត ទាំងមុននិងអំឡុងពេលបំពេញការងារ ដើម្បីត្រៀមខ្លួនចំពោះហានិភ័យដែលកើតមាន។

---

[30] https://kov.koica.go.kr/benefits/benefits.koica (ចូលទស្សនាថ្ងៃទី២៥ ឧសភា ២០១៩)

- KOICA ក៏មានការត្រួតពិនិត្យកន្លែងស្នាក់នៅ និងកន្លែងធ្វើការរបស់អ្នកស្ម័គ្រចិត្តជាមុនផងដែរ ដើម្បីធានាសុវត្ថិភាពអ្នកស្ម័គ្រចិត្ត។
- KOICA ក៏ផ្តល់នូវសម្ភារចាំបាច់ទាំងអស់សម្រាប់ការពារសុវត្ថិភាព ដូចជាឧបករណ៍ការពារខ្លួន ដើម្បីឲ្យពួកគាត់ត្រៀមខ្លួនក្នុងករណីដែលមានឧបសគ្គ។
- KOICA តែងមានការពិនិត្យមើលសុវត្ថិភាពជាទូទៅនៃប្រទេស ដែលអ្នកស្ម័គ្រចិត្តត្រូវបានបញ្ជូន មួយឆ្នាំម្តង។ យោងតាមការវាយតម្លៃ KOICA ក៏បានផ្តល់សេវាសន្តិសុខដល់បណ្តាប្រទេសដែលចាំបាច់ផងដែរ។ ជាមួយនឹងសេវាកម្មមួយនេះ អ្នកស្ម័គ្រចិត្តនឹងត្រូវជម្លៀសចេញទៅប្រទេសជិតខាង ឬប្រទេសកូរ៉េ ប្រសិនបើគ្រោះធម្មជាតិកើតឡើង ឬស្ថានភាពសន្តិសុខមិនអំណោយក្នុងប្រទេសនោះ។
- KOICA ក៏មានមជ្ឈមណ្ឌលផ្តល់ព័ត៌មានពីសុវត្ថិភាពរបស់ KOV នៅឯ KOICA ការិយាល័យកណ្តាល ដោយមានប្រតិបត្តិការ ២៤/៧។ ដូចនេះ ប្រសិនបើមានបញ្ហាកើតឡើងបន្ទាន់ ហើយអ្នកស្ម័គ្រចិត្តមិនអាចទាក់ទងជាមួយការិយាល័យក្នុងតំបន់ ឬការសង្គ្រោះបន្ទាន់ជាអន្តរជាតិ ដែល KOICA បានចុះកិច្ចសន្យាដើម្បីផ្តល់សេវាសន្តិសុខនោះបាន អ្នកស្ម័គ្រចិត្តអាចធ្វើការទំនាក់ទំនងទៅមជ្ឈមណ្ឌលដោយផ្ទាល់បាន។

**៤. អត្ថប្រយោជន៍ផ្សេងទៀត**

- KOICA ផ្តល់ជូនទឹកប្រាក់រហូតដល់ USD ២ ០០០ ដល់អ្នកស្ម័គ្រចិត្តដើម្បីធ្វើការបំពេញការងាររបស់ពួកគាត់។ អ្នកស្ម័គ្រចិត្តអាចទិញសម្ភារដែលចាំបាច់ដូចជា សៀវភៅ និងសម្ភារការិយាល័យជាដើម។
- KOICA ក៏ផ្តល់កញ្ចប់សម្ភារកូរ៉េ (ឧ. គ្រឿងកំប៉ុង) ដើម្បីលើកទឹកចិត្តពួកគាត់ ពីរដងក្នុងមួយឆ្នាំគឺ ថ្ងៃចូលឆ្នាំ និងថ្ងៃរំលឹកគុណម្តាយរបស់កូរ៉េ។
- អ្នកស្ម័គ្រចិត្តអាចអនុវត្តគម្រោងខ្នាតតូច ដែលមានតម្លៃដល់ USD៥០ ០០០ ដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃស្ថាប័នក្នុងស្រុក ហើយគម្រោងនេះនឹងទទួលបាននូវគាំទ្រពី KOICA ។

តារាងទី២.៤ ៖ បច្ចុប្បន្នភាពនៃចំនួនសហប្រតិបត្តិការរបស់ KOVs គិតត្រឹមខែ តុលា ឆ្នាំ ២០១៧

| ទីកន្លែងបម្រើការងារ | KOVs | | សរុប |
|---|---|---|---|
| | ប្រុស | ស្រី | |
| ភ្នំពេញ | ៦ | ៧ | ១៣ |
| បន្ទាយមានជ័យ | ៣ | ១ | ៤ |

| | | | |
|---|---|---|---|
| បាត់ដំបង | ៥ | ១ | ៦ |
| កំពង់ចាម | ១ | ៣ | ៤ |
| កំពង់ឆ្នាំង | ១ | ១ | ២ |
| កំពង់ស្ពឺ | ១ | ០ | ១ |
| កំពង់ធំ | ១ | ៣ | ៤ |
| កំពត | ២ | ២ | ៤ |
| ក្រចេះ | ១ | ២ | ៣ |
| ព្រៃវែង | ១ | ២ | ៣ |
| ពោធិ៍សាត់ | ២ | ០ | ២ |
| រតនគីរី | ០ | ២ | ២ |
| សៀមរាប | ០ | ២ | ២ |
| ស្ទឹងត្រែង | ១ | ១ | ២ |
| តាកែវ | ១ | ២ | ៣ |
| ត្បូងឃ្មុំ | ១ | ០ | ១ |
| សរុប | ២៧ | ២៩ | ៥៦នាក់ |

| ក្រសួងដែល KOVs បម្រើការងារ | KOVs សរុប |
|---|---|
| ក្រសួងអប់រំ យុវជន និងអប់រំ | ៤៧ |
| ក្រសួងសុខាភិបាល | ៦ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣ |
| សរុប | ៥៦នាក់ |

*(ប្រភព ៖ KOICA Cambodia)*

តារាងទី២.៥ ៖ សកម្មភាពកិច្ចសហប្រតិបត្តិការរបស់ KOVs ក្នុងឆ្នាំ ២០១៨

| ក្រសួងដែល KOVs បម្រើការងារ | KOVs សរុប |
|---|---|
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ |
| ក្រសួងសុខាភិបាល | ១ |
| ក្រសួងទេសចរណ៍ | ២ |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៣ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ៤ |
| អង្គការឯករាជ្យ | ៦ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៩ |
| ក្រសួងអប់រំ យុវជន និងកីឡា | ៤២ |
| សរុប | ៧៨ |

*(ប្រភព ៖ KOICA Cambodia)*

ចាប់ពីឆ្នាំ ២០០៣ដល់ឆ្នាំ២០១៨ មានអ្នកស្ម័គ្រចិត្តចំនួន ៣៥១នាក់[31] បានបម្រើការងារក្នុង MoEYS ដូចជា ភាសាកូរ៉េ អប់រំសុខភាព កុមារតូច វិទ្យាសាស្ត្រ កីឡា គំនូរ កំព្យូទ័ និងតៃក្វាន់ដូ។

ក្រាហ្វិកទី២.២ ៖ បង្ហាញពីបច្ចុប្បន្នភាពនៃសមាមាត្រអ្នកស្ម័គ្រចិត្តកូរ៉េតាមផ្នែក ឆ្នាំ ២០១៨




*(ប្រភព ៖ KOICA Cambodia)*

### ខ. កម្មវិធីមិត្តភក្តិពិភពលោកទីប្រឹក្សា KOICA ( WFK Advisors )

កម្មវិធីមិត្តភក្តិពិភពលោកទីប្រឹក្សាKOICA (WFK Advisors) ជាកម្មវិធីដែលបញ្ជូនអ្នកជំនាញជនជាតិកូរ៉េ ដែលមានបទពិសោធជាច្រើនឆ្នាំក្នុងវិស័យផ្សេងៗមកកាន់ប្រទេសកម្ពុជា។ កម្មវិធីនេះមានគោលបំណងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា នៅក្នុងការវិភាគ និងរៀបចំផែនការអភិវឌ្ឍន៍ ក៏ដូចជាការប្រឹក្សាយោបល់ផ្នែកបច្ចេកវិទ្យានិងគ្រប់គ្រងសម្រាប់ការលើកកម្ពស់គម្រោងអភិវឌ្ឍន៍នានា។

គួរបញ្ជាក់ផងដែរថា ទីប្រឹក្សាទាំងនោះមានឯកទេសកម្មលើផ្នែកដូចជា រដ្ឋបាល អប់រំ កសិកម្ម សុខាភិបាលជាដើម ដែលត្រូវបានបញ្ជូនទៅប្រទេសដៃគូ ដើម្បីផ្លាស់ប្តូរចំណេះដឹងនិងការណែនាំអំពីគោលនយោបាយនានា។ ចំណេះដឹងនិងជំបូន្មាន ដែលទីប្រឹក្សាផ្តល់ឲ្យប្រទេសជាដៃគូ គឺជាទ្រព្យវិជ្ជាដ៏សំខាន់ ដែលអាចប្រើប្រាស់ក្នុងការលុបបំបាត់ភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព ។

[31] https://www.cpp.org.kh/details/96060 (ចូលទស្សនាថ្ងៃទី ១៥ មេសា ២០១៩)

តារាងទី២.៦ ៖ ទិន្នន័យអ្នកស្ម័គ្រចិត្ត WFK Advisors តាមស្ថាប័ននានានៅកម្ពុជា ចាប់ពីឆ្នាំ ២០១២ - ២០១៦

| ឆ្នាំ | វិស័យរបស់ KOICA | ភ្នាក់ងារទទួល WFK Advisors | សរុប | |
|---|---|---|---|---|
| ២០១២ | រដ្ឋបាលសាធារណៈ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ | ៣ |
| | បច្ចេកវិទ្យា បរិស្ថាន និងថាមពល | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ២ | |
| ២០១៣ | អប់រំ | សាលាបច្ចេកទេស | ១ | ៨ |
| | | ITC | ១ | |
| | | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ១ | |
| | រដ្ឋបាលសាធារណៈ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២ | |
| | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រសួងអភិវឌ្ឍន៍ជនបទ | ១ | |
| | បច្ចេកវិទ្យា បរិស្ថាន និងថាមពល | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ២ | |
| ២០១៤ | អប់រំ | ក្រសួងមុខងារសាធារណៈ | ២ | ៨ |
| | | ITC | ១ | |
| | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រសួងអភិវឌ្ឍន៍ជនបទ | ១ | |
| | | សាកលវិទ្យាល័យកសិកម្ម | ១ | |
| | | សាកលវិទ្យាល័យបាត់ដំបង | ១ | |
| | រដ្ឋបាលសាធារណៈ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ | |
| | សុខាភិបាល | ក្រសួងអប់រំ យុវជន និងកីឡា | ១ | |
| ២០១៥ | សុខាភិបាល | មជ្ឈមណ្ឌលជាតិសម្រាប់ឱសថបុរាណ | ១ | ២០ |
| | | ក្រសួងអប់រំ យុវជន និងកីឡា | ១ | |
| | រដ្ឋបាលសាធារណៈ | គណៈកម្មាធិកាប៉ារ៉ាឡាំពិកជាតិកម្ពុជា | ១ | |
| | | CDC | ១ | |
| | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ | |
| | | នាយកដ្ឋានលើកកម្ពស់សហករណ៍កសិកម្ម | ១ | |
| | | ធនាគារជាតិកម្ពុជា | ១ | |
| | បច្ចេកវិទ្យា បរិស្ថាន និងថាមពល | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ១ | |
| | អប់រំ | ក្រសួងមុខងារសាធារណៈ | ១ | |

| | | | | |
|---|---|---|---|---|
| | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សាកលវិទ្យាល័យបាត់ដំបង | ៣ | |
| | | ក្រសួងធនធានទឹក និងឧត្តុនិយម | ១ | |
| | | សាកលវិទ្យាល័យកសិកម្ម | ២ | |
| | | MAFF | ១ | |
| | | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១ | |
| | | ក្រសួងអភិវឌ្ឍន៍ជនបទ | ១ | |
| | | ក្រសួងអភិវឌ្ឍន៍ជនបទ | ១ | |
| ២០១៦ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សាកលវិទ្យាល័យកសិកម្ម | ៣ | ២៩ |
| | | សាកលវិទ្យាល័យបាត់ដំបង | ៤ | |
| | | MAFF | ១ | |
| | | ក្រសួងធនធានទឹក និងឧត្តុនិយម | ១ | |
| | | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១ | |
| | អប់រំ | ក្រសួងមុខងារសាធារណៈ | ២ | |
| | សុខាភិបាល | មជ្ឈមណ្ឌលជាតិសម្រាប់ឱសថបុរាណ | ២ | |
| | រដ្ឋបាលសាធារណៈ | គណៈកម្មាធិកាប៉ារ៉ាឡាំពិកជាតិកម្ពុជា | ២ | |
| | | នាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត | ១ | |
| | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ | |
| | | CDC | ២ | |
| | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២ | |
| | | សាកលវិទ្យាល័យជាតគ្រប់គ្រង | ១ | |
| | | នាយកដ្ឋានលើកកម្ពស់សហករណ៍កសិកម្ម | ២ | |
| | | ធនាគារជាតិកម្ពុជា | ២ | |
| | បច្ចេកវិទ្យា បរិស្ថាន និងថាមពល | វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស | ២ | |
| **សរុប** | | | | ៥៨ |

*(ប្រភព ៖ 통합사업관리 stat.koica.go.kr)*

តារាងទី២.៧ ៖ បច្ចុប្បន្នភាពសហប្រតិបត្តិការរបស់អ្នកស្ម័គ្រចិត្ត WFK Advisors គិតត្រឹមខែតុលា ឆ្នាំ ២០១៧

| ទីកន្លែងបម្រើការងារ | WFK Advisors | | សរុប |
|---|---|---|---|
| | ប្រុស | ស្រី | |
| ភ្នំពេញ | ១១ | ០ | ១១ |
| បាត់ដំបង | ២ | ០ | ២ |
| សរុប | ១៣ | ០ | ១៣នាក់ |

| ក្រសួងដែល WFK Advisors បម្រើការងារ | WFK Advisors សរុប |
|---|---|
| ក្រសួងអប់រំ យុវជន និងអប់រំ | ៥ |
| ក្រសួងរដ្ឋបាលសាធារណៈ | ៥ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២ |
| ក្រសួងឧស្សាហកម្ម និងថាមពល | ១ |
| សរុប | ១៣ |

*(ប្រភព ៖ KOICA Cambodia)*

ក្រាហ្វិកទី២.៣ ៖ អ្នកស្ម័គ្រចិត្ត WFK Advisors នៅតាមក្រសួងក្នុងឆ្នាំ ២០១៨




*(ប្រភព ៖ KOICA Cambodia)*

រូបភាពទី២៖ ផែនទីបច្ចុប្បន្នភាពបែងចែកអ្នកស្ម័គ្រចិត្តKOICA នៅកម្ពុជាគិតត្រឹមខែ តុលា ២០១៧




*(ប្រភព ៖ KOICA Cambodia)*

### ២.៥.៦. ផ្សេងៗទៀត

#### ២.៥.៦.១. សមាគមអតីតកម្មសិក្សាការី កម្ពុជា-កូរ៉េ (CAMKAA)[32]

KOICA បានទ្រទ្រង់សមាគមអតីតកម្មសិក្សាការី កម្ពុជា-កូរ៉េ ឬហៅកាត់ថា ស.អ.ក.ក. ឬ CAMKAA ដើម្បីសម្របសម្រួលការចែករំលែកចំណេះដឹង ជំនាញ និងធនធានរវាងអ្នកចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ KOICA ទាំងអស់។

CAMKAA ត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ ២០០២ មកម្ល៉េះ ដែលស្ថិតក្រោមការឧបត្ថម្ភរបស់ KOICA ការិយាល័យកណ្តាល។ គួរបញ្ជាក់ផងដែរថា ដំបូងឡើយឈ្មោះរបស់សមាគមមួយនេះគឺ **ក្លឹបខ្ញុំស្រលាញ់ប្រទេសកូរ៉េ**។ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៧ សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្លឹបនេះ បានប្រារព្ធធ្វើការប្រជុំមួយដោយ គោលបំណងសំខាន់នៃកិច្ចប្រជុំនេះគឺ ការផ្លាស់ប្តូរ ឈ្មោះក្លឹបទៅជា **សមាគមអតីតកម្មសិក្សាការី កម្ពុជា-កូរ៉េ** ហើយចាប់តាំងពីពេលនោះ

[32] https://camkaa.wordpress.com/ (ចូលទស្សនាថ្ងៃទី ២០ មេសា ២០១៩)

មកត្រូវបានគេស្គាល់តាមរយៈអក្សរកាត់ CAMKAA។ លុះដល់ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០៧ ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តការបង្កើត CAMKAA[33]។

**គោលបំណងនៃសមាគមមួយនេះមានដូចតទៅ៖**

- ជំរុញភារតភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមអ្នកចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាលនៅសាធារណៈរដ្ឋកូរ៉េ ដែលឧបត្ថម្ភដោយ KOICA
- បង្កើនភាពជាដៃគូជានិរន្តរភាពរវាងប្រទេសកូរ៉េ និងប្រទេសកម្ពុជា
- សម្របសម្រួល ចែករំលែកចំណេះដឹង ជំនាញ និងធនធានក្នុងចំណោមអ្នកបញ្ចប់ការសិក្សាដែលរៀបចំដោយ KOICA ដូចជា សន្និសីទ សិក្ខាសាលា វេទិកា
- ពង្រីកសេវាកម្មគំរូល្អៗឲ្យបានទូលំទូលាយ ដើម្បីបម្រើប្រយោជន៍សាធារណៈ
- បណ្តុះបណ្តាលផ្នែកសិក្សាអប់រំវប្បធម៌និងសង្គមកិច្ច ហើយមានគោលបំណងមិនស្វែងរកប្រាក់ចំណេញឡើយ ។

**សកម្មភាពរបស់សមាគម** បានប្រឹងប្រែងសម្រេចគោលបំណងរបស់ខ្លួនដោយ៖

- រៀបចំកិច្ចប្រជុំ ការតាំងពិពណ៌ បាឋកថា ឬសិក្ខាសាលាផ្សេងៗ
- ផ្សព្វផ្សាយព័ត៌មានតាមសាធារណៈ ការបោះពុម្ពព្រឹត្តិបត្រ ទស្សនាវដ្តី របាយការណ៍ព័ត៌មាន និងតាមបណ្តាញអេឡិចត្រូនិក។
- រៀបចំកម្មវិធីទស្សនកិច្ចសិក្សានៅកម្ពុជា កូរ៉េ និងនៅប្រទេសដទៃទៀត
- ធ្វើសកម្មភាពដោយស្ម័គ្រចិត្ត ដើម្បីបម្រើផលប្រយោជន៍សាធារណៈ
- រៀបចំកម្មវិធីផ្សេងៗដែលសមាគមយល់ថាជាការចាំបាច់។

### ២.៥.៦.២. ក្រុមសុខសប្បាយ (SST)

អ្នកស្ម័គ្រចិត្តកូរ៉េប្រចាំកម្ពុជា បានបង្កើតក្រុមស្ម័គ្រចិត្តផ្ទាល់ខ្លួន ដែលមានឈ្មោះថា ក្រុមសុខសប្បាយ។ ពួកគេបានប្រជុំគ្នារៀងរាល់មួយខែម្តង ក្នុងអំឡុងពេលចុងសប្តាហ៍ រឺថ្ងៃឈប់សម្រាក ហើយពួកគេបានចុះដល់កន្លែងនានាក្នុងសហគមន៍ និងកន្លែងការងាររបស់អ្នកស្ម័គ្រចិត្តក្រោមសកម្មភាពដូចជា ផ្នែកសុខភាព និងអប់រំ។

ក្រុមនេះ ត្រូវបានបង្កើតឡើងកាលពីឆ្នាំ ២០០៤ ដោយអ្នកស្ម័គ្រចិត្តគិលានុបដ្ឋាយិកា ក្នុងគោលបំណងអភិវឌ្ឍន៍ជនបទ។ ក្រោយមក នៅខែវិច្ឆិកា ឆ្នាំ២០០៦ បន្ទាប់ពីក្រុមអ្នកស្ម័គ្រចិត្តទាំងនោះបានបញ្ចប់បេសកកម្មរបស់ខ្លួនអស់ ក៏មានអ្នកស្ម័គ្រចិត្តមកថ្មី ហើយបានបន្តធ្វើការងារ

[33] ឧបសម្ព័ន្ធ

ក្រុមជាមួយក្រុមសុខសប្បាយ ដោយមានសកម្មភាពផ្សេងៗជាច្រើន ជាពិសេសអ្នកស្ម័គ្រចិត្តផ្នែកអប់រំ បានចូលរួមការបង្រៀនដល់កុមារកម្ពុជា។ ពីពេលនោះមក ឈ្មោះក្រុមសុខសប្បាយក៏បានបង្កើតឡើង។ បន្ទាប់មកនៅថ្ងៃទី៣១ ខែធ្នូ ក្រុមការងារនេះ ទទួលបាន USD ២០០ ដុល្លារពីការលក់របស់របរ ដែលបានបរិច្ចាគពីអ្នកស្ម័គ្រចិត្តសិស្សច្បង និងប្រើថវិកានេះចាប់ផ្តើមក្រុមថ្មីរបស់ក្រុមសុខសប្បាយ។

រហូតមកដល់ឆ្នាំ ២០០៩ សមាជិកក្រុមទាំងអស់បានជួបជុំគ្នា ក្នុងគោលបំណងពិភាក្សាពីចំណុចខ្សោយរបស់ក្រុម ហើយជាលទ្ធផលបានបង្ហាញថា ដើម្បីបង្កើនសកម្មភាពស្ម័គ្រចិត្តនៅក្នុងប្រទេសកម្ពុជា ក្រុមមួយនេះបានបែងចែកជា៣ក្រុមគឺមាន ក្រុមគ្រូពេទ្យ ក្រុមអប់រំ និងក្រុមកំសាន្ត។ លើសពីនេះ ក្រុមការងារនេះមិនត្រឹមតែផ្តល់ការគាំទ្រស្ម័គ្រចិត្តដល់ប្រជាជននៅតាមតំបន់ជនបទប៉ុណ្ណោះទេ តែក៏ត្រូវស្វែងរកតំបន់ដែលត្រូវការជំនួយជាបន្ទាន់ ដើម្បីជួយគាំទ្រដែរ។

គួរបញ្ជាក់ផងដែរថា មានអ្នកស្ម័គ្រចិត្តជាង ២០នាក់បានជួបជុំគ្នារៀងរាល់ខែ និងបរិច្ចាគលុយរបស់ពួកគេរៀងៗខ្លួនក្នុងម្នាក់ USD ១០ ដុល្លារសម្រាប់សកម្មភាពស្ម័គ្រចិត្តរបស់ពួកគេនៅក្នុងតំបន់ដែលត្រូវការជំនួយ។ ប៉ុន្តែដោយសារតែក្រុមសុខសប្បាយបានពង្រីកសកម្មភាពគាំទ្ររបស់ពួកគេ ដូចនេះពួកគេប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុ ហើយបន្ទាប់មក KOICA ក៏បានគាំទ្រក្រុមនេះដោយមានការផ្តល់ជាយានយន្ត។ល។ ហើយការគាំទ្រនេះជួយឲ្យក្រុមសុខសប្បាយធ្វើការងារស្ម័គ្រចិត្តរបស់ពួកគេកាន់តែមានប្រសិទ្ធភាព។

# ជំពូកទី៣

# ការសិក្សាលើលទ្ធផលស្រាវជ្រាវ

# ជំពូកទី ៣ ការសិក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១. សមិទ្ធផល និង ការវាយតម្លៃ

### ៣.១.១. សមិទ្ធផលលើវិស័យអប់រំ

ការកសាងនិងការអភិវឌ្ឍធនធានមនុស្ស តាមរយៈការអប់រំ បណ្តុះបណ្តាលនិងការងារ គឺជាផ្នែកមួយនៃអាទិភាពសំខាន់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រោះការអភិវឌ្ឍធនធានមនុស្ស គឺជាឆ្អឹងខ្នងដ៏សំខាន់សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ នាប៉ុន្មានឆ្នាំចុងក្រោយនេះ មានការជួយជ្រោមជ្រែងពីដៃគូអភិវឌ្ឍន៍ដូចជា KOICA លើវិស័យអប់រំកម្ពុជាយ៉ាងច្រើន ដែលនេះបានធ្វើឲ្យមានភាពប្រសើរឡើងនៃប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជាគួរឲ្យកត់សម្គាល់ ។ តួយ៉ាង ដូចបង្ហាញនៅខាងក្រោមនេះពីសមិទ្ធផលលើវិស័យអប់រំ ដែលបានមកពីការចូលរួមចំណែកនៃជំនួយឥតសំណងរបស់រដ្ឋាភិបាលកូរ៉េតាមរយៈ KOICA ។

**ក. អត្រាសិស្សចូលរៀនកម្រិតបឋមសិក្សា**

ជាលទ្ធផល គេសង្កេតឃើញថា ក្រសួងអប់រំ យុវជន និងកីឡា កាន់តែឈានខិតជិតដល់ការសម្រេចបាននូវការផ្តល់សេវាជាសកលនៃការអប់រំថ្នាក់បឋមសិក្សា តាមរយៈការទទួលបាននូវ អត្រាសិស្សចុះឈ្មោះចូលរៀនចំនួន ៩៧,៧% ក្នុងឆ្នាំសិក្សា ២០១៦-២០១៧[34] ព្រមទាំងការពង្រឹងសមភាពផ្នែកយេនឌ័រក្នុងវិស័យអប់រំក៏មានភាពកាន់តែប្រសើរឡើងផងដែរ ដោយក្នុងនោះមានកុមារីចំនួន ៤៨,២%បានចុះឈ្មោះនៅថ្នាក់បឋមសិក្សា។ លទ្ធផលទាំងនេះ បានមកពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយអង្គការ ឬស្ថាប័នពាក់ព័ន្ធនានា ដូចជាដៃគូអភិវឌ្ឍន៍ KOICA និងបានសម្រេចជាផ្លែផ្កា លើការកម្ពស់គុណភាព និងតម្លៃអប់រំផងដែរ។

**ខ. កម្មសិក្សាការីកម្ពុជានៅកូរ៉េ**

ដើម្បីរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្សកម្ពុជា រដ្ឋាភិបាលកូរ៉េបានផ្តល់អាហារូបករណ៍ដល់មន្ត្រីរាជការកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទៅសិក្សានៅប្រទេសកូរ៉េជារៀងរាល់ឆ្នាំលើជំនាញជាច្រើន នៅថ្នាក់ក្រោយឧត្តមសិក្សា (ថ្នាក់អនុបណ្ឌិត)។ ជាក់ស្តែង ចាប់តាំងពីឆ្នាំ ១៩៩៤-២០១៧ តាមរយៈកម្មវិធីអាហារូបករណ៍ប្រទេសកូរ៉េរបស់ KOICA ផ្តល់ដល់មន្ត្រីរាជការកម្ពុជារហូតដល់ទៅ ២ ៩៤៦នាក់ ក្នុងនោះបានផ្តោតសំខាន់លើការសិក្សាលើមុខវិជ្ជាដែលរួមចំណែកជាអាទិភាពលើការកសាងសេដ្ឋកិច្ចនិងសង្គមកម្ពុជា។ ដូចនេះ បន្ទាប់ពីទទួលបានការសិក្សាអប់រំពីប្រទេសកូរ៉េមក កម្មសិក្សាការីត្រលប់មកកម្ពុជាវិញ ដោយនាំមកនូវចំណេះដឹង និង

[34] ឧបសម្ព័ន្ធ

បទពិសោធមកអនុវត្តន៍ក្នុងសង្គម ដើម្បីចូលរួមកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចម្រើនឡើង។

**គ. អាគារបណ្ដុះបណ្ដាល និងគ្រឿងបរិក្ខារសិក្សា**

ប្រទេសកូរ៉េ បានផ្ដល់ជំនួយតាមរយៈគម្រោងកសាងអាគារមជ្ឈមណ្ឌល ២កន្លែង និងសាលហ្វឹកហាត់តៃក្វាន់ដូចំនួន ១ខ្នង ដែលអាចឲ្យនិស្សិតកម្ពុជាជាច្រើននាក់ ទទួលបានចំណេះដឹងពាក់ព័ន្ធនឹងបច្ចេកវិទ្យា ក៏ដូចជាផ្នែកអាកាសចរណ៍ស៊ីវិល និងការធ្វើលំហាត់ប្រាណដើម្បីសុខភាពតាមរយៈការហ្វឹកហាត់តៃក្វាន់ដូផងដែរ។ ទន្ទឹមនឹងនោះ KOICA ក៏បានចូលរួមក្នុងការផ្គត់ផ្គង់សម្ភារ គ្រឿងបរិក្ខារសិក្សាដល់សាកលវិទ្យាល័យមួយចំនួននៅកម្ពុជា ដោយបានលើកកម្ពស់និងកែលម្អគុណភាពសាលារៀន ពិសេសថ្នាក់ឧត្តមសិក្សាឲ្យកាន់តែមានលក្ខណៈស្តង់ដារអន្តរជាតិ និងអាចឲ្យនិស្សិតកម្ពុជាកាន់តែមានភាពប្រកួតប្រជែងទាំងក្នុងតំបន់និងលើឆាកអន្តរជាតិ។

**ឃ. ផែនការមេស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើទំនើបកម្មប្រព័ន្ធអប់រំដោយមានការអនុវត្ត ផែនការមេស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិកម្ពុជា ឆ្នាំ ២០១៤-២០២០ ដែលត្រូវបានផ្សព្វផ្សាយ កាលពីខែតុលា ឆ្នាំ២០១៤ ដោយក្រសួងផែនការ ដែលមានការគាំទ្រពី KOICA។ ផែនការនេះដែរ មានការផ្តោតទៅលើ ធនធានមនុស្ស ការបណ្តុះបណ្តាល និងការលើកកម្ពស់អក្ខរកម្មឌីជីថល (រាប់បញ្ចូលទាំងអ្នករស់នៅតាមជនបទ) លទ្ធភាពប្រើប្រាស់កុំព្យូទ័ររបស់មន្ត្រីរដ្ឋាភិបាលកម្ពុជា ពង្រីកហេដ្ឋារចនាសម្ព័ន្ធខាងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណែត។ល។ គោលដៅជាក់លាក់នៃផែនការនេះ គឺធ្វើយ៉ាងណាឲ្យប្រជាជនកម្ពុជា អាចប្រើប្រាស់អ៊ីនធឺណែតបាន៧០% នៅឆ្នាំ២០២០។ ជាឧទាហរណ៍ជាក់ស្តែង ចំនួនអ្នកប្រើអ៊ីនធឺណែតនៅក្នុងប្រទេសកម្ពុជា បានកើនឡើងពី ៣២០ ២៩០ នាក់ ក្នុងឆ្នាំ ២០១០ រហូតដល់ ៦ ២៦៤ ៩០២ នាក់ ក្នុងខែមិថុនា ឆ្នាំ ២០១៥។[35] យោងតាមរបាយការណ៍ស្តីពី វិស័យឌីជីថល សង្គម និងទូរស័ព្ទចល័ត របស់អេភីអេស៊ី ឆ្នាំ ២០១៥ ការជ្រៀបចូលចំពោះការប្រើប្រាស់អ៊ិនធឺណែត មាន ២៥% ដែលមានកម្រិតនៅទាបនៅឡើយ បើធៀបនឹងអត្រាជ្រៀបចូលនូវការប្រើអ៊ីនធឺណែតនៅទូទាំងពិភពលោក ដែលមាន ៤២%នោះ។ ដោយសារការសហការយ៉ាងជិតស្និតរវាងរដ្ឋាភិបាល

[35] បញ្ញត្តិករទូរគមនាគមន៍កម្ពុជា. "ការជាវអ៊ីនធើណែត." https://www.trc.gov.kh/ (ចូលទស្សនាថ្ងៃទី ៣០ តុលា ២០១៥)។

កម្ពុជា ជាមួយនិងដៃគូអភិវឌ្ឍន៍ បាននជំរុញឲ្យមានកំណើនសេដ្ឋកិច្ចក្នុងប្រទេស និងបានបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ អាចមានលទ្ធភាពប្រើប្រាស់ទូរស័ព្ទស្មាតហ្វូន និងបច្ចេកវិទ្យាថ្មីៗ ដែលមានតំណភ្ជាប់អ៊ិនធឺណែតក្នុងតម្លៃសមរម្យ រហូតដល់ឆ្នាំ២០១៨ តួរលេខអ្នកប្រើប្រាស់អ៊ីនធឺណែតបានបន្តកើនឡើងរហូតដល់១២,៥លាននាក់។ [36] ចំពោះការកើនឡើងអ្នកប្រើប្រាស់ក៏បានបង្ហាញពីភាពរីកចម្រើនផ្នែកសេវាកម្មរបស់ក្រុមហ៊ុនទូរស័ព្ទចល័តនៅតាមជនបទផងដែរ។

ហេតុនេះ ការអនុម័តផែនការមេមួយនេះ បាននិងកំពុងជំរុញអោយមានការប្រើអ៊ីនធឺណែតតាមតម្រូវការនាពេលអនាគត ជាពិសេសនៅក្នុងវិស័យឧស្សាហកម្ម។

**ខ. គម្រោងអភិវឌ្ឍន៍ផ្នែកបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ**

គម្រោងនេះបានផ្តោតលើ ការកសាងផែនការមេនិងផែនការសកម្មភាព ការរៀបចំកម្មវិធីនិងសៀវភៅសិក្សា ការបណ្តុះបណ្តាលគ្រូនៅក្នុងប្រទេសកម្ពុជា និងនៅសាធារណរដ្ឋកូរ៉េ កម្មវិធីទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ ការអភិវឌ្ឍសមត្ថភាពមន្ត្រីផ្នែកអប់រំបច្ចេកទេស។

ហេតុនេះ វាជាការរួមចំណែកក្នុងការអភិវឌ្ឍវិស័យអប់រំកម្ពុជាប្រកបដោយគុណភាព និងប្រសិទ្ធភាព ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគត។

**ច. សមិទ្ធផល** CKCC

ដោយសារតម្រូវការបច្ចេកវិទ្យាព័ត៌មានវិទ្យានៅក្នុងប្រទេសកម្ពុជាកើនឡើង មជ្ឈមណ្ឌល CKCC បាននិងកំពុងផ្តល់ការបណ្តុះបណ្តាលបច្ចេកវិទ្យា ព័ត៌មានវិទ្យា ដោយឥតគិតថ្លៃដល់និស្សិតសាកលវិទ្យាល័យ។ មជ្ឈមណ្ឌលធនធានមនុស្ស ដែលបានបង្កើតឡើងនៅខែមេសា ឆ្នាំ២០១៣ បានផ្តល់វគ្គបណ្តុះបណ្តាលឥតគិតថ្លៃដល់និស្សិតកម្ពុជាជាង ២០០នាក់ ដោយគិតត្រឹមឆ្នាំ ២០១៥ ហើយក្នុងចំណោមអ្នកទាំងនេះ មានប្រហែល ៣០នាក់កំពុងធ្វើការនៅក្នុងក្រុមហ៊ុន IT នៅក្នុងប្រទេសកូរ៉េខាងត្បូង ខណៈពេលដែលអ្នកផ្សេងទៀតកំពុងតែធ្វើការនៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យាក្នុងស្រុកនៅកម្ពុជា។[37]

**ឆ. សមិទ្ធផល** CATC

បើក្រឡេកទៅមើលលើវិស័យអាកាសចរណ៍នៅកម្ពុជា ដែលកំពុងមានសន្ទុះខ្លាំងគួរឲ្យកត់សម្គាល់នោះ សង្កេតឃើញថា ក្រោមជំនួយឥតសំណងពីរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េតាមរយៈ KOICA បានកសាង CATC ដែលជាមជ្ឈមណ្ឌលអាកាសចរណ៍ស៊ីវិលដំបូងគេនៅកម្ពុជា បានរួម

[36] https://business-combodia.com/article/921 (ចូលទស្សនាថ្ងៃទី ១១ កក្កដា ២០១៩)

[37] Baek Sook Hee, "សេចក្តីថ្លែងសន្ទរកថា," (សិក្ខាសាលា ការចែករំលែកចំណេះដឹង, KOICA ប្រចាំកម្ពុជា, ៥ កញ្ញា ២០១៥)។

ចំណែកក្នុងការលើកកម្ពស់ជំនាញក្នុងផ្នែកអាកាសចរណ៍ស៊ីវិល និងបង្កើតប្រព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពសម្រាប់ធនធានមនុស្សកម្ពុជា។ កម្មវិធីបណ្តុះបណ្តាលនៅ CATC បានគ្របដណ្តប់លើមុខវិជ្ជាជាច្រើនដោយនៅឆ្នាំ២០១៧ មជ្ឈមណ្ឌលមួយនេះបានរៀបចំវគ្គសិក្សាចំនួន ១៥វគ្គ ហើយមានអ្នកចូលរួមចំនួន ២៦១នាក់។ ចំណែកឆ្នាំ២០១៨ CATC បានបង្កើតជំនាញថ្មីៗជាច្រើន ដើម្បីពង្រីកជំនាញអាកាសចរណ៍ ដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនៅកម្ពុជានេះ ពោលគឺបានបើកវគ្គសិក្សាចំនួន ២៦វគ្គ។ រហូតដល់ឆមាសទី ១ នៃឆ្នាំ ២០១៨ CATC បានរៀបចំនិងបញ្ចប់វគ្គបណ្តុះបណ្តាលចំនួន ១៧វគ្គ ដោយមានអ្នកបញ្ចប់ការបណ្តុះបណ្តាលសរុបចំនួន ២៧៨នាក់ ។[38]

**ឆ. សមិទ្ធផល** CKTTC

ដោយឡែកចំពោះ វិស័យកីឡានៅប្រទេសកម្ពុជាវិញ កន្លងមក KOICA បានចូលរួមចំណែកយ៉ាងខ្លាំងលើប្រភេទកីឡាតែក្វាន់ដូ ដែលកាលឆ្នាំ២០១៧ កូរ៉េបានផ្តល់សាលហ្វឹកហាត់តែក្វាន់ដូមួយដល់ វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។ គិតមកត្រឹមឆ្នាំ២០១៧ គរុសិស្សអប់រំកាយនិងកីឡាចំនួន ២៨០នាក់[39]ហើយ ដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាតែក្វាន់ដូ ហើយក្រោយទទួលបានចំណេះដឹងពីទីនេះ ពួកគាត់នឹងក្លាយជាអ្នកផ្សព្វផ្សាយបន្តទៀត នៅពេលដែលពួកគាត់ចេញទៅបម្រើការងារនៅតាមសាលារៀននានានៅទូទាំងប្រទេសកម្ពុជា ។

**ជ. សមិទ្ធផល** KCNSA

ចំពោះគម្រោង លើកកម្ពស់គុណភាពសិក្សានិងកែលម្អសាលាជាតិកសិកម្មខេត្តកំពង់ចាម បានចូលរួមចំណែកជាច្រើនក្នុងការកសាងធនធានមនុស្សផ្នែកកសិកម្ម ដោយកាលពីឆ្នាំ ២០១៧ មានសិស្សចំនួនជិត ៣០០នាក់បានបញ្ចប់ការសិក្សា។[40] ហេតុនេះ តាមរយៈគម្រោងមួយនេះនឹងមានការកើនឡើងធនធានមនុស្សក្នុងវិស័យមួយនេះ ដែលអាចអភិវឌ្ឍន៍ការរស់នៅតាមជនបទកាន់តែប្រសើរឡើងបន្ថែមទៀត ។

[38] ម៉ៅ ហាវណ្ណាល់, "សេចក្តីថ្លែងសន្ទរកថា," (ពិធីសម្ពោធមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរណ៍ស៊ីវិល (CATC), CATC, ៥ កក្កដា ២០១៨)។

[39] ហង្ស ជួនណារ៉ុន, "សេចក្តីថ្លែងសន្ទរកថា," (ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ សាលហ្វឹកហាត់តែក្វាន់ដូ (CKTTC), NIPES, ១២ មករា ២០១៧)។

[40] សួន សេរី, "សេចក្តីថ្លែងសន្ទរកថា," (សិក្ខាសាលាពិគ្រោះយោបល់ ស្តីពី ការធ្វើឲ្យប្រសើរឡើងគុណភាពសិក្សា និងកែលម្អសាលាជាតិកសិកម្មកំពង់ចាម, សណ្ឋាគារអាំងតែណង់ទីណង់តាល់, ១៨ មករា ២០១៨)។

### ៣.១.២. ការវាយតម្លៃ

ជាការពិតណាស់ ធនធានមនុស្សមានសារៈសំខាន់ ដែលមិនអាចប្រកែកបានឡើយក្នុងការអភិវឌ្ឍប្រទេសទាំងអស់នៅក្នុងពិភពលោក មិនថាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍឧស្សាហកម្ម ឬក៏សម្រាប់ប្រទេសអភិវឌ្ឍន៍ ដែលមានភាពចាស់ទុំក្នុងវិស័យឧស្សាហកម្មហើយនោះទេ។ ដើម្បីទទួលបានធនធានមនុស្សកាន់តែច្រើនទាំងបរិមាណ និងគុណភាពនៅក្នុងប្រជាជាតិមួយ ការអភិវឌ្ឍវិស័យអប់រំត្រូវបានទទួលស្គាល់ថាជាយន្តការដ៏មានប្រសិទ្ធភាពបំផុត។ ទាក់ទងទៅនឹងវិស័យអប់រំនេះ ប្រទេសកូរ៉េបានចូលរួមសម្របសម្រួល និងផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការជាច្រើន ដើម្បីពង្រឹងគុណភាពអប់រំ ព្រមទាំងសមត្ថភាពធនធានមនុស្សនៅកម្ពុជា ដែលតាមរយៈរូបភាពទាំងនេះ បានផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសកំពុងអភិវឌ្ឍន៍មួយនេះ។

#### ៣.១.២.១. ការកើនឡើងធនធានមនុស្ស និងកាត់បន្ថយការចំណាយលើការអប់រំ

ការអភិវឌ្ឍធនធានមនុស្ស គឺជាភារកិច្ចសំខាន់មួយរបស់KOICA ក្នុងវិស័យអាទិភាពអប់រំ។ កន្លងមក ការបណ្តុះបណ្តាលធនធានមនុស្សផ្នែក ICT នៅប្រទេសកម្ពុជា ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារដែលមាននាពេលបច្ចុប្បន្ន នៅមានកម្រិតនៅឡើយ។ ហេតុនេះ ក្នុងនាមជាគម្រោងដ៏សំខាន់របស់ KOICA មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានផ្តល់នូវបរិយាកាស និងស្តង់ដាសិក្សាល្អ ដល់និស្សិតសាកលវិទ្យាល័យ អ្នកស្រាវជ្រាវ និងប្រជាជនក្នុងស្រុក។ មិនតែប៉ុណ្ណោះ CKCC បាននិងកំពុងតែផ្តល់ជូននូវកម្មវិធីអប់រំជាច្រើន ដោយផ្តោតលើបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង និងវគ្គសិក្សាភាសាកូរ៉េផងដែរ។ តាមរយៈការបណ្តុះបណ្តាលទាំងនេះ អាចឲ្យនិស្សិតកម្ពុជាមានចំណេះដឹង ក៏ដូចជាបទពិសោធជាច្រើនបន្ថែមទៀត ពាក់ព័ន្ធទៅនឹងវិស័យបច្ចេកវិទ្យា ដែលបច្ចុប្បន្នប្រទេសកម្ពុជាកំពុងមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញឲ្យមានកំណើនអ្នកដែលមានជំនាញមួយនេះ ដើម្បីចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចេរភាព។

ចំណែកឯ ការបណ្តុះបណ្តាលធនធានមនុស្សបំរើឲ្យវិស័យអាកាសចរណ៍ស៊ីវិលនៅកម្ពុជា ដោយឆ្លងតាមរយៈប្រវត្តិសាស្ត្រថ្មីនៃការបង្កើត CATC ដោយជំនួយរបស់រដ្ឋាភិបាលកូរ៉េនេះ បានបង្កើននូវធនធានមនុស្សផ្នែកអាកាសចរណ៍នេះ ព្រមទាំងកាត់បន្ថយការចំណាយក្នុងការបញ្ជូនមន្ត្រី និងបុគ្គលិកសម្រាប់ការបណ្តុះបណ្តាលនៅក្រៅប្រទេស។ គម្រោងសម្រាប់ការបង្កើត CATC នៅក្នុងប្រទេសកម្ពុជាមានសារៈសំខាន់ណាស់ក្នុងការជួយប្រទេសកម្ពុជាឲ្យទទួលបាននូវ

ចំណេះដឹង និងបច្ចេកវិទ្យាចាំបាច់ ដើម្បីកែលម្អឧស្សាហកម្មអាកាសចរណ៍កម្ពុជា វាក៏នឹងលើកកម្ពស់វិស័យគន្លឹះសំខាន់ៗដូចជា ទេសចរណ៍និងការដឹកជញ្ជូន ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ឧស្សាហកម្មដឹកជញ្ជូនផ្លូវអាកាស ដើរតួនាទីយ៉ាងសំខាន់នៅក្នុងសកម្មភាពសេដ្ឋកិច្ចពិភពលោក ហើយវានៅតែជាផ្នែកមួយនៃវិស័យដែលរីកលូតលាស់លឿនបំផុត។ ដោយកំណើននៃវិស័យអាកាសចរណ៍ស៊ីវិល ធនធានមនុស្សផ្នែកនេះត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់ ដើម្បីដោះស្រាយលទ្ធភាពនៃផលប៉ះពាល់អវិជ្ជមានលើឧស្សាហកម្មនេះ។ ដូច្នេះ តួនាទីCATCមានសារៈសំខាន់ខ្លាំងណាស់ក្នុងការចាប់យកសន្ទុះនៃកំណើនអាកាសចរណ៍នៅក្នុងប្រទេសកម្ពុជា ក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ វាមានសារៈសំខាន់ក្នុងការបង្កើនសមត្ថភាពជាតិដើម្បីឆ្លើយតបទៅនឹងវិស័យអាកាសចរណ៍ ដែលកំពុងតែរីកចម្រើន និងកំពុងកើនឡើងយ៉ាងឆាប់រហ័សនេះ ដោយសារតែវិស័យទេសចរណ៍អាចពង្រីកសេដ្ឋកិច្ច និងពង្រឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពអន្តរតំបន់។

ហេតុនេះហើយ គម្រោងនៃការបង្កើតអគារ CKCC និង CATC នៅកម្ពុជា ពិតជាបានផ្តល់សារៈសំខាន់ណាស់ក្នុងការជួយឲ្យសិស្សនិស្សិតកម្ពុជា ទទួលបាននូវចំណេះដឹង និងបច្ចេកវិទ្យាចាំបាច់ ក្នុងការជំរុញសមត្ថភាពជាតិ ដើម្បីឆ្លើយតបទៅនឹងវិស័យទាំងឡាយ និងការពង្រីកឲ្យបាននូវសេដ្ឋកិច្ចការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។

### ៣.១.២.២. ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច

ភាពក្រីក្រនៅតែជាបញ្ហាប្រឈមមួយដ៏ធំនៅកម្ពុជា បើទោះបីជាតួរលេខនៃអត្រាភាពក្រីក្របានបង្ហាញពីការថយចុះក៏ដោយ។[41] ដោយសារតែភាពក្រីក្រមួយចំនួនធំ ស្ថិតនៅតាមជនបទដែលមានប្រជាជនភាគច្រើនពុំទទួលបានការអប់រំ និងការបណ្តុះបណ្តាលនូវជំនាញផ្សេងៗដែលជាមូលហេតុចម្បងនៃភាពក្រីក្រ។ ការអប់រំដែលមានកម្រិតទាប នាំឲ្យមានវិសមភាពការបែងចែកឱកាសនៃការអប់រំ គឺអាចជាមូលហេតុចំបងនៃភាពក្រីក្រនិងវិសមភាពសង្គមរយៈពេលវែង។ ការសិក្សាជាច្រើនបង្ហាញថា គ្រួសារដែលមានកម្រិតការអប់រំទាប មានជីវភាពក្រីក្រ គឺក្រជាងគ្រួសារដែលមានការអប់រំកម្រិតខ្ពស់។ ដោយសារពួកគេក្រ ពួកគេទំនងជាមិនវិនិយោគច្រើនលើការអប់រំកូនរបស់គេទេ ហើយមួយចំណែកធំនៃចំណូលអាចចាយបាន គឺចាយលើអាហារូបត្ថម្ភ

[41] ឧបសម្ព័ន្ធ

និងមួយភាគតូចលើការសន្សំ។ ជាលទ្ធផល ពួកគេរកចំណូលបានទាប និងចាយច្រើនលើអាហារូបត្ថម្ភ សន្សំបានតិច ឬមិនអាចសន្សំប្រាក់បាន និងចាយតិចលើការសិក្សារបស់កូន។[42]

ដើម្បីសម្រេចបាននូវកំណើននៃវិស័យអប់រំនៅតាមជនបទ ទាមទារការរួមចំណែកពីជំនួយអភិវឌ្ឍន៍ របស់ដៃគូអភិវឌ្ឍន៍ដូចជា KOICA ដែលពុំអាចខ្វះបាន។ ការអប់រំមួយនេះ ពិតជាមានសារៈសំខាន់ណាស់នៅក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ព្រោះនៅពេលដែលនៅតាមទីជនបទមានចំណេះដឹង ពួកគាត់អាចបង្កើនប្រាក់ចំណូលបាន តាមរយៈការបង្កើននូវទិន្នផលផលិតកម្ម ឬបង្កើតមុខរបរចិញ្ចឹមជីវិតផ្សេងទៀត បើទោះបីជាប្រជាជននៅតាមជនបទប្រកបរបរកសិកម្មយ៉ាងណាក៏ដោយ។ ម្យ៉ាងទៀត ប្រសិនបើពួកគាត់មានចំណេះដឹងសមរម្យកម្រិតជីវភាពរបស់ពួកគាត់កាន់តែប្រសើរជាងមុន បើទោះបីជាពួកគាត់បានធ្វើចំណាកស្រុកទៅកាន់កន្លែងផ្សេងពីស្រុកកំណើតរបស់ខ្លួន ដើម្បីទៅធ្វើការងារក៏ដោយ។ ក្នុងន័យនេះ ពួកគាត់អាចក្លាយជាបុគ្គលិកជំនាញនៅតាមរោងចក្រ ឬសហគ្រាសឧស្សាហកម្មផ្សេងៗបាន ដោយគ្រាន់តែទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈខ្លីៗមួយចំនួន ដែលត្រូវនឹងមុខជំនាញរបស់ខ្លួនកំពុងតែបម្រើការងារនាពេលបច្ចុប្បន្ន។ ជាលទ្ធផល ពួកគាត់នឹងអាចទទួលបានប្រាក់ចំណូលខ្ពស់ក្នុងការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ហើយពិសេស រូបភាពនេះនឹងនាំឲ្យមានការកាត់បន្ថយភាពក្រីក្របានមួយកម្រិតដែរ។

ហេតុនេះ ជំនួយអភិវឌ្ឍន៍ផ្លូវការមួយនេះ ពិតជាមានសារៈប្រយោជន៍ណាស់ក្នុងការធ្វើឲ្យប្រសើរឡើងនូវការអប់រំនៅតាមជនបទ ក៏ដូចជាកម្រិតជីវភាពរបស់ប្រជាជនផងដែរ ដែលជាហេតុនាំឲ្យអត្រាភាពក្រីក្រមានការថយចុះ ឈានដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

#### ៣.១.២.៣. ការរួមចំណែកក្នុងសង្គមខ្មែរ

ការចូលរួមចំណែកនៃជំនួយអភិវឌ្ឍន៍កូរ៉េ លើវិស័យអប់រំនិងការពង្រឹងសមត្ថភាពធនធានមនុស្សនៅកម្ពុជា មិនត្រឹមជួយឲ្យអ្នកទាំងនោះមានចំណេះដឹងទេ ថែមទាំងជួយឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងសង្គមជាតិទាំងមូលមានសុខសុវត្ថិភាព និងភាពថ្លៃថ្នូរក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ នៅក្នុងនោះដែរ មានមូលហេតុ ៣ ដែលសំខាន់នៅក្នុងការរួមចំណែកទាំងនេះ ៖

**មូលហេតុទី ១** ៖ ការលើកកម្ពស់និងការកែលម្អគុណភាពការអប់រំនៅតាមសាលារៀនរបស់រដ្ឋាភិបាលកូរ៉េ ក៏ដូចជាការចូលរួមណែនាំ លើកទឹកចិត្តពីសំណាក់អ្នកស្ម័គ្រចិត្តកូរ៉េផងនោះ បាន

[42] វិទ្យាស្ថានសភាកម្ពុជា,*ឯកសារស្រាវជ្រាវសង្ខេប ភូមិភាគទី៦ព្រឹទ្ធសភា ស្តីពី មូលហេតុនៃភាពក្រីក្រ និងគោលនយោបាយពាក់ព័ន្ធទីជនបទនៅកម្ពុជា* (២០១៥), ទំព័រទី៧ ។

ជំរុញលើកទឹកចិត្តដល់ឪពុកម្តាយឬអាណាព្យាបាលតាមមូលដ្ឋាននៅជនបទ បញ្ជូនបុត្រធីតាខ្លួនទៅសិក្សា បើទោះបីលទ្ធភាពផ្គត់ផ្គង់ការសិក្សាកូនរបស់ពួកគាត់នៅមានកម្រិតយ៉ាងណាក៏ដោយក៏ពួកគាត់មានបំណងចង់ឲ្យកូនៗអាចអាន សរសេរអក្សរនិងគណនាលេខបានដែរ។ សកម្មភាពនេះហើយ បានជំរុញឲ្យមានអត្រាចូលរៀនរបស់កុមារមានការឡើងគួរឲ្យកត់សម្គាល់ ខណៈដែលវាអាចកែប្រែអនក្ខរជននៅកម្ពុជា ឲ្យក្លាយជាអក្ខរជនវិញ ហើយពួកគាត់អាចរស់នៅនិងប្រកបរបរសមស្របដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។

**មូលហេតុទី២** ៖ ប្រជាពលរដ្ឋកម្ពុជានឹងយល់ដឹងច្រើនពីបរិបទសង្គមដែលខ្លួនកំពុងរស់នៅបន្ទាប់ពីពួកគាត់ទទួលបានការអប់រំ ហើយថែមទាំងដឹងពីអំពើណាដែលគប្បីប្រព្រឹត្តនិងអំពើណាដែលមិនគួរគប្បីប្រព្រឹត្ត ចៀសវាងការនាំទុក្ខទោសដល់ខ្លួនឯង គ្រួសារ និងនាំឲ្យសង្គមជាតិមានភាពអាណាធិបតេយ្យ។ ជាក់ស្តែង ភាគច្រើននៃអ្នកដែលមិនទទួលបានការអប់រំ ឬទទួលបានការអប់រំតិចតួច តែងជួបប្រទះការលំបាកក្នុងជីវភាពរស់នៅ ហើយពេលខ្លះដើម្បីបំពេញក្រពះរបស់ខ្លួន ពួកគាត់ក្លាយជាជនពាល អាវាសែនៅក្នុងសង្គម លួច ឆក់ ប្លន់អ្នកដទៃ ហើយសេពគប់ជាមួយ ក្មេងទំនើងផ្សេងទៀត រួចក៏បង្កសកម្មភាពចលាចល ធ្វើឲ្យអសន្តិសុខក្នុងសង្គម ។

**មូលហេតុទី ៣** ៖ ជាទូទៅ អនក្ខរជនត្រូវបានគេមើលងាយ និងរើសអើងនៅក្នុងសង្គម។ ជាក់ស្តែង អ្នកដែលមិនបានទទួលការអប់រំ តែងត្រូវគេកំណត់ថាជាអ្នកដែលមិនបានយល់ដឹងអ្វីពីសង្គមឡើយ ហេតុនេះនៅក្នុងការសម្រេច និងព្រឹត្តិការណ៍នានាដែលមាននៅក្នុងសង្គមតែត្រូវបានគេមិនឲ្យចូលរួមទេ។ ដូច្នេះហើយ ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋពិតជាសំខាន់ណាស់ ដែលជួយឲ្យពួកគាត់រស់នៅក្នុងភាពថ្លៃថ្នូរ និងអាចធ្វើការសម្រេចចិត្តសំខាន់ៗដែលមាននៅក្នុងសង្គមដែលពួកគាត់រស់នៅបាន ដោយមិនត្រូវបានអ្នកដទៃរើសអើងនោះទេ ។

ហេតុនេះ ជំនួយអភិវឌ្ឍន៍របស់កូរ៉េលើវិស័យអប់រំនៅកម្ពុជា ពិតជាបានរួមចំណែកសំខាន់ណាស់នៅក្នុងការលើកកម្ពស់ កម្រិតជីវភាពរស់នៅប្រចាំថ្ងៃ សេចក្តីថ្លៃថ្នូរ និងការចូលរួមក្នុងសង្គម របស់ប្រជាជនកម្ពុជាប្រាកដមែន ។

### ៣.១.២.៤. ការទាក់ទាញវិនិយោគិនពីបរទេស

សមត្ថភាពរបស់ធនធានមនុស្ស អាចជាចំណែកមួយនៅក្នុងកត្តាជាច្រើនដទៃទៀតក្នុងការទាក់ទាញអ្នកវិនិយោគផ្ទាល់ពីបរទេស ព្រោះអ្នកទាំងនោះជាចំណែកដ៏សំខាន់និងមិនអាចខ្វះ

បានក្នុងការបង្កើតផលិតផលនិងសេវាកម្ម។[43] ស្របពេលដែលកម្ពុជាកំពុងតែបោះជំហានចេញពីប្រទេសកសិកម្ម មកជាប្រទេសដែលពឹងផ្អែកលើឧស្សាហកម្ម វាទាមទារឲ្យមានការអភិវឌ្ឍលើមូលធនមនុស្សនៅក្នុងវិស័យមួយនេះយ៉ាងខ្លាំង។ ហេតុដូចនេះទើប ក្រសួងការងារបានខិតខំប្រឹងប្រែងក្នុងការសហការជាមួយនឹងដៃគូអភិវឌ្ឍនានា ដើម្បីជំរុញឲ្យវិស័យ TVET កាន់តែអភិវឌ្ឍខ្លាំងឡើង ហើយក្រសួងក៏បានប្រើប្រាស់នូវផែនការមេ ដែលមានការប្រឹក្សាយោបល់លើការរៀបចំ និងអនុវត្តន៍ប្រព័ន្ធគុណវុឌ្ឍិវិជ្ជាជីវៈថ្នាក់ជាតិ សម្រាប់ TVET នៅកម្ពុជា តាមរយៈ KOICA ក្នុងគោល-បំណងជំរុញឲ្យនិស្សិតជ្រើសរើសមុខវិជ្ជា TVET ជាអាជីពនៅថ្ងៃអនាគត ដើម្បីទទួលបានឱកាសការងារយ៉ាងសម្បូរបែបនៅក្នុងពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគតផងដែរ។ តួយ៉ាង យុវជនកម្ពុជា ដែលទទួលបានការបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងវិជ្ជាជីវៈនាពេលបច្ចុប្បន្ននេះ បានបង្កើនសមត្ថភាពរបស់ខ្លួនកាន់តែខ្លាំងឡើង ស្របតាមស្តង់ដារកំណត់ដោយនិយោជក និងផ្នែកឧស្សាហកម្មដូចជាជំនាញមេកានិក សំណង់ ធុរកិច្ច ព័ត៌មានវិទ្យា កម្មន្តសាលអគ្គិសនី ក្រឡឹង កែច្នៃម្ហូបអាហារ និងផ្នែកសេវាកម្មមួយចំនួនទៀត។[44]

**៣.១.២.៥. ការកសាងកិត្តិយសជូនជាតិ**

ប្រទេសមួយដែលមានប្រជាជនតិចមិនមែនជាបញ្ហានោះទេ តែអ្វីដែលជាបញ្ហានោះគឺប្រទេសដែលមានអ្នកចេះដឹងតិច ស្របពេលដែលមិនមានការលើកតម្កើន និងប្រើប្រាស់ដើម្បីផលប្រយោជន៍ជាតិ។ ត្រង់ចំណុចនេះហើយ ដែលរដ្ឋាភិបាលកម្ពុជាខិតខំយកចិត្តទុកដាក់លើប្រជាពលរដ្ឋខ្មែរគ្រប់រូប ឲ្យមានការអប់រំ ដើម្បីបណ្តុះសីលធម៌ គុណធម៌ ចំណេះដឹង និងជំនាញវិទ្យាសាស្ត្រពិត ការយល់ដឹងពីច្បាប់ ក្នុងគោលបំណងធានាឲ្យបានថាជាពលរដ្ឋថ្លៃថ្នូរដែលជាកម្លាំងចលករដ៏សំខាន់ ក្នុងការអភិវឌ្ឍប្រទេសជាតិ អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ សម្បត្តិវប្បធម៌ ប្រពៃណីរបស់ជាតិ។ តាមរយៈសកម្មភាពនេះនឹងនាំឲ្យមានការកសាងកេរ្តិ៍ឈ្មោះនិងកិត្យានុភាពរបស់កម្ពុជាលើឆាកអន្តរជាតិផងដែរ ។

ម្យ៉ាងវិញទៀត ចំពោះវិស័យកីឡានៅកម្ពុជាវិញ កន្លងមក KOICA បានចូលរួមចំណែកទៅលើវិស័យមួយនេះយ៉ាងខ្លាំង ដោយមានការផ្តោតសំខាន់ប្រភេទកីឡាតែក្វាន់ដូ ដែលកន្លងមក

[43] អ៊ិត សំហេង, "សេចក្តីថ្លែងសន្ទរកថា," (ក្នុងពិធីប្រកាសផ្សព្វផ្សាយ និងចុះហត្ថលេខាលើកម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិ ស្តីពីមុខរបរ និងការងារសម្រាប់យុវជននៅកម្ពុជា, សណ្ឋាគារឡឺរ៉ូយ៉ាល់, ៣១ សីហា ២០១៧)។

[44] http://www.lareine.com.kh/news/education/19748/ (ចូលទស្សនា ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៨)។

ពិភពលោកបានស្គាល់កម្ពុជា កាន់តែច្បាស់តាមរយៈប្រភេទកីឡាមួយនេះ គឺការដណ្តើមបាននូវមេដៃមាសក្នុងព្រឹត្តិការណ៍ការប្រកួតកីឡាអូឡាំពិក របស់វីរនារីតៃក្វាន់ដូ ស៊ន សៀវម៉ី ។

## ៣.២. បញ្ហាប្រឈម និងដំណោះស្រាយ

### ៣.២.១. បញ្ហាប្រឈម

#### ៣.២.១.១. អំឡុងពេលសហការអនុវត្តន៍គម្រោង[45]

##### ក. ការបែងចែកថវិកា

នៅក្នុងចំណុចនេះ យើងសង្កេតឃើញថា មន្ត្រីមួយចំនួនដែលបម្រើក្នុងស្ថាប័នពាក់ព័ន្ធជាមួយនិង KOICA បានរៀបចំបែងចែកកញ្ចប់ថវិកាហាក់ដូចជាពុំសូវជាមានប្រសិទ្ធភាពសម្រាប់ការអនុវត្តគម្រោងនៅឡើយ ពោលគឺមានការលេចឡើងនូវការប្រើប្រាស់ថវិកាមិនចំគោលដៅ និងអំពើពុករលួយតាមការិយាល័យធិបតេយ្យ។ ហេតុនេះ ការអនុវត្តគម្រោងមួយចំនួនក្នុងវិស័យអប់រំកន្លងមក មានការប្រឈមនឹងការខ្វះខាតថវិកា ដែលធ្វើឲ្យមានការរាំងស្ទះដល់ការបញ្ចប់គម្រោង ហើយភាគីដែលពាក់ព័ន្ធដូចជា MoEYS និង KOICA ក៏បានព្យាយាមស្វែងរកការសហការបន្ថែមពីអង្គភាពផ្សេងៗទៀត ដើម្បីបន្តការអនុវត្តគម្រោង សម្រេចបានគោលដៅដែលបានគ្រោងទុក ។

##### ខ. ខ្វះខាតការណែនាំពីការសាងសង់

ទាក់ទងនឹងការសិក្សាស្រាវជ្រាវរួមគ្នារវាងអ្នកជំនាញដែលមកពីប្រទេសកូរ៉េ និងនៅកម្ពុជា គេមើលឃើញថាការណែនាំលម្អិតពាក់ព័ន្ធនឹងការអនុវត្តគម្រោងដូចជា ការសាងសង់អាគារសិក្សាជាដើម ដល់អ្នកជំនាញជនជាតិកម្ពុជាពីសំណាក់អ្នកជំនាញបរទេស ដើម្បីធ្វើការសិក្សាឲ្យបានឆាប់រហ័សនិងមានប្រសិទ្ធភាពនោះ ហាក់មិនទាន់បានល្អប្រសើរនៅឡើយ ។ កត្តានេះ អាចបណ្តាលមកពីបញ្ហាភាសានិងការទំនាក់ទំនងដូចបង្ហាញក្នុងចំណុច គ. ខាងក្រោម ដែលនេះ ធ្វើឲ្យមានការរាំងស្ទះដល់ការអនុវត្តគម្រោងផងដែរ។

##### គ. ភាសានិងការទំនាក់ទំនង

ទាំងក្នុងអំឡុងពេលការសហការអនុវត្តកម្មវិធីអភិវឌ្ឍន៍នៅកម្ពុជា និងការបណ្តុះបណ្តាលបណ្តាលសិក្ខាកាមនៅឯប្រទេសកូរ៉េ ដែលបានបញ្ជូនទៅសិក្សានិងទទួលយកបទពិសោធនៃការ

[45] Kinm Sung-hee និងShin Jung-yeon, "Aid-for-trade case study: Republic of South Korea [ជំនួយសម្រាប់ធុរកិច្ចករណីសិក្សា៖ សាធារណៈរដ្ឋកូរ៉េ]." (ឯកសារថតចម្លង, ២០១១), ទំព័រទី ៣។

អភិវឌ្ឍរបស់ប្រទេសកូរ៉េ ក្នុងគោលបំណងដើម្បីពង្រឹង និងពង្រីកលទ្ធភាពការអនុវត្តគម្រោងបន្ត នៅកម្ពុជា តែងជួបប្រទះនឹងបញ្ហាទំនាក់ទំនង ដោយសារភាសាប្រើប្រាស់ខុសគ្នា។

**ឃ. កង្វះខាតគ្រឿងបន្លាស់ និងសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ទំនើបៗ**

គ្រឿងបរិក្ខារដែលផ្តល់ដោយប្រទេសកូរ៉េ ភាគច្រើនជាផលិតផលបច្ចេកវិទ្យាខ្ពស់ ដូច្នេះ ហើយនៅពេលដែលមានបញ្ហាខូចខាត ឬមិនដំណើរការអ្វីនោះ វាពិតជាពិបាកក្នុងការស្វែងរក គ្រឿងបន្លាស់ ឬជួសជុលណាស់នៅប្រទេសកំពុងអភិវឌ្ឍន៍ដូចជា ប្រទេសកម្ពុជាមួយនេះ។ ទន្ទឹមនឹងនោះ ឧបករណ៍ទាំងនោះទាមទារឲ្យមានការមើលថែទាំ ពីអ្នកជំនាញក្នុងការប្រើ និងផ្ទេរ ជំនាញចាំបាច់ក្នុងការប្រើប្រាស់ ឲ្យបានគ្រប់គ្រាន់ផងដែរ ខណៈពេលប្រទេសកម្ពុជា ពុំសូវមាន អ្នកជំនាញខាងមេកានិចច្រើននៅឡើយនោះ។

**ង. ការអនុវត្តគម្រោងតាមមូលដ្ឋាននៅមានកម្រិត**

ភាពមិនអំណោយផលខាងផ្លូវគមនាគមន៍ នៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា ហាក់មិនអំណោយផលដល់ការអនុវត្តគម្រោងជាក់ស្តែងរបស់ KOICA ទាល់តែសោះ ដែលជា ហេតុ ធ្វើឲ្យការអនុវត្តជំនួយលើគម្រោងនិងកម្មវិធីអភិវឌ្ឍន៍មួយចំនួនរបស់ប្រទេសកូរ៉េ មិនបាន ជ្រាបទៅដល់មូលដ្ឋានរបស់ប្រជាជន ទាំងអស់នោះទេ ។

**៣.២.១.២. ក្រោយពេលបញ្ចប់គម្រោង**[46]

**ក. តម្រូវការថវិកាបន្ថែម**

ក្រោយពេលបញ្ចប់គម្រោង តែងមានការអង្កេត តាមដាន វាយតម្លៃ និងការធ្វើផែនការ ប្រតិបត្តិការប្រចាំឆ្នាំ ដែលទាមទារថវិកាបន្ថែម។ ជាក់ស្តែងដូចជា គម្រោង CATC តម្រូវឲ្យមាន ការធ្វើផែនការប្រតិបត្តិការប្រចាំឆ្នាំ ក៏ប៉ុន្តែគេសង្កេតឃើញថា វាមិនទាន់មានថវិកាគ្រប់គ្រាន់ ដើម្បីធ្វើនៅឡើយ ។

**ខ. កង្វះខាតបុគ្គលិក**

ក្នុងចំណុចនេះដែរ ចំពោះគម្រោងដូចជា ការកសាងអាគារមជ្ឈមណ្ឌល តម្រូវឲ្យមាន បុគ្គលិកបម្រើការងារជាច្រើននាក់។ ជាឧទាហរណ៍ គម្រោង CATC ដដែល នៅមានតម្រូវការ បុគ្គលិកជាច្រើននាក់ ជាពិសេសអ្នកធ្វើការងារពេញម៉ោង មានជំនាញពាក់ព័ន្ធនឹងអាកាសចរណ៍ ដើម្បីបម្រើការងារនៅក្នុងអាគារថ្មីមួយនេះ ។

[46] ហ្វូត ស្រី, "វិស័យហេដ្ឋារចនាសម្ព័ន្ធរបស់ KOICA នៅកម្ពុជា និងគម្រោង CATC." (បទបង្ហាញក្នុងកម្មវិធីចែករំលែក ចំណេះដឹង (KSP), ការិយាល័យ KOICA ប្រចាំកម្ពុជា, ភ្នំពេញ, ១១ តុលា ២០១៧)។

**គ. មិនមានអ្នកជំនាញបច្ចេកទេស**

ដោយសារគម្រោងដែលបញ្ចប់ តែងមានការប្រើប្រាស់គ្រឿងម៉ាស៊ីនទំនើបៗទាន់សម័យ ហេតុដូចនេះ វាទាមទារអ្នកជំនាញក្នុងការមើលថែទាំ និងប្រើប្រាស់គ្រឿងបរិក្ខារទាំងនោះប្រកបដោយប្រសិទ្ធភាព។ ក៏ប៉ុន្តែ អ្នកជំនាញទាំងនោះនៅកម្ពុជា ហាក់ពុំទាន់មានច្រើននៅឡើយ ដែលជាហេតុធ្វើឲ្យខ្វះអ្នកជំនាញ និងតម្រូវឲ្យមានអ្នកជំនាញដែលមកពីកូរ៉េធ្វើការបង្ហាត់បង្រៀនពីរបៀបប្រើប្រាស់សម្ភារទាំងនោះផង ។

**ឃ. ការខ្វះខាតសម្ភារ គ្រឿងបរិក្ខារទំនើបៗ**

ជាការពិតណាស់ គម្រោងពាក់ព័ន្ធនឹងការសាងសង់ និងកែលម្អគុណភាពសាលារៀនដែលបានអនុវត្តន៍ តែងមានការបំពាក់នៅគ្រឿងបរិក្ខារទាន់សម័យ ក៏ប៉ុន្តែវាមិនទាន់ឆ្លើយតបនឹងតម្រូវការទាំងស្រុងនៅឡើយទេ។ តួយ៉ាង គម្រោង CATC គ្រាន់តែមានជណ្ដើរយន្ត ច្រកទ្វារចេញ-ចូល និងCCTV និងគ្រឿងបរិក្ខារទំនើបៗមួយចំនួនទៀតតែប៉ុណ្ណោះ ចំណែកបណ្ណាល័យពុំទាន់មានសៀវភៅឬឯកសារគ្រប់គ្រាន់នៅឡើយ។ មួយវិញទៀតបើ ឧបករណ៍ទំនើបទាំងនោះមានការខូចខាត ឬដំណើរការមិនប្រក្រតីណាមួយ ទាមទារការផ្លាស់ប្ដូរគ្រឿងបន្លាស់ វានឹងក្លាយទៅជាបញ្ហាប្រឈម ដោយសារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជានេះ ពុំសូវមានគ្រឿងបន្លាស់បរិក្ខារទំនើបៗទាំងនោះសម្បូរបែបនៅឡើយទេ។

**៣.២.១.៣. ភាពស្មុគស្មាញនៅក្នុង KOICA[47]**

**ក. នីតិវិធីសហការគម្រោង**

នីតិវិធីរបស់ប្រទេសកូរ៉េផ្ទាល់មានភាពស្មុគស្មាញ សម្រាប់ឲ្យម្ចាស់ជំនួយដទៃទៀតធ្វើកិច្ចសហការគម្រោងជាមួយ។ ខណៈពេលដែលប្រទេសកូរ៉េកំពុងមានបំណងចូលរួមក្នុងកម្មវិធីជំនួយដែលមានស្រាប់ ប្រទេសមួយនេះមិនទាន់មានបទពិសោធគ្រប់គ្រាន់នៅឡើយក្នុងការតាក់តែង និងផ្តួចផ្តើមកម្មវិធីផ្តល់ជំនួយរួមគ្នាថ្មីឬក៏យន្តការឧបត្ថម្ភថវិកានោះទេ។

**ខ. តម្លាភាព និងការចូលរួមក្នុងកិច្ចការសាធារណៈជាមួយសង្គមស៊ីវិល**

ប្រទេសកូរ៉េ ពុំសូវមានការបញ្ចេញព័ត៌មានដែលទាក់ទងនឹងជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ខ្លួនឲ្យសាធារណៈជន ជាពិសេសភាគីដែលពាក់ព័ន្ធដូចជា សមាជិកសភា សង្គមស៊ីវិល និងប្រទេសជាដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើការស្វែងយល់ និងផ្តល់មតិយោបល់នោះទេ។ ការណ៍នេះ បានបង្ហាញពីអតម្លាភាពនៃការផ្តល់ហិរញ្ញប្បទាន និងលទ្ធផលនៃការអនុវត្តគម្រោងរបស់កូរ៉េ ដែល

---

[47] http://dx.doi.org/10.1787/9789264288829-en (ចូលទស្សនាទស្សនាថ្ងៃទី ២៨ មីនា ២០១៩) ។

ធ្វើឲ្យមជ្ឈដ្ឋានទូទៅដូចជា សង្គមស៊ីវិលបានធ្វើការរិះគន់កម្រិតនៃព័ត៌មានសាធារណៈដែលស្តីពីកម្មវិធីជំនួយរបស់ប្រទេសកូរ៉េ ទៀតផង ។

**គ. ខ្វះអ្នកជំនាញបច្ចេកទេស**

ក្រុមការងាររបស់ KOICA ប្រចាំកម្ពុជា កាលពីឆ្នាំ ២០១៧ មានតែ ៤នាក់ដែលមកពី KOICA ការិយាល័យកណ្តាល និងបុគ្គលិកក្នុងស្រុកចំនួន ១៩នាក់ រួមជាមួយអ្នកហាត់ការចំនួន ៦នាក់ប៉ុណ្ណោះ ដែលគ្រប់គ្រងលើកម្មវិធីដែលមានទាំងអស់ក្នុងប្រទេស និងសម្របសម្រួលការរៀបចំយុទ្ធសាស្ត្ររបស់ប្រទេសកូរ៉េ។ ស្របពេលដែលការអនុវត្តលើគម្រោងក្នុងវិស័យអាទិភាពកាន់តែស៊ីជម្រៅ តែប្រព័ន្ធគ្រប់គ្រងគម្រោងមានភាពស្មុគស្មាញ វានឹងធ្វើឲ្យការតាក់តែងនូវការអនុវត្តគម្រោង និងការធ្វើរបាយការណ៍កាន់តែប្រឈមនឹងហានិភ័យកាន់តែខ្លាំង។

**ឃ. ចំណេះដឹងភាសានៅមានកម្រិត**

ឯកសារ និងឱកាសហ្វឹកហាត់ការងារជាច្រើនសុទ្ធតែជាភាសាកូរ៉េ ដែលនេះទាមទារឲ្យមានការបកប្រែ និងកែសម្រួលជាភាសាជាតិ ហេតុនេះ វាក៏ក្លាយជាបញ្ហាប្រឈមចំពោះបុគ្គលិកដែលជាជនជាតិខ្មែរកំពុងបម្រើការងារក្នុងការិយាល័យ KOICA ប្រចាំកម្ពុជា។

**៣.២.១.៤. ចំពោះអ្នកស្ម័គ្រចិត្តរបស់ KOICA នៅកម្ពុជា**

- **សុវត្ថិភាព** ៖ បញ្ហាសុវត្ថិភាព និងសន្តិសុខសង្គមនៅកម្ពុជា ជាបញ្ហាមួយដែលមជ្ឈដ្ឋានទូទៅ មិនថាពលរដ្ឋកម្ពុជា ឬជនបរទេសទេនៅតែមានការព្រួយបារម្ភ បើទោះបីជាមានការអះអាងពីអាជ្ញាធរថា ស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសមានសន្តិសុខល្អក៏ដោយ។ ជាពិសេសនៅតាមតំបន់ជនបទ ដែលអ្នកស្ម័គ្រចិត្តទាំងនោះចុះតាមមូលដ្ឋានដើម្បីបំពេញការងារឲ្យកាន់តែជិតស្និទ្ធជាមួយនឹងប្រជាជនមូលដ្ឋាននោះ ពុំទាន់មានការធានាការធ្វើដំណើរនិងការស្នាក់នៅរបស់ពួកគាត់ឲ្យមានសុវត្ថិភាពទាំងស្រុងនៅឡើយ។
- **ទំនាក់ទំនង និងការយល់ដឹងពីវប្បធម៌រវាងគ្នាទៅវិញទៅមក** ៖ ការបរិភោគ ការស្លៀកពាក់ ការទំនាក់ទំនងភាសា និងប្រពៃណីទំនៀមទម្លាប់មួយចំនួន ហាក់មិនដូចគ្នានោះទេរវាងប្រជាជនកូរ៉េនិងកម្ពុជា ដែលនេះជាបញ្ហាមួយតែងកើតមានចំពោះអ្នកស្ម័គ្រចិត្តកូរ៉េដោយត្រូវសម្របខ្លួននឹងបរិយាកាសការរស់នៅខុសគ្នានេះ។
- **រយៈពេលស្ម័គ្រចិត្ត** ៖ ជាទូទៅត្រូវបានបញ្ចប់លឿន និងការបញ្ជូនអ្នកស្ម័គ្រចិត្តនៅសភាពយឺតយ៉ាវ ដោយសារកាលកំណត់ចំពោះការបញ្ជូនអ្នកស្ម័គ្រចិត្ត ជួនកាលត្រូវបានធ្វើឡើងនៅពាក់កណ្តាលឆ្នាំឯណោះ។

- កង្វះកិច្ចសហការពីឪពុកម្ដាយនៅតាមមូលដ្ឋាន ដើម្បីឲ្យអ្នកស្ម័គ្រចិត្តស្វែងយល់បន្ថែមពីបញ្ហាដែលកំពុងប្រឈមចំពោះការសិក្សារបស់កូនៗ។
- គុណវុឌ្ឍិរបស់អ្នកស្ម័គ្រចិត្ត មិនទាន់ឆ្លើយតបនឹងតម្រូវការដែលមាននៅក្នុងសង្គម ឬមិនទាន់ឆ្លើយតបនឹងការរំពឹងទុករបស់អង្គភាពដែលអ្នកស្ម័គ្រចិត្តធ្វើការក្នុង។
- ការស្វែងយល់លើកម្មវិធី KOV របស់អង្គភាពទាំងនោះនៅមានកម្រិតនៅឡើយ។
- កាលវិភាគការងាររបស់ KOV មិនទាន់មានភាពច្បាស់លាស់ ដើម្បីឲ្យ KOV ធ្វើការប្រកបដោយប្រសិទ្ធភាព។
- កង្វះធនធានមនុស្ស ដោយសារតែពិបាកក្នុងការជ្រើសរើសអ្នកស្ម័គ្រចិត្ត ។

### ៣.២.២. ដំណោះស្រាយ

#### ៣.២.២.១. អំឡុងពេល និងក្រោយពេលអនុវត្តន៍គម្រោង

##### ក. ការបែងចែកថវិកា

កន្លងមក KOICA បានអនុវត្តវិធីសាស្ត្រ ២ ដែលមានប្រសិទ្ធភាព ដើម្បីដោះស្រាយលើបញ្ហាកង្វះថវិកាសម្រាប់ ការអនុវត្តកម្មវិធីអភិវឌ្ឍន៍ និងការខ្វះខាតគ្រឿងបរិក្ខារផងនោះ។ **ទីមួយ** KOICA ធ្វើការប្រកាសអញ្ជើញចូលរួមពិគ្រោះថ្លៃ ឬដាក់ដេញថ្លៃនៅលើគេហទំព័រផ្លូវការរបស់ខ្លួន និងមានការចុះផ្សព្វផ្សាយព័ត៌មានលើទំព័រកាសែត និងគេហទំព័រផ្សព្វផ្សាយព័ត៌មានផ្សេងៗ។[48] ពាក់ព័ន្ធនឹងការដេញថ្លៃនេះ ក្រុមហ៊ុនក្នុងនិងក្រៅស្រុក អាចដាក់សំណើកិច្ចព្រមព្រៀងអនុវត្តន៍នានា។ ម្យ៉ាងវិញទៀត ការដាក់ដេញថ្លៃនេះ មិនសំដៅផ្ដល់អាទិភាពដល់ក្រុមហ៊ុនមកពីប្រទេសណាមួយទេ សូម្បីក្រុមហ៊ុននោះជាក្រុមហ៊ុនកូរ៉េក៏ដោយ ហើយមិនអនុញ្ញាតឲ្យមានការវិនិយោគរួមទេ។ ចំណែកឯ **ទីពីរ KOICA** ប្រើប្រាស់ថវិកាដែលនៅសល់ពីការអនុវត្តន៍គម្រោងកន្លងមក។[49]

បើទោះបីជា វិធីសាស្ត្រទាំង ២ខាងលើ ជាជម្រើសដ៏មានអាទិភាពហើយ តែវាអាចប្រឈមនឹងហានិភ័យមួយចំនួន ដូចជា ការដាក់ដេញថ្លៃមិនទាន់ឆ្លើយតបទៅនឹងតម្រូវការ ឬថវិកាដែលនៅសល់ពីគម្រោងចាស់ មិនអាចបំពេញភាពខ្វះខាតនៃការអនុវត្តគម្រោង។ ជាការពិតណាស់ ការអនុវត្តគម្រោងជំនួយរបស់ KOICA កន្លងមក មិនមានការលេចឡើងនូវបញ្ហាខាង-លើនេះទេ ក៏ប៉ុន្តែ ដើម្បីបង្ការហានិភ័យទាំងនេះ ទាំងអ្នកផ្ដល់ជំនួយ (កូរ៉េ) ក៏ដូចជា ម្ចាស់គម្រោង (កម្ពុជា) ត្រូវតែលម្អិតទៅលើការត្រៀមថវិកាជំនួយ នៅពេលវាយតម្លៃអំពីគម្រោងនៅមុនពេល

[48] ឧបសម្ព័ន្ធ

[49] ឧបសម្ព័ន្ធ

ចាប់ផ្ដើមអនុវត្ត និងតាមដានការបែងចែកថវិកាជំនួយ ថាតើគួរតែបង្កើនកញ្ចប់ថវិកាបម្រុងដែលមានស្រាប់ដែរ ឬទេ។

ចំពោះ បញ្ហាអំពើពុករលួយក្នុងប្រទេសកម្ពុជា ប្រទេសកូរ៉េត្រូវពង្រឹងការណែនាំស្ដីពី ការគ្រប់គ្រង តាមរយៈការរៀនសូត្រពីដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលមានវត្តមាននៅកម្ពុជា ក៏ដូចជាពី GOVNET (បណ្ដាញ OECD-DAC ស្ដីពីអភិបាលកិច្ច) លើវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយអំពើពុករលួយបាន។

